សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីក្នុងរឿងក្ដីរដ្ឋប្បវេណីនៅសាលាដំបូងរាជធានីភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ប្រុស ពិសិដ្ឋ**

លោក **សូ វិជ័យ**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ញឹក ឧុឌ្ឌី**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# នីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីនៅសាលាដំបូងរាជធានីភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ប្រុស ពិសិដ្ឋ**

លោក **សូ វិជ័យ**

ណែនាំដោយ

សាស្ត្រាជំនួយ **ញឹក ខុឌ្ធី**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **សូ ទិវ័យ** និងខ្ញុំបាទឈ្មោះ **ប្រុស ពិសិដ្ឋ** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែក នីតិសាស្រ្តឆ្នាំទី៤ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចសូមសម្តែងនូវកតញ្ញូតាធម៌សូមសម្តែងការគោរពដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុកឈ្មោះ **សូ តីរុន** និងលោកឪពុកឈ្មោះ **ផាន់ ប្រុស**

អ្នកម្តាយឈ្មោះ **សុខ ស្រីធឿន** និងអ្នកម្តាយឈ្មោះ **ជា ផល**

ដ៏មានគុណទាំងបួនដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងដល់យើងខ្ញុំទាំងពីរនាក់តាំងពីចាប់កំណើតរហូតដល់ធំដឹងក្តីពេញរូបពេញរាង។ លោកទាំងពីរនាក់តែងតែយកចិត្តទុកដាក់ពុះពារគ្រប់ឧបសគ្គដើម្បីផ្គត់ផ្គង់ទាំងមិនគិតពីសុខទុក្ខលំបាករបស់ខ្លួនឯងធ្វើយ៉ាងណាឱ្យកូនបានទទួលការអប់រំឱ្យមានចំណេះដឹង និងមានចំណេះដឹងមកដល់សព្វថ្ងៃ។ បើគ្មានអ្នកមានគុណទាំងពីរ យើងទាំងពីរនាក់ក៏មិនទទួលបានអ្វីៗមកដល់សព្វថ្ងៃដែលព្រហ្មវិហារធម៌ និងឧបការគុណរបស់អ្នកទាំងពីរពិតមានតម្លៃណាស់មិនអាចកាត់ថ្លៃបានឡើយ។

ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធាន ដេប៉ាតឺម៉ង់អនុប្រធានដេប៉ាតឺម៉ង់និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

លោក លោកស្រីដែលជា សាស្រ្តាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការបង្ហាត់បង្រៀន និងអប់រំឱ្យយើងខ្ញុំទាំងពីរនាក់ក៏ដូចជានិស្សិតទាំងអស់ឱ្យមានចំណេះដឹងដើម្បីចូលរួមចំណែកកសាងធនធានមនុស្ស និងកសាងប្រទេសជាតិនាថ្ងៃមុខ។

ឯកឧត្តម **លី ឆេង** ព្រមទាំងគ្រួសារដែលបានផ្តល់ឱកាសការងារ និងណែនាំនូវដំបូន្មានល្អដល់រូបខ្ញុំបាទ។

ជាពិសេសសាស្រ្តាចារ្យជំនួយ **ញឹក ឧុធ្នី** ដែលបានបង្ហាត់បង្រៀន អប់រំ ទូន្មានបង្ហាញណែនាំផ្លូវដ៏ល្អសម្រាប់ពួកយើង ព្រមទាំងណែនាំក្រុមខ្ញុំបាទទាំងពីរនាក់ ក្នុងការសរសេរអត្ថបទសារណាស្រាវជ្រាវនេះដោយបានផ្តល់នូវគំនិត និងវិធីសាស្រ្តតាំងពីដើមរហូតបានសម្រេចជាលទ្ធផល។ នូវសេចក្តីដឹងគុណនេះពួកខ្ញុំទាំងពីរនាក់សូមធ្វើការបួងសួងដល់វត្ថុសាកសិទ្ធិទាំងអស់នៅក្នុងពិភពលោក សូមជួយថែរក្សាការពារលោកសាស្រ្តចារ្យព្រមទាំងក្រុមគ្រួសារទទួលបាននូវសេចក្តីសុខ សេចក្តីចម្រើនព្រមទាំងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីអាកខានឡើយ។

# អារម្ភកថា

ដោយសារតែក្នុងមុខវិជ្ជានីតិរដ្ឋប្បវេណីវាមានភាពស្មុគស្មាញ ហើយពិបាកយល់ជាច្រើននៃនីតិវិធីក្នុងការដាក់ពាក្យបណ្តឹងរហូតដល់ចេញសាលក្រមរបស់តុលាការដូច្នេះវាធ្វើឱ្យមានការវែកញែកជាច្រើន និងការមិនច្បាស់លាស់ណាមួយទើបយើងខ្ញុំទាំងពីរសរសេរចងក្រងឯកសារនេះឡើងដើម្បីបញ្ជាក់ជួយសម្រួលដល់ការប្រើប្រាស់ផ្សេងៗ និងដើម្បីឱ្យនិស្សិតច្បាប់បានយល់ដឹងអំពីលំហូរនៃនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីឱ្យកាន់តែច្បាស់ ។

បន្ទាប់ពីបានធ្វើការសិក្សាយ៉ាងលម្អិតរយៈពេល ៤ឆ្នាំ កន្លងមកលើផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះដើម្បីជាសក្ខីភាពដែលជាស្នាដៃជំនួយដល់ការសិក្សារបស់និស្សិតជំនាន់ក្រោយ ខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយស្តីពី "នីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីនៅសាលាដំបូងរាជធានីភ្នំពេញ" យកមកធ្វើជាប្រធានបទក្នុងការសិក្សាស្រាវជ្រាវ ដើម្បីចងក្រងជារបាយការណ៍បញ្ចប់ការសិក្សា ។ ដោយមានការជ្រោមជ្រែង និងការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ក្នុងការបង្ហាត់បង្រៀនអស់ពីកម្លាំងកាយចិត្តទាំងអស់នេះហើយ ទើបធ្វើឱ្យយើងខ្ញុំអាចឈានមកដល់ការចងក្រងសារណាថ្នាក់បរិញ្ញាបត្រជំនាន់ទី២៤ និងដើម្បីចូលរួមចំណែកក្នុងការចែករំលែកចំណេះដឹងមួយចំនួនដល់និស្សិតជំនាន់ក្រោយផង។

មូលហេតុចម្បងដែលខ្ញុំបាទសម្រេចចិត្តជ្រើសរើសប្រធានបទមួយនេះ ដើម្បីយកមករៀបរៀងជាសៀវភៅសារណាដើម្បីបញ្ចប់ការសិក្សានោះ គឺយើងខ្ញុំបាទយល់ឃើញថាដោយសារតែក្នុងមុខវិជ្ជានីតិរដ្ឋប្បវេណីវាមានភាពស្មុគស្មាញ ហើយពិបាកយល់ជាច្រើននៃនីតិវិធី ក្នុងការដាក់ពាក្យរហូតដល់ចេញសាលក្រមរបស់តុលាការដូច្នេះវាធ្វើឱ្យមានការវែកញែកជាច្រើន និងការមិនច្បាស់លាស់ណាមួយទើបពួកខ្ញុំទាំងពីរសរសេរចងក្រងឯកសារនេះឡើងដើម្បីបញ្ជាក់ជួយសម្រួលដល់ការប្រើប្រាស់ផ្សេងៗ និងដើម្បីឱ្យនិស្សិតច្បាប់ យល់ដឹងអំពីលំហូរនៃនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីឱ្យកាន់តែច្បាស់ ។

ជាចុងក្រោយក្នុងនាមយើងខ្ញុំទាំងពីរជាអ្នកសិក្សាស្រាវជ្រាវ និងចងក្រងឯកសារនេះរមែងតែងតែជៀសមិនផុតពីកំហុសឆ្គងដោយអចេតនារួមមានទាំងការប្រើប្រាស់ពាក្យពេចន៍ អក្ខរាវិរុទ្ធ ខ្លឹមសារ ឬ អត្ថន័យនៅក្នុងអត្ថបទក្តី ដែលកើតមានឡើង។ អាស្រ័យហេតុនេះយើងខ្ញុំសូមធ្វើការសុំក្តីមេត្តាអធ្យាស្រ័យ និងជួយកែតម្រូវដើម្បីកិច្ចការស្រាវជ្រាវមួយនេះកាន់តែមានភាពល្អប្រសើរជាងមុន។ ខ្ញុំបាទទាំងពីររង់ចាំទទួលរាល់មតិរិះគន់ និងស្ថាបនាក្នុងបំណងកែលម្អអត្ថបទនេះកាន់តែល្អស៊ីជម្រៅ និងមានភាពច្បាស់លាស់ជាងមុន។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**បណ្តឹងរដ្ឋប្បវេណី**

**ផ្នែកទី១. ការចាត់ចែងរក្សាការពារនិងសញ្ញាណទូទៅនៃការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី** ...... ៣

**កថាភាគទី១. ការចាត់ចែងរក្សាការពារ** ........ ៣

១. អត្ថន័យ និងគោលបំណង ........ ៣

២. ប្រភេទនៃការចាត់ចែងរក្សាការពារ ........ ៤

**កថាភាគទី២. សញ្ញាណទូទៅនៃការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី** ........ ៥

១. ពាក្យបណ្តឹង ........ ៥

២. បណ្តឹង ........ ៥

**កថាភាគទី៣. ប្រភេទនៃបណ្តឹងរដ្ឋប្បវេណី** ........ ៦

១. បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ........ ៦

២. បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ........ ៧

៣. បណ្តឹងទាមទារឱ្យបញ្ជាក់ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និងទំនាក់ទំនងគតិយុត្ត ........ ៧

**ផ្នែកទី២. ភាគីបណ្តឹងរដ្ឋប្បវេណី** ........ ៨

**កថាភាគទី១. សមត្ថភាពភាគី** ........ ៨

១. ភាគីដែលមិនមានសមត្ថភាពក្នុងការធ្វើបណ្តឹង ........ ៩

២. ករណីកង្វះសមត្ថភាពក្នុងការធ្វើបណ្តឹង ........ ១០

**កថាភាគទី២. អ្នកតំណាងតាមផ្លូវបណ្តឹង**. ........ ១១

១. អ្នកតំណាងដែលច្បាប់បានកំណត់ ........ ១២

២. អ្នកតំណាងដោយអាណត្តិ ........ ១៣

**កថាភាគទី៣. នីតិវិធីនៃការដាក់ពាក្យបណ្តឹង** ........ ១៤

១. ទម្រង់ពាក្យបណ្តឹង ........ ១៤

១.១. ចំណុចត្រូវសរសេរក្នុងពាក្យបណ្តឹង ........ ១៥

១.១.១ អំពីភាគី........................................................................................................................ ១៥
១.១.២ កម្មវត្ថុ និងមូលហេតុនៃការទាមទារ .................................................................................... ១៦
១.២ ចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្ដឹង .................................................................................. ១៦
២. ការពិនិត្យលើពាក្យបណ្ដឹង និងការចាត់ចែងលើពាក្យបណ្ដឹងជាអាទិ៍ដែលពុំមានភាពត្រឹមត្រូវ..... ១៧
២.១ ការពិនិត្យលើពាក្យបណ្ដឹង .......................................................................................................... ១៧
២.១.១ លក្ខខណ្ឌទម្រង់.................................................................................................................. ១៧
២.១.២ ពន្ធដាក់ពាក្យសុំ.................................................................................................................. ១៨
២.២ ការចាត់ចែងលើពាក្យបណ្ដឹងជាអាទិ៍ដែលពុំមានភាពត្រឹមត្រូវ....................................................... ១៩
២.២.១ តុលាការការចេញដីកាសម្រេចបង្គាប់ឱ្យកែតម្រូវ ..................................................................... ១៩
២.២.២ តុលាការការចេញដីកាសម្រេចលើកចោលពាក្យបណ្ដឹង................................................................ ១៩

## ជំពូកទី២

## ដំណើរការនីតិវិធីនៃការជម្រះក្ដីលើកទី១

**ផ្នែកទី១. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**.................................................................... ២០
**កថាភាគទី១. សំណុំឯកសារត្រៀម**.................................................................................................. ២១
១. ឯកសារត្រៀម................................................................................................................................ ២១
២. ចំណុចដែលត្រូវសរសេរនៅក្នុងឯកសារត្រៀម ................................................................................ ២២
**កថាភាគទី២. ដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ..................................................... ២៣
១. សកម្មភាពរបស់តុលាការ ................................................................................................................ ២៣
២. សកម្មភាពរបស់ភាគី ....................................................................................................................... ២៤
**ផ្នែកទី២. ការទាញហេតុផលដោយផ្ទាល់មាត់**...................................................................................... ២៥
**កថាភាគទី១. មុនពេលនៃការទាញហេតុផលដោយផ្ទាល់មាត់** ................................................................ ២៥
១. កាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់.......................................................................... ២៦
២. ភស្តុតាងត្រៀម ............................................................................................................................... ២៦
**កថាភាគទី២. នៅក្នុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់**........................................................... ២៦
១. សេចក្ដីថ្លែងការណ៍របស់ភាគី................................................................................................................ ២៧
២. ការពិនិត្យភស្តុតាង ........................................................................................................................... ២៧
៣. ការវិនិច្ឆ័យរបស់ចៅក្រម ..................................................................................................................... ២៨

## ជំពូកទី៣
## ការបញ្ចប់បណ្ដឹង

**ផ្នែកទី១. ការបញ្ចប់បណ្ដឹងដោយសកម្មភាពភាគី** ........ ៣០

**កថាភាគទី១. ការបញ្ចប់បណ្ដឹងដោយភាគី** ........ ៣០

១. ការដកពាក្យបណ្ដឹង ........ ៣០

២ . ការសះជាតាមផ្លូវបណ្ដឹង ........ ៣១

៣. ការលះបង់ ឬ ការទទួលស្គាល់ការទាមទារ ........ ៣២

**កថាភាគទី២. ការបញ្ចប់បណ្ដឹងដោយស្វ័យប្រវត្តិ** ........ ៣២

១. មរណភាពរបស់ភាគី ........ ៣៣

២. ការរួមបញ្ចូលនូវឋានៈរបស់ភាគីទាំងសងខាង(ព្យាកុលភាព) ........ ៣៣

**ផ្នែកទី២. ការបញ្ចប់បណ្ដឹងដោយសកម្មភាពតុលាការ** ........ ៣៣

**កថាភាគទី១. ការចេញសាលក្រម** ........ ៣៣

១. ប្រភេទនៃសាលក្រម ........ ៣៤

២. ការប្រកាសសាលក្រមចុងក្រោយ ........ ៣៥

**កថាភាគទី២. ការអនុវត្តដោយបង្ខំ** ........ ៣៦

១. របៀបដាក់ពាក្យសុំអនុវត្តដោយបង្ខំ ........ ៣៧

២. លក្ខខណ្ឌចំពោះការអនុវត្តដោយបង្ខំ ........ ៣៧

៣. កិច្ចការនៅពេលដែលអនុវត្តដោយបង្ខំ ........ ៣៨

**ផ្នែកទី៣. នីតិវិធីនៃការអនុវត្តផ្សេងទៀត** ........ ៣៨

**កថាភាគទី១. នីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិច** ........ ៣៩

១. គោលគំនិត និងកម្មវត្ថុនៃនីតិវិធីបណ្ដឹងចំនួនទឹកប្រាក់តិច ........ ៣៩

២. ការដាក់ពាក្យបណ្ដឹង ........ ៣៩

៣. ភាពមិនចាំបាច់មាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ៤០

៤. គោលការណ៍នៃការជំនុំជម្រះតាមកាលបរិច្ឆេទតែមួយថ្ងៃ ........ ៤០

៥. បញ្ញត្តិពិសេសស្ដីពីសាលក្រម ........ ៤១

៦. បណ្ដឹងឧបាស្រ័យចំពោះសាលក្រម ........ ៤១

**កថាភាគទី២. នីតិវិធីជាស់តឿន(តុលាការ)** ...... ៤១
១. លក្ខខណ្ឌចំពោះនីតិវិធីនៃការជាស់តឿន ...... ៤១
២. អានុភាពនៃដីកាសម្រេចជាស់តឿន ...... ៤២
**សេចក្តីសន្និដ្ឋាន** ...... ៤៣
**អនុសាសន៍** ...... ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅក្នុងសង្គមយើងសព្វថ្ងៃនេះមនុស្សគ្រប់រូបរមែងជួបប្រទះការកើតមានឡើងនូវជម្លោះ ឬ វិវាទធំ តូច ដែលតែងកើតចេញពីការមិនយល់ចិត្តនឹងគ្នា ឬ ការមិនពេញចិត្តគ្នាលើរឿងអ្វីមួយជៀសមិនផុត និងពិបាកក្នុងការរកដំណោះស្រាយ។ នៅពេលដែលមានវិវាទណាមួយកើតមានឡើង ពួកគេគឺតែងតែស្វះស្វែងរកនូវវិធីសាស្ត្រសម្រាប់ដោះស្រាយវិវាទរបស់ខ្លួនឱ្យទាន់ពេលវេលា ហើយក្នុងការដោះស្រាយវិវាទនីមួយៗ គឺមានវិធីសាស្ត្រជាច្រើនខុសៗគ្នា ទៅតាមទំហំ និងប្រភេទនៃវិវាទ។ តែយ៉ាងណាមិញ សេចក្តីសុខកាយសប្បាយចិត្តនឹងមិនកើតមានឡើងឡើយ ប្រសិនបើការរស់នៅត្រូវទទួលរងនូវការបំពានសិទ្ធិ ឬ ការបំពានលើទ្រព្យសម្បត្តិរបស់ខ្លួនត្រូវបានបុគ្គលដទៃធ្វើឱ្យប៉ះពាល់ ឬ ខូចខាតនោះ។ ដោយសារតែមានការរំលោភបំពានបែបនេះហើយទើបប្រទេសបង្កើតច្បាប់ដើម្បី រារាំង និងទប់ស្កាត់អំពើបំពានទាំងនោះ។ ការបង្កើតឱ្យមានច្បាប់ដើម្បីគ្រប់គ្រងមិនគ្រប់គ្រាន់នោះឡើយទោះបីជាមានច្បាប់ គ្រប់គ្រងយ៉ាងណាក៏ដោយ ក៏ជម្លោះនៅតែកើតមានឡើងជៀសមិនផុត ដែលជាហេតុនាំឱ្យមានការកើតទុកមិនសុខចិត្តបែបនេះហើយ ទើបស្ថាប័នតុលាការមានតួនាទីសំខាន់ណាស់លើការដោះស្រាយ វិវាទរបស់បុគ្គលឯកជន គឺតុលាការរដ្ឋប្បវេណី ដែលមានសមត្ថកិច្ចដោះស្រាយវិវាទរដ្ឋប្បវេណី ។ អាស្រ័យហេតុនេះហើយទើបធ្វើឱ្យមានការឈានចូលដល់ការដាក់ពាក្យបណ្តឹង ដើម្បីរើកញែករកខុសត្រូវជូនជនដែលរងគ្រោះ ទើបធ្វើឱ្យបុគ្គលគ្រប់រូបមិនយល់ឬងើយឆ្ងល់អំពីថា តើនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីក្នុងសាលាដំបូងគេប្រព្រឹត្តិ ឬ អនុវត្តទៅយ៉ាងដូចម្តេចក្នុងមួយដំណាក់កាលៗ ?

ជាការពិតណាស់ការដោះស្រាយវិវាទរដ្ឋប្បវេណីគឺផ្តើមឡើងដោយមានការដាក់ពាក្យបណ្តឹងមកតុលាការរដ្ឋប្បវេណីដែលមានសមត្ថកិច្ច។ ហើយតុលាការដើម្បីអាចសម្រេចសេចក្តីត្រូវឆ្លងកាត់នីតិវិធីច្រើន គួរបញ្ជាក់ផងដែរថា នៅក្នុងរឿងក្តីរដ្ឋប្បវេណីមានលំហូរនីតិវិធីច្រើនដូចជានីតិវិធីបណ្តឹង នីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច នីតិវិធីដាស់តឿន នីតិវិធីអនុវត្តដោយបង្ខំ និងនីតិវិធីរក្សាការពារជាដើមដោយពេលនេះយើងនឹងធ្វើការបកស្រាយដោយផ្តោតសំខាន់ទៅលើលំហូរនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីនៅសាលាដំបូងរាជធានីភ្នំពេញតែប៉ុណ្ណោះ។

ម្យ៉ាងទៀតការស្រាវជ្រាវប្រធានបទមួយនេះទៀតសោត មានគោលបំណងជាឯកសារជំនួយស្មារតីដល់និស្សិតផ្នែកនីតិសាស្ត្រ និងគ្រប់មជ្ឈដ្ឋានទាំងអស់ក៏ដូចជាមិត្តនិស្សិតទូទៅដែលមានបំណងចង់យល់ដឹងអំពីនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីនៅសាលាដំបូងព្រោះថាគ្រប់បុគ្គលទាំងអស់ អាចមានវិវាទរដ្ឋប្បវេណីនៅតុលាការនៅថ្ងៃណាមួយ និងជាស្ពានក្នុងការដោះស្រាយការងើយឆ្ងល់រួមទាំងផ្តល់ចំណេះដឹងទាក់ទងនឹងការដាក់ពាក្យបណ្តឹងរឿងក្តីរដ្ឋប្បវេណីទៅកាន់តុលាការ អំពីដំណាក់កាលនីមួយៗ គេអនុវត្តទៅយ៉ាងដូចម្តេចនិងមានអ្វីខ្លះក៏ដូចជាការប្រកាសសាលក្រមស្ថាពររបស់តុលាការជាដើម។

ដោយមើលឃើញនូវចំណោទបញ្ហាទាំងអស់នេះ ទើបយើងខ្ញុំមានចំណាប់អារម្មណ៍ចំពោះ នីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីនៅសាលាដំបូងរាជធានីភ្នំពេញ។ ចំពោះប្រធានបទនេះគឺជាស្នាដៃមួយក្រោមកំណែទម្រង់បរិបទថ្មីក្នុងវិស័យយុត្តិធម៌ និងក្រោមការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានបង្កើតឱ្យមានបង្កើតក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ហើយប្រើប្រាស់រហូតដល់បច្ចុប្បន្ននេះឡើងមក។

អាស្រ័យហេតុនេះ ចំពោះដែនកំណត់នៃការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំនឹងសម្រេចយកត្រឹមតែចាប់ផ្តើមពីដំណាក់កាលនៃការដាក់ពាក្យបណ្តឹងរហូតដល់ពេលប្រកាសសាលក្រម ឬ ការបញ្ចប់បណ្តឹង បូករួមទាំងនីតិវិធីនៃការអនុវត្តផ្សេងទៀតខ្លះផងដែរ។

ដើម្បីជាភាពងាយស្រួលក្នុងការបកស្រាយពាក់ព័ន្ធនឹងប្រធានបទសារណានេះ យើងខ្ញុំបានបែងចែកជាបី (០៣) ជំពូកគឺ៖

- ជំពូកទី១. បណ្តឹងរដ្ឋប្បវេណី
  - ផ្នែកទី១. ការចាត់ចែងរក្សាការពារ និងសញ្ញាណទូទៅនៃការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី
  - ផ្នែកទី២. ភាគីបណ្តឹងរដ្ឋប្បវេណី
- ជំពូកទី២. ដំណើរការនីតិវិធីនៃការជម្រះក្តីលើកទី១
  - ផ្នែកទី១. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
  - ផ្នែកទី២. ការទាញហេតុផលដោយផ្ទាល់មាត់
- ជំពូកទី៣. ការបញ្ចប់បណ្តឹង
  - ផ្នែកទី១. ការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី
  - ផ្នែកទី២. ការបញ្ចប់បណ្តឹងដោយសកម្មភាពតុលាការ
  - ផ្នែកទី៣. នីតិវិធីនៃការអនុវត្តផ្សេងទៀត។

# ជំពូកទី១
# បណ្តឹងរដ្ឋប្បវេណី

# ជំពូកទី១
# បណ្តឹងរដ្ឋប្បវេណី

ការស្វែងយល់អំពីនីតិវិធីនៃបណ្តឹង គឺជារឿងដ៏សំខាន់មួយព្រោះនីតិវិធីនៃបណ្តឹង ត្រូវបានចាប់ផ្តើមអនុវត្ត នៅពេលដែលបានដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ចហើយពាក្យបណ្តឹងដែលចាត់ទុកថាបានដាក់ គឺជាពាក្យបណ្តឹងដែលក្រឡាបញ្ជីបានបោះត្រាចូលថាបានទទួល តាមទម្រង់បែបបទរដ្ឋបាលរបស់តុលាការនោះ។ ប៉ុន្តែពាក្យបណ្តឹងដែលអាចចាត់ទុកថាបានធ្វើឡើងត្រឹមត្រូវស្របតាមច្បាប់កំណត់ គឺជាបណ្តឹងដែលមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្តែង និងអាចដោះស្រាយបានដោយសាលក្រម។ ដោយឡែកបើយើងក្រឡេកមកមើល បណ្តឹងរដ្ឋប្បវេណី ត្រូវបានឱ្យនិយមន័យថា គឺជាបណ្តឹងមួយដែលច្បាប់ទទួលស្គាល់ និងអនុញ្ញាតសម្រាប់ជនគ្រប់រូបអាចជារូបវន្តបុគ្គល ឬ ជានីតិបុគ្គលក្នុងការពឹងពាក់ស្ថាប័នតុលាការចំពោះវិវាទរដ្ឋប្បវេណី ដើម្បីឱ្យតុលាការជួយដោះស្រាយបញ្ហាដែលកើតមានឡើងដោយផ្អែកលើអង្គហេតុ និងអង្គច្បាប់[1]។ ចំណុចដែលគួរស្វែងយល់មុននឹងឈានទៅដល់ការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីដែលមាន២ផ្នែកសំខាន់ៗ ការចាត់ចែងរក្សាការពារ និងសញ្ញាណទូទៅនៃការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី(ផ្នែកទី១) និងភាគីបណ្តឹងរដ្ឋប្បវេណី (ផ្នែកទី២)។

## ផ្នែកទី១. ការចាត់ចែងរក្សាការពារ និងសញ្ញាណទូទៅនៃការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី

### កថាភាគទី១. ការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីមួយដែលតុលាការសម្រេចរក្សាការពារកម្មវត្ថុនៃវិវាទដែលមានការស្នើសុំពីភាគីដើម្បីឱ្យមានការចាត់ចែងរក្សាការពារនេះឡើងក្នុងគោលដៅការពារកម្មវត្ថុនោះកុំឱ្យមានការប្រែប្រួលបច្ចុប្បន្នភាពរបស់វាដែលជាហេតុនាំឱ្យមានការប៉ះពាល់ដល់ដំណើរការរឿងក្តីដែរ។ ដោយនៅត្រង់ចំណុចនេះ យើងនឹងសិក្សាស្វែងយល់ពីបន្ថែមនូវអត្ថន័យ និងគោលបំណងនៃការចាត់ចែងរក្សាការពារនេះ (១) និង ប្រភេទនៃការចាត់ចែងរក្សាការពារ (២)។

#### ១. អត្ថន័យ និងគោលបំណង

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងការពារ និងថែរក្សាស្ថានភាពបច្ចុប្បន្នដោយប្រើអំណាចរបស់រដ្ឋ ដើម្បីការពារសិទ្ធិរបស់បុគ្គលណាម្នាក់នៅពេលដែលមានការបារម្ភថាការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬ នៅពេលដែលមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ។ ហើយមួយវិញទៀតអាចនិយាយបានថា ការចាត់ចែងរក្សាការពារវាជានីតិវិធីមួយដែលមានលក្ខណៈបណ្តោះអាសន្នដើម្បីការពារសិទ្ធិ

[1] មាត្រា២ (គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី សិទ្ធិពឹងពាក់តុលាការ) កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី។

និងផលប្រយោជន៍របស់ម្ចាស់បំណុលនៅពេលពេលដែលមានការបារម្ភថាការអនុវត្តដោយបង្ខំ ឬ ការសម្រេចសិទ្ធិរបស់ម្ចាស់បំណុលមិនអាចធ្វើបាន ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុល ឬ ប្រសិនបើមានការបារម្ភថានឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ។

## ២. ប្រភេទនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពាក៏ត្រូវបានគេធ្វើការបែងចែកតាមប្រភេទដែរ ព្រោះថាប្រភេទនៃការចាត់ចែងរក្សាការពារនីមួយៗ មានគោលដៅអនុវត្តផ្សេងគ្នាតាមកម្មវត្ថុនៃការទាមទារនៃករណីនីមួយៗ ដែលភាគីបានស្នើសុំមកកាន់តុលាការដើម្បីឱ្យមានការចាត់ចែងរក្សាការពារនេះឡើងក្នុងគោលបំណងការពារផលប្រយោជន៍ និងស្វែករកយុត្តធម៌ជូនបុគ្គលដែលមានសិទ្ធិត្រឹមត្រូវស្របច្បាប់។ ការចាត់ចែងរក្សាការពាត្រូវបានច្បាប់ធ្វើការបែងចែកជា២ប្រភេទ មានដូចខាងក្រោម៖

- **ការរឹបអូសជាបណ្តោះអាសន្ន៖** សិទ្ធិដែលត្រូវបានរក្សាការពារ គឺជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។ គោលបំណងចម្បងគឺដើម្បីមិនឱ្យកូនបំណុលចាត់ចែងទ្រព្យសម្បត្តិហើយការធានា នូវទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលសម្រាប់ការអនុវត្តដោយបង្ខំនៅពេលអនាគត[2]។ មានន័យថាជាការរឹបអូសសិទ្ធិរបស់បុគ្គលដែលមិនព្រមអនុវត្តកាតព្វកិច្ច ក្នុងនាមជាកូនបំណុលដោយសងជាប្រាក់ទៅឱ្យម្ចាស់បំណុលហើយត្រូវបានតុលាការចេញសាលក្រម បញ្ឈប់សិទ្ធិបណ្តោះអាសន្នលើការចាត់ចែងប្រាក់ ដែលកូនបំណុលនោះមាន។
- **ការចាត់ចែងជាបណ្តោះអាសន្នដោយការចាត់ចែងប្រភេទនេះមានការចែកចេញជា២របៀប៖**
    - → ការចាត់ចែងបណ្តោះអាសន្នកម្មវត្ថុនៃវិវាទ៖ការចាត់ចែងប្រភេទនេះគឺជាការចាត់ចែងកម្មវត្ថុនៃការទាមទាររបស់ភាគីស្នើសុំដែលភាគីនោះបារម្ភថាបើកម្មវត្ថុនោះខូចខាត ឬ ប្រែប្រួលបច្ចុប្បន្នភាពរបស់វានាំឱ្យភាគីស្នើសុំ ឬ ម្ចាស់បំណុលមិនអាច ឬ លំបាកខ្លាំងក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន នៅពេលដែលតវ៉ាក្តីចប់ និងដើម្បីជៀសវាងនូវភាពស្មុគស្មាញក្នុងការអនុវត្តទាមទារកម្មវត្ថុនៃវិវាទ[3]។
    - → ការចាត់ចែងបណ្តោះអាសន្នលើការកំណត់ឋានៈជាបណ្តោះអាសន្ន៖ ការចាត់ចែងប្រភេទនេះគឺជាការចាត់ចែងឋានៈរបស់បុគ្គលជាបណ្តោះអាសន្នសិនដោយហេតុថាមានការបង្កគ្រោះថ្នាក់ ឬលំបាក និងទប់ស្កាត់បញ្ហាផ្សេងទៀត ដែលបណ្តាលមកពីភាពយឺតយ៉ាវ នៃការកំណត់ ឋានៈរបស់បុគ្គលនោះ[4]។

[2] មាត្រា៥៣១ ចំណុច ក. ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[3] មាត្រា៥៣១ ចំណុច ខ. ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[4] មាត្រា៥៣១ ចំណុច ខ. ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

មូលហេតុចម្បងនៃការពិចារណានៅលើការរក្សាការពារនេះ ក៏ព្រោះជាទូទៅមិនគ្រប់ករណីសុទ្ធសឹងតែត្រូវចាំបាច់ដាក់រក្សាការពារនោះទេ។ អ្វីដែលយើងត្រូវពិចារណានោះគឺថាតើយើងមានលក្ខខណ្ឌដើម្បីតតាំងហើយឬនៅ ព្រោះថាបើគេមានប្រាតិភោគរួចរាល់នោះគេមិនចាំបាច់ត្រូវដាក់រក្សាការពារនោះឡើយ ក៏ប៉ុន្តែដែលយើងលើកមកគិតនៅត្រង់ចំណុចនេះគឺជាប្រភេទម្ចាស់បំណុលធម្មតា។ ចំពោះម្ចាស់បំណុលធម្មតាដើម្បីឱ្យមានភាពប្រាកដប្រជាថា កម្មវត្ថុដែលត្រូវរឹបអូសដោយការអនុវត្តបង្ខំមិនត្រូវបានបាត់បង់ ឬ ខូចតម្លៃដោយប្រការណាមួយនោះយើងចាំបាច់ត្រូវតែដាក់រក្សាការពារ។

ចំពោះរក្សាការពារនេះមិនមែនជាប្រធានបទគោលដែលយើងត្រូវយកមកបកស្រាយនោះឡើយ ក៏ប៉ុន្តែយើងខ្ញុំគ្រាន់តែចង់ឱ្យពិចារណាត្រង់នេះព្រោះវាក៏ជាចំណុចសំខាន់មួយផងដែរ ដើម្បីជៀសវាងនៅពេលដែលយើងធ្វើបណ្តឹងចប់សព្វគ្រប់ពុំមានអ្វីយកមកអនុវត្ត គឺមានន័យថាយើងធ្វើបណ្តឹងឈ្នះតែក្រដាសមិនទទួលបានផលប្រយោជន៍អ្វីមកវិញឡើយ។ ចូលមកចំណុចសំខាន់ដែលយើងត្រូវបកស្រាយបន្តនោះគឺសញ្ញាណទូទៅនៃការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី។

## កថាភាគទី២. សញ្ញាណទូទៅនៃការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី

### ១. ពាក្យបណ្តឹង

ការរៀបចំពាក្យបណ្តឹង គឺជាដំណាក់កាលសំខាន់សម្រាប់ភាគីដើមចោទពីព្រោះពាក្យបណ្តឹងគឺជាឯកសារផ្ទុកនូវការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទ។ ម្យ៉ាងវិញទៀតនៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ (ក្រឡាបញ្ជីដែលទទួលបន្ទុកក្នុងការទទួលពាក្យបណ្តឹងត្រូវបោះត្រាដែលបញ្ជាក់អំពី ថ្ងៃ-ខែ-ឆ្នាំ ដែលបានទទួលពាក្យបណ្តឹងក្នុងគោលបំណងបញ្ជាក់អំពីថ្ងៃដាក់ពាក្យបណ្តឹង) អានុភាពនៃបណ្តឹងមានចំពោះដើមចោទ និងតុលាការតែប៉ុណ្ណោះ រហូតដល់ពេលពាក្យបណ្តឹងនោះត្រូវបានបញ្ជូនទៅឱ្យចុងចម្លើយ (ទំនាក់ទំនងគតិយុត្តកើតឡើងចំពោះដើមចោទ ចុងចម្លើយ និងតុលាការ) ហេតុនេះ ក្នុងករណីពាក្យបណ្តឹងមិនត្រឹមត្រូវតាមលក្ខខណ្ឌនៃទម្រង់តុលាការនឹងមិនចាត់ការបណ្តឹងនោះទេ (តុលាការពុំបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ) ។

### ២. បណ្តឹង

បណ្តឹង គឺជាការសុំទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់មួយ ដោយផ្អែកលើការទាមទារតាមផ្លូវបណ្តឹង ដែលការទាមទារតាមផ្លូវបណ្តឹង (ការទាមទារ) គឺជាការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់ នីតិឯកជនដែលបានកំណត់មួយរបស់ដើមចោទចំពោះចុងចម្លើយ។ ការទាមទារតាមផ្លូវបណ្តឹង ជាកម្មវត្ថុនៃការវិនិច្ឆ័យ និងសម្រេចសេចក្តីនៃបណ្តឹង ហៅថាកម្មវត្ថុនៃបណ្តឹងត្រូវបានកំណត់តាមរយៈពាក្យបណ្តឹងនៅក្នុងចំណុចស្តីពីខ្លឹមសារនៃសាលក្រមដែលដើមចោទ ទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារដែលមានបញ្ញត្តិក្នុងមាត្រា៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋ

ប្បវេណី។ ចំណែកឯការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាខ្លឹមសារនៃការទាមទារតាមផ្លូវបណ្តឹង ជាសិទ្ធិដែលត្រូវបានបញ្ញត្តិនៅក្នុងច្បាប់សារធាតុ ដូចជាសិទ្ធិទាមទារឱ្យសងប្រាក់កម្ចីផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ សិទ្ធិទាមទារថ្លៃលក់ផ្អែកលើកិច្ចសន្យាលក់ទិញ សិទ្ធិទាមទារឱ្យប្រគល់វត្ថុផ្អែកលើកម្មសិទ្ធិសិទ្ធិទាមទារឱ្យលុបការចុះបញ្ជី ផ្អែកលើកាតព្វកិច្ចបដិទានសិទ្ធិទាមទារសំណងការខូចខាតផ្អែកលើអំពើអនីត្យានុកូលជាអាទិ៍។

### កថាភាគទី៣. ប្រភេទនៃបណ្តឹងរដ្ឋប្បវេណី

ប្រភេទបណ្តឹងអាចបែងចែកជាច្រើនប្រភេទ ទៅតាមបទដ្ឋាននីមួយៗ ដោយផ្អែកតាមស្ថានភាពនៃអង្គហេតុដែលបានកើតឡើងដូច្នេះថាតើគេអាចធ្វើការបែងចែកប្រភេទនៃបណ្តឹងរដ្ឋប្បវេណីតាមរបៀបយ៉ាងដូចម្តេច? ប្រភេទបណ្តឹងរដ្ឋប្បវេណី ត្រូវបានគេបែងចែកដោយផ្អែកតាមប្រភេទ និងបែបយ៉ាងនៃកម្មវត្ថុលើការទាមទារតាមផ្លូវបណ្តឹងមកធ្វើជាបទដ្ឋានក្នុងការបែងចែកប្រភេទនៃបណ្តឹងរដ្ឋប្បវេណីរួមមានបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក(១) បណ្តឹងទាមទារឱ្យ បង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត(២) បណ្តឹងទាមទារឱ្យបញ្ជាក់ (៣)[5]។

### ១. បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក

បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក គឺជាបណ្តឹងមួយដែលបានគេឱ្យនិយមន័យថា ជាបណ្តឹងដែលធ្វើការទាមទារ ឱ្យតុលាការចេញសាលក្រមតាមការទាមទាររបស់ខ្លួន ដោយបង្គាប់ឱ្យចុងចម្លើយផ្តល់តាវកាលិកស្របតាមការទាមទារដោយផ្អែកលើអត្ថិភាពនៃសិទ្ធិ ដែលខ្លួនមានក្នុងការទាមទារស្របតាមច្បាប់សារធាតុដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី[6]។ នេះបើយោងតាមសន្ទានុក្រម ផ្នែករដ្ឋប្បវេណី តាវការលិក គឺជាវត្ថុ ឬ សកម្មភាពដែលជាទីតាំង (ឬជាកម្មវត្ថុ) នៃកាតព្វកិច្ច។ ដូច្នេះយើងអាចធ្វើការសន្និដ្ឋានបានថា បណ្តឹងដែលធ្វើការទាមទារឱ្យផ្តល់តាវកាលិក គឺជាប្រភេទបណ្តឹងដែលទាមទារទៅលើ៖

- សកម្មភាពនៃការទាមទារឱ្យបង់ជាប្រាក់
- សកម្មភាពនៃការទាមទារឱ្យធ្វើតាមឆន្ទៈ ឬមិនឱ្យធ្វើសកម្មភាពណាមួយ
- ការទាមទារឱ្យប្រគល់អចលនទ្រព្យដូចជាផ្ទះសម្បែង ដីធ្លី សំណង់អគារផ្សេងៗ
- ការទាមទារឱ្យប្រគល់ចលនវត្ថុដូចជារថយន្ត សម្ភារៈផ្សេងៗជាដើម។

ឧទាហរណ៍ ៖ លោក ក ជាម្ចាស់បំណុល និង លោក ខ ជាកូនបំណុល បានបង្កើតកិច្ចសន្យាខ្ចីប្រាក់ជាមួយគ្នា ហើយនៅពេលកាលកំណត់នៃថ្ងៃសងប្រាក់បានមកដល់ប៉ុន្តែ លោក ខ មិនព្រមសងប្រាក់នោះមកឱ្យ លោក ក វិញឡើយ។ ដូចនេះ លោក ក ក៏បានដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីទាមទារប្រាក់កម្ចីពី លោក ខ ត្រឡប់

[5] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកការរៀបចំសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី សេចក្តីពន្យល់ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីចេញសាលក្រម ផ្នែកទី៣ ប្រភេទនៃបណ្តឹង ទំព័រ៤៥។

[6] សេចក្តីពន្យល់ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីចេញសាលក្រម កថាខណ្ឌទី១ បណ្តឹងទាមទារឱ្យផ្តល់ តាវកាលិក ទំព័រ៤៥។

មកវិញដោយក្នុងពាក្យបណ្តឹង លោក ក បានសរសេរទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យ លោក ខ ដែលជាកូនបំណុលបង់ប្រាក់ដើម និងការប្រាក់ដែលច្បាប់បានកំណត់មកឱ្យខ្លួន។ ក្នុងករណីដែល លោក ក បានដាក់ពាក្យបណ្តឹងទៅតុលាការទាមទារឱ្យ លោក ខ បង់ប្រាក់ដើម និងការប្រាក់ដែលច្បាប់បានកំណត់នេះគឺជាបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក។

## ២. បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត

បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងដែលដើមចោទអះអាងអំពីអត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តកំណត់មួយដែលជាការទាមទារតាមផ្លូវបណ្តឹងហើយទាមទារឱ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មី ប្តូរ ឬរំលត់នូវទំនាក់ទងគតិយុត្ត ដោយផ្អែកលើសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនោះ[7]។ ហើយបណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ជាប្រភេទបណ្តឹងដែលកើតមានជា ច្រើនករណីក្នុងសង្គមរបស់យើងសព្វថ្ងៃ និងបានក្លាយជារឿងធម្មតាបាត់ទៅហើយដូចជា៖ បណ្តឹងលែងលះ ដែលជាបណ្តឹងទាមទារឱ្យរំលត់នូវទំនាក់ទំនងរវាង សហព័ទ្ធ ហើយក៏ជាបណ្តឹងទាមទារឱ្យបង្កើតនូវទំនាក់ទំនងគតិយុត្តផងដែរពោលគឺសម្តៅទៅលើការបែងចែក ទ្រព្យសម្បត្តិ និង ការកំណត់អំណាចមេបាលើកូនប្រសិនបើមាន។ បណ្តឹងសុំរំលាយកិច្ចសន្យា គឺជាបណ្តឹង ទាមទារឱ្យរំលត់នូវទំនាក់ទំនងគតិយុត្ត ឬ កាតព្វកិច្ចរបស់គូភាគីនៃកិច្ចសន្យា។ បណ្តឹងសុំឱ្យរំលាយកិច្ចសន្យា ដែលមានវិការៈ និង សុំឱ្យទទួលស្គាល់កិច្ចសន្យាដែលគ្មានវិការៈវិញ គឺជាបណ្តឹងទាមទារឱ្យប្តូរនូវទំនាក់ទំនង គតិយុត្ត។ ឧទាហរណ៍ៈ ដើមចោទ បានទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយ ឈ្មោះ ខ ផ្ទេរកម្មសិទ្ធិត្រឡប់លើដី (x) មកឱ្យដើមចោទ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ xxxx ចុះថ្ងៃxx ខែxx ឆ្នាំxxxx ។

## ៣. បណ្តឹងទាមទារឱ្យបញ្ជាក់ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និងទំនាក់ទំនងគតិយុត្ត

បណ្តឹងទាមទារឱ្យបញ្ជាក់ គឺជាបណ្តឹងមួយប្រភេទដែលដើមចោទអះអាងនូវអត្ថិភាព ឬ នត្ថិភាព ឬ ទំនាក់ទំនងគតិយុត្តកំណត់មួយ ហើយទាមទារឱ្យតុលាការចេញសាលក្រមបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាព ឬ ទំនាក់ទំនងគតិយុត្តនោះ។ បណ្តឹងទាមទារឱ្យបញ្ជាក់នេះការសរសេរខ្លឹមសារនៃពាក្យបណ្តឹងដែលដើមចោទទាមទារឱ្យតុលាការចេញសាលក្រមនៅក្នុងបណ្តឹង(ក) និង(ខ)ខាងលើការសរសេរខ្លឹមសារនៃបណ្តឹងនេះ(បណ្តឹងទាមទារឱ្យបញ្ជាក់) ដើមចោទគ្រាន់តែបង្ហាញនូវអង្គហេតុដែលចាំបាច់ដើម្បីបញ្ជាក់នូវការទាមទាររួចជាការស្រេច។ ឧទាហរណ៍ៈ ដើមចោទបានទាមទារឱ្យតុលាការចេញសាលក្រម បញ្ជាក់ថាដើមចោទជាកម្មសិទ្ធិនៅលើផ្ទះ(x) ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ xxxx ចុះថ្ងៃxx ខែxx ឆ្នាំxxxx។

---

[7] សេចក្តីពន្យល់ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីចេញសាលក្រម កថាខណ្ឌទី ៣ បណ្តឹងទាមទារ ឱ្យបង្កើត ប្តូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត ទំព័រ៥០។

សរុបសេចក្តីមក នៅក្នុងការសរសេរពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញចាំបាច់ត្រូវបញ្ជាក់ពីខ្លឹមសារដែលខ្លួនទាមទារឱ្យបានច្បាស់លាស់ ព្រោះងាយស្រួលដល់ចៅក្រមចេញសាលក្រមតាមចំណុចដែលខ្លួនទាមទារឲ្យតុលាការចេញសាលក្រម ។

**ផ្នែកទី២. ភាគីបណ្តឹងរដ្ឋប្បវេណី**

ភាគីបណ្តឹងនៅក្នុងរឿងក្តីរដ្ឋប្បវេណីមាន២គឺ ភាគីខាងដើមចោទ (ដើមបណ្តឹងរដ្ឋប្បវេណី) និង ភាគីខាងចុងចម្លើយ ដែលភាគីខាងដើមចោទ គឺជាភាគីដែលស្នើសុំឱ្យតុលាការធ្វើការចេញសាលក្រមដែលមានអត្ថន័យស្របតាមការទាមទារ និងការចង់បានរបស់ខ្លួនទៅលើភាគីចុងចម្លើយ ដោយអះអាងពីអត្ថិភាពនៃសិទ្ធិ ស្របច្បាប់របស់ខ្លួន រីឯភាគីខាងចុងចម្លើយវិញជាភាគីដែលមានសិទ្ធិអះអាង ឬ តវ៉ាលើការទាមទាររបស់ភាគី ខាងដើមចោទដោយផ្អែកលើអង្គហេតុនិងភស្តុតាងស្របច្បាប់របស់ខ្លួនដូចគ្នា។ ដោយភាគីទាំង២គឺជាសមាសភាពដែលនាំឱ្យមានវិវាទតាមផ្លូវច្បាប់កើតមានឡើង ពោលគឺមកពីមូលហេតុនៃភាគីណាម្ខាងមិនបានធ្វើ ការអនុវត្តកាតព្វកិច្ចបានត្រឹមត្រូវ ដែលជាមូលហេតុនាំឱ្យមានការឈ្លោះទាស់ទែងគ្នា រហូតឈានដល់ដំណាក់ កាលនៃការប្តឹងផ្តល់ទៅតុលាការ ដើម្បីទទួលបានការកាត់ក្តីយុត្តធម៌មួយ ចំពោះវិវាទដែលកើតមានឡើង។

ប៉ុន្តែមានករណីមួយចំនួនដែលរូបវន្តបុគ្គល ឬបុគ្គលឯកជន នឹងមិនអាចក្លាយជាភាគីបណ្តឹងនៅក្នុងរឿងក្តីរដ្ឋប្បវេណីបាន ទោះបីជាភាគីបុគ្គលនោះត្រូវបានទទួលការខូចប្រយោជន៍ដោយសារបុគ្គលម្ខាងទៀតក្តី ក៏បុគ្គលដែលខូច ឬខាតបង់ប្រយោជន៍នោះមិនអាចក្លាយជាភាគីបណ្តឹង ឬដាក់ពាក្យបណ្តឹងទៅកាន់តុលាការបានឡើយ ផ្ទុយទៅវិញបើបុគ្គលនោះធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងផ្ទាល់ នោះតុលាការនឹងធ្វើការច្រានចោលបណ្តឹងនោះភ្លាម។ ដូច្នេះដើម្បីទទួលបានចំណេះដឹងបន្ថែមអំពីថាតើប្រភេទបុគ្គលណាខ្លះដែលគ្រប់លក្ខណៈសម្បត្តិក្នុងការធ្វើបណ្តឹងយើងគួរស្វែងយល់ពី សមត្ថភាពភាគី(កថាភាគទី១) និងអ្នកតំណាងតាមផ្លូវបណ្តឹង (កថាភាគទី២)។

**កថាភាគទី១. សមត្ថភាពភាគី**

សមត្ថភាពភាគី គឺជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើការយល់ដឹង ព្រោះថាបើយើងយល់ច្បាស់ពីលក្ខណៈសម្បត្តិគ្រប់គ្រាន់ទូទៅរបស់បុគ្គលនោះមានន័យថា យើងនឹងមានភាពងាយស្រួលក្នុងការកំណត់ពីបុគ្គលដែលអាចធ្វើបណ្តឹងបាន ឬ មិនអាចក្លាយជាភាគីក្នុងបណ្តឹងបាន។ ដោយឡែកក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជាយើងបានកំណត់ថា រូបវន្តបុគ្គល និងនីតិបុគ្គល ក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច ដែលមានន័យថា រូបវន្តបុគ្គល និងនីតិបុគ្គលគឺជាភាគីដែលមានសមត្ថភាព និងសូម្បីតែទារកក្នុងគភ៌ ក៏អាចក្លាយជាភាគីដែលមាន សមត្ថភាពនៅក្នុងរឿងក្តីបណ្តឹងរដ្ឋប្បវេណីបានដែរ[៦]។ ប៉ុន្តែនៅក្នុងករណីនេះ មិនមែនគ្រប់រូបវន្តបុគ្គល និងនីតិបុគ្គល ដែល

[៦]មាត្រា៦ (គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ) និងមាត្រា៩ (ទារកនៅក្នុងគភ៌)ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ជាភាគីមានសមត្ថភាពសុទ្ធតែអាចមានសមត្ថភាពក្នុងការធ្វើបណ្តឹងរដ្ឋប្បវេណីបានទាំងអស់នោះឡើយនៅត្រង់ចំណុចនេះ យើងត្រូវបែងចែកឱ្យបានច្បាស់លាស់ពីពាក្យថា ភាគីមានសមត្ថភាព និងភាគីមានសមត្ថភាពក្នុងការធ្វើបណ្តឹង ឧទាហរណ៍ ទារកក្នុងគភ៌ អាចក្លាយជាភាគី ដែលមានសមត្ថភាពបាន ប៉ុន្តែទារក ក្នុងគភ៌ មិនអាចក្លាយជាភាគី ដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងបានទេ។

ច្បាប់បានអនុញ្ញាតឱ្យបុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគិតពិចារណា និងវិនិច្ឆ័យបានត្រឹមត្រូវប៉ុណ្ណោះ ទើបអាចធ្វើបណ្តឹងបាន និងមិនអនុញ្ញាតឡើយចំពោះបុគ្គលដែលមិនទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការគិតពិចារណា ដែលមានគោលបំណង គឺដើម្បីការពារផលប្រយោជន៍របស់ជន ដែលមិនទាន់មានការពិចារណាគ្រប់ជ្រុងជ្រោយនោះកុំឱ្យជនឆ្លៀតឱកាសមួយចំនួនមករំលោភបំពានលើផលប្រយោជន៍របស់ពួកគេបាន។

ដូច្នេះហើយទើបមានចំណុចមួយចំនួន ដែលនឹងត្រូវសិក្សាស្វែងយល់លើបញ្ហាទាំងអស់នេះ ដែលមានដូចជាភាគីមិនមានសមត្ថភាពក្នុងការធ្វើបណ្តឹង(១) និងករណីកង្វះសមត្ថភាពក្នុងការធ្វើបណ្តឹង (២)។

### ១. ភាគីដែលមិនមានសមត្ថភាពក្នុងការធ្វើបណ្តឹង

ភាគីដែលមិនមានសមត្ថភាពក្នុងការធ្វើបណ្តឹងបាន គឺត្រូវបានកំណត់ដោយច្បាប់បើក្នុងករណីតុលាការរកឃើញថាភាគីណាម្ខាង ឬ ទាំងសងខាងខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹងនោះតុលាការនឹងចេញសាលក្រមអំពីការលើកបណ្តឹងនោះចោលភ្លាម ដោយមូលហេតុថាផ្ទុយនឹងច្បាប់ និងមានមោឃភាពចាប់តាំងពី ថ្ងៃដាក់ពាក្យបណ្តឹងដំបូងមកម្ល៉េះ។ ដូច្នេះហើយ ដើម្បីជៀសវាងកំហុសដោយអចេតនាទាំងអស់នេះយើងត្រូវសិក្សាថាតើជនណាខ្លះដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើបណ្តឹងដែលរួមមានដូចខាងក្រោម៖

- **អនីតិជន៖** នេះបើយោងតាមសន្ទានុក្រមផ្នែករដ្ឋប្បវេណីបានឱ្យនិយមន័យលើពាក្យអនីតិជនថាជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬ ជនដែលមានអាយុក្រោម១៨ឆ្នាំ[៩]។ មានន័យថាបុគ្គលដែលមានអាយុជាមធ្យមក្រោម១៨ឆ្នាំ គឺជាបុគ្គលដែលច្បាប់មិនអនុញ្ញាតឱ្យមានសមត្ថភាពក្នុងការធ្វើបណ្តឹងបាននោះទេក្រោមហេតុផលថា ជនដែលស្ថិតក្រោម១៨ឆ្នាំនេះ គឺមិនអាចមានគំនិតពិចារណាគ្រប់គ្រាន់ក្នុងការការពារផលប្រយោជន៍របស់ខ្លួនបានឡើយដោយងាយនឹងចាញ់បោកជនឆក់ឱកាស។
- **ជនដែលស្ថិតក្រោមអាណាព្យាបាល៖** គឺជាជនដែលស្ថិតក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយជាទូទៅ ឬស្ថិតក្រោមការមើលថែរបស់សាច់ញាតិនៃជននោះ ដោយជនរូបនេះមានលក្ខណៈស្រដៀងទៅនឹងអនីតិជនដែរ ប៉ុន្តែខុសត្រង់អនីតិជនមួយចំនួន គឺមិនបានស្ថិតក្រោមអាណាព្យាបាលទេ ហើយច្បាប់ក៏មិនបានឱ្យជាមាត្រា ឬ និយមន័យពាក់ព័ន្ធនឹងជនដែលស្ថិតក្រោមអាណាព្យាបាលនេះដែរ ពោលគឺ មនុស្ស

[៩] មាត្រា១៧ (អត្ថន័យនៃអនីតិជន) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ទូទៅយល់ឃើញថា វាមិនមានភាព ឬ លក្ខណៈចាំបាច់ ដោយផ្អែកលើមូលហេតុជនប្រភេទនេះមានលក្ខណៈដូច ឬស្រដៀងទៅនឹងអនីតិជនដែរ។

- **ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ៖** គឺជាជនដែលមានបញ្ញាបញ្ញា និងស្មារតីដែលជាទូទៅបុគ្គលប្រភេទនេះត្រូវបានគេសន្មតថាមិនអាចធ្វើការព្យាបាល ឬជាសះស្បើយជារៀងរហូត ដែលជននោះផ្ទាល់ត្រូវមានការសម្រេចចេញសាលក្រមពីតុលាការ ពីការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅនៅពេលវ័យនៃអាយុ១៥ឆ្នាំមកដល់ តាមពាក្យស្នើសុំរបស់ជននោះ[10]។ ដោយផ្អែកលើបញ្ញាបញ្ញា និងស្មារតីជានិរន្តរ៍របស់ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅនេះ ច្បាប់មិនអាចអនុញ្ញាតឱ្យជននោះធ្វើបណ្តឹងដោយខ្លួនឯងបានឡើយ ជៀសវាងនាំឱ្យមានការខូចផលប្រយោជន៍របស់ជននោះបាន។
- **ជនដែលស្ថិតក្រោមហិតូបត្ថម្ភ៖** ជនដែលត្រូវបានកម្រិតសមត្ថភាពមួយនេះវិញ គឺជាបុគ្គលដែលមានសមត្ថភាពតិចតួចក្នុងការយល់ដឹងពីច្បាប់ ដោយសារមានបញ្ញាបញ្ញា និងស្មារតីមិនគ្រប់គ្រាន់ដើម្បីវិនិច្ឆ័យពីអំពើដែលបង្កឡើងដោយសកម្មភាពរបស់ខ្លួន[11]។ ដោយជនរូបនេះខុសពីជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅត្រង់ថា ជនដែលស្ថិតក្រោមហិតូបត្ថម្ភ មានបញ្ញាស្មារតី គ្រាន់បើជាងជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ដែលផ្នែកបញ្ញា និងស្មារតីអាចមិនជាសះស្បើយជារៀងរហូត ទោះបីជាយ៉ាងណា ច្បាប់ក៏នៅតែមិនអាចអនុញ្ញាតឱ្យជននោះធ្វើបណ្តឹងដោយខ្លួនឯងបានឡើយជៀសវាងនាំឱ្យខូចប្រយោជន៍ដល់ជននោះបាន។

សរុបជារួមមក ជនដូចដែលបានរៀបរាប់ខាងលើ ដែលមានដូចជាអនីតិជន ជនដែលស្ថិតនៅក្រោមអាណាព្យាបាល ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ជនដែលស្ថិតក្រោមហិតូបត្ថម្ភ គឺសុទ្ធសឹងតែមិនមានសមត្ថភាពក្នុងការធ្វើបណ្តឹងរដ្ឋប្បវេណីបានដោយឯកឯងនោះទេ ពោលគឺច្បាប់មានចេតនាក្នុងការការពារផលប្រយោជន៍របស់ជនទាំងអស់នោះ រហូតដល់ពេលពួកគេមានសមត្ថភាពក្នុងការធ្វើបណ្តឹងឡើងវិញ ឬចាំរហូតដល់ពួកគេមានជំនួយពីតតិយជនដែលច្បាប់បានអនុញ្ញាត ទើបដំណើរការនៃការធ្វើបណ្តឹងមានលក្ខណៈត្រឹមត្រូវ និងស្របតាមច្បាប់។

## ២. ករណីកង្វះសមត្ថភាពក្នុងការធ្វើបណ្តឹង

ក្នុងករណីដែលបុគ្គលត្រូវបានគេកម្រិតសមត្ថភាពខាងលើនោះ បានជួបប្រទះបញ្ហាដែលនាំឱ្យពួកគេ ខូចផលប្រយោជន៍ភ្លាមៗ តើច្បាប់នឹងចូលខ្លួនដើរតួការពារពួកគេ ពីការខូចប្រយោជន៍ទាំងអស់នោះយ៉ាងដូចម្តេចទៅវិញ?អ្នកបង្កើតច្បាប់បានបង្កើតច្បាប់ឡើងដោយមិនមានលក្ខណៈតឹងតែងរហូតដល់ថ្នាក់គ្មានផ្លូវទុកសម្រាប់ដោះស្រាយសោះនោះទេ ពោលគឺច្បាប់តែងទុកចន្លោះមួយសម្រាប់បុគ្គលដែលអនុវត្តច្បាប់នោះឱ្យមាន ឱកាស

[10] មាត្រា២៥ (អត្ថន័យនៃជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[11] មាត្រា២៩ (អត្ថន័យនៃជនស្ថិតនៅក្រោមហិតូបត្ថម្ភ) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ក្នុងការជួយទៅដល់ជនរងគ្រោះ ដែលត្រូវការជំនួយបន្ទាន់ដើម្បីជៀសវាងការខាតបង់ប្រយោជន៍របស់ ពួកគេ ដោយសារតែហេតុថាច្បាប់មានលក្ខណៈតឹងតែងពេក។ ចំពោះក្រមនៃនីតិវិធីរដ្ឋប្បវេណីក៏ដូចគ្នា ដោយ ក្រមនេះ បានទុកចន្លោះឱ្យបុគ្គលដែលត្រូវបានគេកម្រិតសមត្ថភាពនោះ មានឱកាសចូលខ្លួនដើម្បីទទួលបានការការពារ ផលប្រយោជន៍ក្នុងពេលបន្ទាន់តាមផ្លូវបណ្ដឹងបានដែរដោយអនុវត្តក្រោមលក្ខខណ្ឌមួយចំនួនដូចខាងក្រោមនេះ៖

- **ការទុកពេលឱ្យកែតម្រូវ៖** បើតុលាការរកឃើញថាភាគីខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ឬ ខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ក្នុងការការពារអសមត្ថជននោះ តុលាការមិនធ្វើការបដិសេធបណ្ដឹងនោះភ្លាមៗទេ ពោលគឺតុលាការនឹងទុកពេលយ៉ាងសមរម្យមួយដើម្បីឱ្យភាគីធ្វើការកែតម្រូវត្រង់ចំណុចដែលខ្វះខាត ឬផ្ទុយទៅនឹងច្បាប់នោះ[12]។
- **ការអនុវត្តបណ្ដឹងជាបណ្ដោះអាសន្ន៖** តុលាការអាចនឹងធ្វើការអនុញ្ញាតឱ្យបុគ្គល ដែលត្រូវបានកម្រិតសមត្ថភាព ធ្វើសកម្មភាពបណ្ដឹងជាបណ្ដោះអាសន្នបាន បើមានការបង្កឱ្យខូចប្រយោជន៍របស់ជននោះក្នុងពេលបន្ទាន់ ឬដោយសារការយឺតយ៉ាវណាមួយក្នុងពេលធ្វើបណ្ដឹង[13]។
- **ការចូលខ្លួនការពាររបស់ភាគីមានសមត្ថភាព៖** បើមានភាគីមានសមត្ថភាពធ្វើបណ្ដឹង ឬអាណាព្យាបាល ឬ អាណាព្យាបាលទូទៅ ឬ ហិតូបត្ថម្ភកៈ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ បានចូលខ្លួន មកការពារ និងដោះស្រាយជូនបុគ្គលដែលមិនមានសមត្ថភាពក្នុងការធ្វើបណ្ដឹងនោះ ក្នុងរយៈពេលសមរម្យណាមួយ នាំឱ្យបណ្ដឹងដែលបុគ្គលនោះទាមទារឱ្យតុលាការជួយធ្វើការដោះស្រាយ នឹងមានអានុភាពប្រតិសកម្មចាប់តាំងពីពេលដែលបណ្ដឹងនោះបានធ្វើឡើង។ សិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្ដឹងត្រូវបានបញ្ជាក់ដោយលិខិតជាលាយលក្ខណ៍អក្សរ[14]។

### កថាភាគទី២. អ្នកតំណាងតាមផ្លូវបណ្ដឹង

ចំពោះពាក្យអ្នកតំណាងតាមផ្លូវបណ្ដឹងនេះ ក្នុងសំណុំរឿងរដ្ឋប្បវេណីត្រូវមានការចូលរួមពីភាគីដែលជាបុគ្គលពាក់ព័ន្ធនឹងវិវាទដើម្បីដំណើរការនីតិវិធីនៅស្ថាប័នតុលាការ ដោយភាគីត្រូវអះអាងបញ្ជាក់ភស្តុតាង ដែលជាផលប្រយោជន៍របស់ខ្លួនដើម្បីអាចឱ្យតុលាការពិចារណានៅពេលសម្រេចសេចក្ដីលើសពីនេះ ភាគីត្រូវចេះឆ្លើយតបទៅនឹងការអះអាងដែលភាគីម្ខាងទៀតបានថ្លែង ប៉ុន្តែចំពោះបុគ្គលណាដែលមិនមានចំណេះដឹងផ្លូវច្បាប់គ្រប់គ្រាន់ក្នុងការតតាំងក្ដី ឬ ចំពោះជនដែលត្រូវបានកម្រិតសមត្ថភាព នោះច្បាប់បានអនុញ្ញាតឱ្យមានអ្នកតំណាង

[12] មាត្រា៣៥ (វិធានការក្នុងការករណីដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ជាអាទិ៍) កថាខណ្ឌទី១ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[13] មាត្រា៣៥ (វិធានការក្នុងការករណីដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ជាអាទិ៍) កថាខណ្ឌទី១ វាក្យខណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[14] មាត្រា៣៥ (វិធានការក្នុងការករណីដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ជាអាទិ៍) កថាខណ្ឌទី២ និងកថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

តាមផ្លូវបណ្ដឹងអាចមានសិទ្ធិចូលរួមអ្នកតំណាងតាមផ្លូវបណ្ដឹង ជាទូទៅត្រូវបានច្បាប់ធ្វើការបែងចែកជា២ប្រភេទ គឺអ្នកតំណាងដែលច្បាប់បានកំណត់(១) និងអ្នកតំណាងដោយអាណត្តិ(២)។

### ១. អ្នកតំណាងដែលច្បាប់បានកំណត់

អ្នកតំណាងតាមច្បាប់កំណត់ គឺជាអ្នកតំណាងដែលច្បាប់តម្រូវ ដោយមិនអាចជ្រើសរើសតាមចិត្តរបស់ភាគីទេ។ អ្នកតំណាងដែលច្បាប់បានកំណត់ គឺជាអ្នកតំណាងដែលទទួលស្គាល់ដោយច្បាប់(**អនីតិជន**) ឬប្រកាសចេញដោយសាលក្រមរបស់តុលាការ(**ជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ**) ដែលអ្នកតំណាងនោះមានសិទ្ធិលើភាគីដែលស្ថិតក្រោមការតំណាងរបស់ខ្លួន ទៅតាមអ្វីដែលច្បាប់បានកំណត់ និងមានសិទ្ធិធ្វើបណ្ដឹងជំនួសឱ្យភាគីបានដែរក្នុងគោលបំណងការពារផលប្រយោជន៍របស់ភាគីនោះ។ ដែលជាទូទៅភាគីដែលស្ថិតក្រោមការតំណាងនោះ អសមត្ថភាពក្នុងការធ្វើបណ្ដឹង ដោយខ្លួនឯង ដូច្នេះហើយទើបច្បាប់បានអនុញ្ញាតឱ្យមានអ្នកតំណាង ដើរតួជាអ្នកការពារជនទាំងអស់នោះ ហើយអ្នកតំណាងដែលច្បាប់បានកំណត់នោះ នឹងធ្វើការពន្យល់រៀបរាប់ដូចខាងក្រោម៖

- **អាណាព្យាបាល៖** អ្នកតំណាងដែលច្បាប់បានកំណត់ប្រភេទនេះ ជាទូទៅ គឺជាឪពុកម្ដាយ ឬ ក៏អាចជាសាច់ញាតិជិតស្និតរបស់អនីតិជនដែលមើលថែ និងទទួលខុសត្រូវក្នុងនាមជាអាណាព្យាបាល បើមានវិវាទរដ្ឋប្បវេណីកើតឡើងឬក៏ត្រូវដោះស្រាយដែលបង្កឡើងដោយសកម្មភាពរបស់អនីតិជននោះអាណាព្យាបាលត្រូវចូលខ្លួនការពារជាចាំបាច់។
- **អាណាព្យាបាលទូទៅ៖** អ្នកតំណាងដែលច្បាប់បានកំណត់ជាអាណាព្យាបាលទូទៅនេះ កើតឡើងពីការប្រកាសទទួលស្គាល់របស់តុលាការ គឺការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីភាគី ដែលមានអាយុ១៥ឆ្នាំឡើងទៅ ដោយការអះអាងរបស់សាមីភាគីក្រោមមូលហេតុមានបញ្ហាខាងផ្នែកបញ្ញា ស្មារតី និងដើម្បីការពារពីការរំលោភបំពានសិទ្ធិពីជនឆ្លៀតឱកាស[15]។
- **ហិតូបត្ថម្ភកៈ៖** នៅក្នុងច្បាប់សារធាតុមិនបានកំណត់សិទ្ធិជាអ្នកតំណាងតាមផ្លូវបណ្ដឹងចំពោះជននៅក្រោមហិតូបត្ថម្ភនោះទេ ព្រោះជនហិតូបត្ថម្ភច្បាប់អនុញ្ញាតឱ្យធ្វើសកម្មភាពបណ្ដឹងខ្លួនឯងបានដោយគ្រាន់ មានការយល់ព្រមពីហិតូបត្ថម្ភកៈ។
- **អ្នកតំណាងពិសេស៖** អ្នកតំណាងពិសេស ជាអ្នកតំណាងជំនួសឱ្យអ្នកតំណាងតាមច្បាប់កំណត់ដែលបានរៀបរាប់ខាងលើ ក្នុងករណីដែលគ្មានអ្នកតំណាង ឬ អ្នកតំណាងមិនអាចប្រតិបត្តិនូវសិទ្ធិតំណាងនោះបានដូច្នេះបុគ្គលដែលមានបំណងធ្វើសកម្មភាពបណ្ដឹងជំនួសបុគ្គលដែលគ្មានសមត្ថភាពធ្វើបណ្ដឹងអាចដាក់ពាក្យស្នើសុំទៅតុលាការដើម្បីក្លាយជាអ្នកតំណាងពិសេស។ តុលាការអាចនឹងជ្រើសតាំង

[15] មាត្រា១៧ (អត្ថន័យនៃអនីតិជន) ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ព្រះរាជអាជ្ញា ជាអ្នកតំណាងពិសេសបាន ដើម្បីធ្វើសកម្មភាពបណ្ដឹងហើយ អ្នកតំណាងពិសេសត្រូវចាំបាច់មានការប្រគល់សិទ្ធិជាអ្នកតំណាង។ អ្នកតំណាងពិសេស គឺជាអ្នកតំណាងជំនួសអ្នកតំណាងដែលច្បាប់កំណត់ ដូច្នេះអាចប្រើប្រាស់សិទ្ធិអំណាចដូចអ្នកតំណាងដែលច្បាប់បានកំណត់ដែរ (មាត្រា ៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[16]។

## ២. អ្នកតំណាងដោយអាណត្តិ

អ្នកតំណាងដោយអាណត្តិ គឺជាអ្នកតំណាងដែលកើតចេញពីការយល់ព្រម ឬ ក៏កើតចេញពីឆន្ទៈរបស់ភាគីដោយផ្ដល់ឱ្យសិទ្ធិក្នុងការធ្វើបណ្ដឹងទៅអ្នកតំណាងនោះ ក្រោមមូលហេតុថាអ្នកតំណាងដោយអាណត្តិមានសមត្ថភាព មានបទពិសោធន៍តាមផ្លូវតុលាការច្រើនដែលធ្វើឱ្យដំណើរការក្នុងរឿងក្ដីមានភាពរលូន និងឆាប់រហ័សដែរ។ អ្នកតំណាងដោយអាណត្តិ ដែលជាទូទៅត្រូវបានមនុស្សគ្រប់គ្នាស្គាល់ថា ជាមេធាវី និងសូម្បីតែក្រមនៃនីតិវិធីរដ្ឋប្បវេណីក៏បានទទួលស្គាល់យ៉ាងដូច្នេះដែរ គឺត្រង់មាត្រា៥៣ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ដែលអ្នកតំណាងដោយអាណត្តិត្រូវតែជាមេធាវី។

មេធាវី គឺជាអ្នកតំណាងដែលត្រូវបានជ្រើសរើសផ្អែកតាមឆន្ទៈរបស់កូនក្ដី (ភាគីដើមចោទ ឬភាគីចុងចម្លើយ) សម្រាប់ពឹងពាក់ឱ្យការពារផលប្រយោជន៍ និងដំណើរការរឿងក្ដីឱ្យកាន់តែមានប្រសិទ្ធិភាព ឆាប់រហ័ស និងស្របតាមច្បាប់។ មិនត្រឹមតែប៉ុណ្ណោះ វិជ្ជាជីវៈមេធាវី គឺជាវិជ្ជាជីវៈមួយដែលមានភាពឯករាជ្យ និងដោយសេរីក្នុងការចូលខ្លួនបម្រើឱ្យវិស័យតុលាការ និងវិស័យយុត្តធម៌[17]។ ហើយមេធាវីខ្លួនឯងផ្ទាល់ ក៏ជាបុគ្គលដែលមានចំណេះ និងជំនាញខាងផ្នែកតុលាការច្បាស់លាស់ ព្រោះថាមេធាវី គឺជាអ្នករៀបចំឯកសារដាក់ពាក្យបណ្ដឹង និងតតាំងដោយផ្ទាល់មាត់នៅក្នុងសវនាការ ដើម្បីរកដំណោះស្រាយ ក៏ដូចជាភាពជោគជ័យជូនកូនក្ដីរបស់ខ្លួន។

ចំពោះសកម្មភាព នៃនីតិវិធីបណ្ដឹងរបស់អ្នកតំណាងដោយអាណត្តិអាចបង្កើតអានុភាពដូចភាគី ប៉ុន្តែអ្នកតំណាងដោយអាណត្តិមិនមែនជាភាគីទេ ដូច្នេះអ្នកតំណាងដោយអាណត្តិមិនអាចទទួលអានុភាពនៃសាលក្រម ដីកាសម្រេច របស់តុលាការឡើយ។ អ្នកតំណាងដោយអាណត្តិអាចមានសិទ្ធិធ្វើសកម្មភាព បណ្ដឹងដូចជាការដាក់ពាក្យបណ្ដឹង ការឆ្លើយដោះសារចំពោះពាក្យបណ្ដឹង ធ្វើបណ្ដឹងតប ប្ដឹងទាស់ ប្ដឹងតវ៉ា ការចូលរួមអន្តរាគមន៍បណ្ដឹង ដាក់បណ្ដឹងទៅតុលាការជាន់ខ្ពស់ ការចាត់តាំងអនុតំណាងជាមេធាវី។ ប្រសិនបើអ្នកតំណាងដោយអាណត្តិជាមេធាវី ភាគីមិនអាចកម្រិតនូវសិទ្ធិដែលត្រូវតំណាងបានឡើយ លើកលែងតែការដាក់បណ្ដឹងតប ការដកពាក្យបណ្ដឹង ការដកខ្លួនពីបណ្ដឹង ការលះបង់ការទាមទារ ការទទួលស្គាល់ការទាមទារ ការផ្សះផ្សា ការដាក់ពាក្យបណ្ដឹង និងការដកពាក្យបណ្ដឹងឧប្បាស្រ័យ។ ប៉ុន្តែករណីអ្នកតំណាងដោយអាណត្តិមិនមែនជាមេធាវី អាច

[16] មាត្រា៣៦ (អ្នកតំណាងពិសេស) កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[17] មាត្រា១ ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ។

ប្រើប្រាស់សិទ្ធិត្រឹមការព្រមព្រៀងតែប៉ុណ្ណោះ ហើយការព្រមព្រៀងគួរតែធ្វើជាលាយលក្ខណ៍អក្សរ។ បើទោះបីមានអ្នកតំណាងដោយអាណត្តិក្នុងដំណើរការនីតិវិធីបណ្តឹងក្តី ក៏ភាគីអាចចូលរួមក្នុងសកម្មភាពបណ្តឹងបានដដែល។ អ្នកតំណាងដោយអាណត្តិត្រូវតែជាមេធាវី លើកលែងតែក្នុងករណីពិសេសណាមួយនៃមាត្រា៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែលច្បាប់បានកំណត់លុះត្រាតែះ

- **រឿងក្តីក្រោមទឹកប្រាក់ ១.០០០.០០០រៀលះ** តុលាការអនុញ្ញាតឱ្យតតិយជន ក្លាយជាអ្នកតំណាងដោយអាណត្តិបាន ដោយមិនមែនជាមេធាវី
- **ការតែងតាំងបុគ្គលិកពីស្ថាប័នរដ្ឋះ** តុលាការអនុញ្ញាតឱ្យបុគ្គលិកដែលជាតំណាងដោយស្ថាប័នរដ្ឋណាមួយ ក្លាយជាអ្នកតំណាងដោយអាណត្តិបាន ដែលមិនមែនជាមេធាវី
- **ការអនុញ្ញាតពីច្បាប់ះ** ក្នុងករណីច្បាប់ផ្សេងទៀតអនុញ្ញាតឱ្យមានការតែងតាំងតតិយជន ឱ្យក្លាយជាអ្នកតំណាងដោយអាណត្តិ ឬ ក្រមនីតិវិធីរដ្ឋប្បវេណីជាដើម[18] ។

សរុបសេចក្តីមក អ្នកតំណាងតាមផ្លូវបណ្តឹងក្នុងសំណុំរឿងរដ្ឋប្បវេណីច្បាប់បញ្ញត្តិឡើងមកក្នុងគោលបំណងការពារផលប្រយោជន៍ស្របច្បាប់របស់ភាគីជាជនត្រូវបានកម្រិតសមត្ថភាព ឬ បុគ្គលទូទៅដែលខ្វះខាតចំណេះដឹងផ្លូវច្បាប់ ពុំមានពេលវេលាគ្រប់គ្រាន់ធ្វើសកម្មភាពបំពេញកិច្ចនីតិវិធីដែលតុលាការបានបង្គាប់ឱ្យធ្វើ អាចមានអ្នកតំណាងតាមផ្លូវបណ្តឹង ដើម្បីធ្វើសកម្មភាពជំនួសខ្លួននេះជាតម្លាភាពក្នុងការផ្តល់ភាពយុត្តធម៌ដល់ភាគីនៅស្ថាប័នតុលាការ ។

## កថាភាគទី៣. នីតិវិធីនៃការដាក់ពាក្យ

### ១. ទម្រង់ពាក្យបណ្តឹង

ទម្រង់នៃពាក្យបណ្តឹង គឺជាបណ្តុំឯកសារដែលត្រូវរៀបចំ និងបំពេញឱ្យបានត្រឹមត្រូវព្រមទាំងគ្រប់ជ្រុងជ្រោយទើបតុលាការសម្រេចទទួលយក ដោយឆ្លងកាត់ដំណាក់កាត់នៃការត្រួតពិនិត្យបណ្តឹងដែរ[19] ។បើក្នុងករណីតុលាការត្រួតពិនិត្យ និងរកឃើញថា ទម្រង់ពាក្យបណ្តឹងដែលបានដាក់ជូននោះ មានលក្ខណៈខ្វះខាត មិនពេញលេញត្រឹមត្រូវ នោះតុលាការនឹងទុកពេលឱ្យកែតម្រូវ ឬអាចលើកបណ្តឹងចោលបានក្នុងករណីមិនព្រមធ្វើការកែតម្រូវ[20]។ បញ្ហាទាំងអស់នេះហើយ ដែលជាមូលហេតុនាំឱ្យយើងត្រូវសិក្សាជាមុន ចំណុចត្រូវសរសេរក្នុងពាក្យបណ្តឹង(១) និងចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្តឹង (២) ។

[18] មាត្រា៥៣ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[19] មាត្រា៧៨ (ការពិនិត្យពាក្យបណ្តឹង) កថាខណ្ឌទី១ និងកថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[20] មាត្រា៧៨ (ការពិនិត្យពាក្យបណ្តឹង) កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

## ១.១. ចំណុចត្រូវសរសេរក្នុងពាក្យបណ្ដឹង

ថ្វីត្បិតតែគំរូនៃពាក្យបណ្ដឹងនោះមានបោះពុម្ពរួចជាស្រេចហើយក៏ដោយ ប៉ុន្តែក៏នៅតែមានចន្លោះដែលភាគីដើមបណ្ដឹងរដ្ឋប្បវេណីត្រូវធ្វើការបំពេញជាចាំបាច់ដែលរួមមានដូចជាអំពីភាគី (១.១) កម្មវត្ថុ និងមូលហេតុនៃការទាមទារ (១.២)។

### ១.១.១ អំពីភាគី

ជានីតិវិធីការប្ដឹងត្រូវធ្វើដោយដាក់ពាក្យបណ្ដឹងជាលាយល័ក្ខអក្សរទៅតុលាការ[21]។ នៅក្នុងគំរូនៃពាក្យបណ្ដឹងតែងតែបានបន្សល់ទុកចន្លោះសម្រាប់ឱ្យដើមបណ្ដឹង ធ្វើការបំពេញព័ត៌មានផ្ទាល់ខ្លួន សមាសភាពរបស់ភាគីម្ខាងទៀត និងអង្គហេតុសំខាន់ៗ មានន័យថាដែលច្បាប់បានតម្រូវឱ្យមាននៅក្នុងគំរូពាក្យបណ្ដឹងនោះ រួមមានដូចជា៖

- **សរសេរ ឬបំពេញ ឈ្មោះ នាមករណ៍៖** ឈ្មោះ នាមករណ៍របស់ភាគី ឬអ្នកតំណាងដែលច្បាប់បាន កំណត់ឱ្យបានច្បាស់លាស់ព្រោះថា ពិតជាមានភាពចាំបាច់ខ្លាំងណាស់ក្នុងពាក្យបណ្ដឹងព្រោះដើម្បីកំណត់បានអត្តសញ្ញាណ របស់បុគ្គលរងគ្រោះ ឬជនខូចប្រយោជន៍ និងជាការតម្រូវរបស់ច្បាប់ដែរ ដែលកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីប្រសិនបើយើងពុំបានកំណត់អត្តសញ្ញាណនោះវា និងបង្កភាពស្មុគស្មាញក្នុងបណ្ដឹងព្រមទាំងធ្វើខាតពេលវេលាក្នុងការកែតម្រូវ[22]។
- **ក្នុងករណីភាគីជានីតិបុគ្គល៖** បើភាគីបណ្ដឹងជានីតិបុគ្គលវិញ នោះយើងមិនអាចសរសេរ ឬ បំពេញឈ្មោះបុគ្គល ដែលមានវត្តមាន ឬ ធ្វើការនៅក្នុងក្រុមហ៊ុននៃនីតិបុគ្គលទាំងអស់នោះបានទេ និងមិនអាចយកឈ្មោះ ឬ នាមករណ៍ក្រុមហ៊ុនរបស់នីតិបុគ្គលនោះមកសរសេរបានឡើយ ពោលគឺត្រូវយកឈ្មោះ ឬ នាមករណ៍នៃអ្នកតំណាងរបស់ក្រុមហ៊ុននៃនីតិបុគ្គលនោះ មកសរសេរជំនួសវិញ។
- **ទីតាំងអាសយដ្ឋាន៖** ការសរសេរបញ្ជាក់អំពីអាសយដ្ឋានឱ្យបានច្បាស់លាស់គឺជាការចាំបាច់សម្រាប់ភាគីដើម្បីបង្កភាពងាយស្រួលដល់តុលាការសម្រាប់ធ្វើការបញ្ជូន និងផ្ញើពាក្យបណ្ដឹង និងឯកសារផ្សេងទៀតទៅកាន់ភាគីទាំងសងខាង។ ម៉្យាងទៀតប្រសិនបើភាគីមាន អ្នកតំណាងដែលច្បាប់កំណត់នោះពាក្យបណ្ដឹង ត្រូវសរសេរបញ្ជាក់អំពីអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងគោលបំណងបង្កភាពងាយស្រួលដល់តុលាការក្នុង ការបញ្ជូន និង ផ្ញើពាក្យបណ្ដឹង និង ឯកសារផ្សេងៗដូចជាដីកាកោះ(សម្រាប់ភាគីនៃវិវាទ, អ្នកតំណាងជា អាណាព្យាបាល ឬ អ្នកតំណាងឱ្យនីតិបុគ្គល) ឬ លិខិតអញ្ជើញ (សម្រាប់អ្នកតំណាងដោយអាណត្តិរបស់ភាគីនៃវិវាទជាមេធាវី) ហេតុដូចនេះក៏ព្រោះតែនៅក្នុងករណីខ្លះដែលភាគីម្ខាងជាអ្នកអសមត្ថភាពក្នុងបណ្ដឹង[23]។

---

[21] មាត្រា៧៥ (របៀបដាក់ពាក្យបណ្ដឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង) កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[22] មាត្រា៧៥ (របៀបដាក់ពាក្យបណ្ដឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង) កថាខណ្ឌទី២ ចំណុច(ក) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[23] មាត្រា៧៥ (របៀបដាក់ពាក្យបណ្ដឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង) កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ១.១.២ កម្មវត្ថុ និងមូលហេតុនៃការទាមទារ

នៅក្នុងពាក្យបណ្តឹងដែលនឹងត្រូវដាក់ជូនតុលាការ ចំណុចដែលសំខាន់បំផុតនោះ គឺការសរសេរបញ្ជាក់អំពីកម្មវត្ថុ និងមូលហេតុនៃការទាមទារ ពីព្រោះថាចំណុចនេះនឹងបង្ហាញឱ្យតុលាការបានឃើញពីមូលហេតុដែលយើងធ្វើបណ្តឹង និងបានដឹងពីចំណុចនៃការទាមទារក៏ដូចជាអង្គហេតុដែលនាំឱ្យមានវិវាទតាមផ្លូវច្បាប់កើតមានឡើងដែរ។ នៅក្នុងគំរូនៃពាក្យបណ្តឹងនោះ ភាគីដែលជាដើមបណ្តឹងរដ្ឋប្បវេណី គប្បីត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់ពី៖

- **កម្មវត្ថុនៃការទាមទារ៖** ត្រង់ចំណុចនេះភាគីដើមបណ្តឹងរដ្ឋប្បវេណីចាំបាច់ត្រូវសរសេរឱ្យបានច្បាស់លាស់ និងចំៗ ពីខ្លឹមសារនៃសាលក្រម ដែលដើមចោទធ្វើការទាមទារឱ្យតុលាការចេញតាមការចង់បាន របស់ខ្លួន ដោយផ្អែកលើទំហំនៃការខាតបង់ និងខូចប្រយោជន៍ ដែលបណ្តាលមកពីវិវាទដែលបានកើត ឡើងដោយសកម្មភាពភាគីម្ខាងទៀត[24]។
- **មូលហេតុនៃការទាមទារ៖** ដោយឡែកចំពោះចំណុចនេះវិញ ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក៏ត្រូវធ្វើការសរសេររៀបរាប់ជាចាំបាច់អង្គហេតុសំខាន់ៗ ដើម្បីបញ្ជាក់ពីមូលហេតុនៃការទាមទាររបស់ខ្លួនដែរ ព្រោះថាកាលណាការសរសេរអង្គហេតុបានក្បោះក្បាយត្រឹមត្រូវ និងសមហេតុផលល្អនោះវានឹងជាកាតាលីករជម្រុញឱ្យយើងមានឱកាសឈ្នះក្តីក៏កាន់តែខ្ពស់ដែរ[25]។

### ១.២ ចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្តឹង

បន្ទាប់បានរៀបរាប់ពីចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង អ្វីដែលយើងគួរធ្វើបន្តក្រៅពីដូចដែលបានរៀប រាប់ខាងលើរួចមកហើយនោះ យើងក៏មានការបង្ហាញពីអ្វីដែលគួរគប្បីសរសេរលើចំណុចមូលហេតុនៃការទាមទារក្នុងពាក្យបណ្តឹងនោះដែរដែលមានដូចជា៖

- **អង្គហេតុចម្បងនៃការកកើតសិទ្ធិ៖** គឺជាអង្គហេតុដែលត្រូវរៀបរាប់ពីមូលហេតុដែលនាំឱ្យមានការបង្កើតសិទ្ធិ ពោលគឺវាជាលំនាំបញ្ហាដែលនាំឱ្យមានវិវាទរវាងភាគីកើតមានឡើង។ ឧទាហរណ៍ កិច្ចសន្យាខ្ចីបរិភោគ ចំនួន៩០០០ដុល្លារ ត្រង់ចំណុចនេះយើងគួរគប្បីសរសេរយ៉ាងណាឱ្យមានភាពក្បោះក្បាយត្រឹមត្រូវ សមហេតុផលទៅតាមអង្គហេតុដែលបានកើតឡើងព្រោះថាវាគឺជាអង្គហេតុសំខាន់ព្រមទាំងវាជាកម្មវត្ថុក្នុងការទាមទារផងដែរ ដែលនឹងនាំឱ្យមានអង្គហេតុផ្សេងៗ ទៀតកើតមានឡើង។
- **អង្គហេតុនាំឱ្យមានការរារាំងក្នុងការកកើតសិទ្ធិ៖** ជាអង្គហេតុ ឬ មូលហេតុដែលនាំឱ្យមានការចាប់ផ្តើមមកពីកិច្ចសន្យាដែលមិនមានអានុភាពគតិយុត្ត ឬ ពុំបានធ្វើទៅតាមទម្រង់បែបបទដែលច្បាប់បានតម្រូវ។

---

[24] មាត្រា៧៥ (របៀបដាក់ពាក្យបណ្តឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង) កថាខណ្ឌទី២ ចំណុច(ខ) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[25] មាត្រា៧៥ (របៀបដាក់ពាក្យបណ្តឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង) កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ឧទាហរណ៍ លោក ខ បានខ្ចីបរិភោគដោយភ្ជាប់នឹងការប្រាក់ ៥០.០០០ ដុល្លារ ពីលោក ក បន្ទាប់មក លោក ខ មិនបានអនុវត្តកាតព្វកិច្ចដោយសងជាប្រាក់ ឬ បង់ការប្រាក់ជូន ទៅឱ្យលោក ក វិញឡើយ។ នៅត្រង់ចំណុចបនេះលោក ក ពុំមានសិទ្ធិទាមទារឱ្យលោក ខ បង់ការប្រាក់មកឱ្យខ្លួនឡើយក៏ព្រោះថា កិច្ចសន្យានេះមិនបានបង្កើតអានុភាពឡើយ ស្របតាមមាត្រា៥៨៣ កថាខណ្ឌទី៣ (ប្រសិនបើពុំបានធ្វើតាមលិខិតជាលាយលក្ខណ៍អក្សរដោយចុះហត្ថលេខារបស់អ្នកខ្ចីទេ ពុំមានអានុភាពឡើយ)។ នេះគឺជាអង្គហេតុសំខាន់ដែលវាជាភស្តុតាងដោះបន្ទុកលើភាគីចុងចម្លើយ និងជាអង្គហេតុដែលជួយយើងក្នុងដំណាក់កាលសវនាការបានដែរ ប៉ុន្តែប្រាក់ដើមលោក ក នៅតែមានសិទ្ធិទាមទារមកវិញបាន។

- **អង្គហេតុនាំឱ្យមានការរំលត់សិទ្ធិ៖** គឺជាអង្គហេតុតវ៉ារបស់ចុងចម្លើយលើការចោទប្រកាន់ ដែលអះអាងពីការរលត់កាតព្វកិច្ចរបស់ខ្លួន និងការរំលត់សិទ្ធិរបស់ដើមចោទក្នុងកិច្ចសន្យា ឧទាហរណ៍ លោក ខ បានធ្វើកិច្ចសន្យាខ្ចីបរិភោគ ជាមួយលោក គ ចំនួន៨០.០០០ដុល្លារ។ មិនយូរប៉ុន្មានលោក ខ បានបំពេញកាតព្វកិច្ចចប់រួចរាល់ ក៏ប៉ុន្តែលោក គ នៅតែបន្តទាមទារប្រាក់បន្តទៀត តែលោក ខ បានអះអាងថាបានសងប្រាក់៨០.០០០ដុល្លារ ឬក៏បាន សងជាការប្រាក់គ្រប់ចំនួនទៅលោក គ រួច ត្រង់ចំណុចនេះ អាចជាប្រយោជន៍ដល់ចុងចម្លើយប៉ុន្តែដើមបណ្ដឹង ឬអ្នកដាក់ពាក្យបណ្ដឹង អាចសរសេរ ឬយកចំណុចនេះជាឱកាសក្នុងការយកលេស ឬហេតុផលមិនសមរម្យក្នុងការលើកឡើង របស់ចុងចម្លើយបាន។
- **អង្គហេតុបង្កើតការរារាំងការអនុវត្តសិទ្ធិ៖** អង្គហេតុខាងលើ វាគឺជាការ អះអាងពីការតវ៉ារបស់ចុងចម្លើយក្នុងការមិនព្រមអនុវត្តកាតព្វកិច្ចខ្លួន ដោយស្ថិតក្រោមហេតុផលមួយថាការទាមទាររបស់ម្ចាស់បំណុលពុំត្រឹមត្រូវឡើយ។ ឧទាហរណ៍ លោក ខ អះអាងថានឹងសងប្រាក់១៥០.០០០ដុល្លារ ទៅលោក ក នៅពេលកំណត់ណាមួយដែលមានចែងក្នុងកិច្ចសន្យា ប៉ុន្តែពេលកំណត់មិនទាន់មកដល់ លោក ក បានអនុវត្តសិទ្ធិទាមទារប្រាក់មកវិញដែលជាហេតុនាំឱ្យលោក ខ បានរារាំងការអនុវត្តសិទ្ធិរបស់លោក ក។ អង្គហេតុនេះ ក៏អាចជាប្រយោជន៍ដល់ ចុងចម្លើយបានដែរ ។

## ២. ការពិនិត្យលើពាក្យបណ្ដឹង និងការចាត់ចែងលើពាក្យបណ្ដឹង

### ២.១ ការពិនិត្យលើពាក្យបណ្ដឹង

#### ២.១.១ លក្ខខណ្ឌទម្រង់

បន្ទាប់ពីបានទទួលពាក្យបណ្ដឹង ចៅក្រមដែលទទួលបន្ទុកចំពោះរឿងក្ដីតាមការបែងចែកសំណុំរឿងក្ដី ត្រូវធ្វើការពិនិត្យពាក្យបណ្ដឹង។ ការពិនិត្យពាក្យបណ្ដឹងនេះជានីតិវិធីមួយសំខាន់ក្នុងចំណោមនីតិវិធីផ្សេងទៀតដោយតុលាការត្រូវពិនិត្យអំពីភាពស្រប ឬមិនស្របនឹងលក្ខខណ្ឌនៃទម្រង់ មុននឹងបញ្ជូនពាក្យបណ្ដឹងទៅចុងចម្លើយ ឬមុននឹងបន្តនីតិវិធី។ ផ្អែកតាមមាត្រា៧៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការពិនិត្យ ពាក្យបណ្ដឹងអំពី

ចំណុចដែលចាំបាច់ត្រូវសរសេរក្នុងពាក្យបណ្តឹងតាមបញ្ញត្តិនៃមាត្រា៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ហេតុនេះការពិនិត្យពាក្យបណ្តឹងផ្អែកតាមមាត្រា ៧៨ កថាខណ្ឌទី១ ខាងលើ មិនមែនជាការពិនិត្យអំពីភាពស្រប ឬ មិនស្របនឹងផលប្រយោជន៍នៃបណ្តឹង ឬ លក្ខខណ្ឌបណ្តឹងផ្សេងទៀត ឬ ការទាមទារតាមផ្លូវបណ្តឹងមានមូលហេតុ ត្រឹមត្រូវ ឬ មិនត្រឹមត្រូវនោះទេ។ តុលាការនឹងពិនិត្យពាក្យបណ្តឹង ចំពោះចំណុចដែលចាំបាច់ត្រូវ សរសេរនៅក្នុងពាក្យបណ្តឹងរួមមាន ចំណុចស្តីពីភាគី និងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ព្រមទាំងអង្គហេតុ ចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ។ ចំពោះចំណុចស្តីពីភាគី តុលាការនឹងពិនិត្យមើលឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកតំណាងនីតិបុគ្គល។ ចំណែកឯ ចំណុចស្តីពី ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារគឺជាការសរសេរអំពីការទាមទារតាមផ្លូវបណ្តឹងដែលជាកម្មវត្ថុនៃបណ្តឹងហេតុនេះ តុលាការនឹង ពិនិត្យពាក្យបណ្តឹង ដោយប្រើប្រាស់វិធីបញ្ជាក់អំពីការទាមទារគឺ ការកំណត់អំពីភាគី និងអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់នីតិឯកជនដែលបានកំណត់មួយ។

ការពិនិត្យអំពីភាពត្រឹមត្រូវនៃពាក្យបណ្តឹងចំពោះចំណុចស្តីពីខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ តុលាការត្រូវធ្វើឡើងដោយ រួមគ្នា ពោលគឺពុំធ្វើការពិចារណាផ្សេងៗ គ្នានោះទេ ពីព្រោះចំណុចទាំងពីរនេះ គឺជាកម្មវត្ថុនៃបណ្តឹង។ ឧទាហរណ៍៖ លោក ក បានលក់កុំព្យូទ័រ មួយគ្រឿងតម្លៃ ១.០០០ ដុល្លារអាមេរិកឱ្យ លោក ខ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ហើយបានប្រគល់កុំព្យូទ័រនោះឱ្យលោក ខ រួចរាល់ ប៉ុន្តែលោក ខ មិនបានបង់ប្រាក់ថ្លៃលក់តាមពេលកំណត់ទេ ហេតុនេះ លោក ក បានដាក់ពាក្យបណ្តឹងទាមទារឱ្យលោក ខ បង់ប្រាក់ថ្លៃលក់ទិញកុំព្យូទ័រមកឱ្យខ្លួន។

### ២.១.២ ពន្ធដាក់ពាក្យសុំ

ផ្អែកតាមមាត្រា ៧៨ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្រៅពីការពិនិត្យទម្រង់នៃពាក្យបណ្តឹង (ចំណុចដែលចាំបាច់ត្រូវសរសេរក្នុង ពាក្យបណ្តឹង) តុលាការត្រូវពិនិត្យអំពីពន្ធដាក់ពាក្យសុំផងដែរ មានន័យថា នៅពេលដើមចោទដាក់ពាក្យបណ្តឹងចាំបាច់ត្រូវបង់ពន្ធដាក់ពាក្យសុំ ក្នុងករណីដើមចោទមិនបង់ពន្ធដាក់ពាក្យសុំ តុលាការត្រូវបង្គាប់ឱ្យបង់ ដោយកំណត់អំឡុងពេលសមរម្យ ប្រសិនបើដើមចោទ មិនបង់តាមការ កំណត់ទេ តុលាការត្រូវលើកពាក្យបណ្តឹងចោលដោយដីកាសម្រេច។ ការបង់ពន្ធដាក់ពាក្យសុំត្រូវអនុវត្តតាម មាត្រា៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ចំពោះ បណ្តឹងតប ត្រូវអនុវត្តដូចគ្នានឹងបណ្តឹងដើមពោលគឺ ពាក្យបណ្តឹងតប ត្រូវសរសេរនូវចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុង ពាក្យបណ្តឹងតាមបញ្ញត្តិនៃមាត្រា ៧៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ហើយត្រូវបង់ពន្ធដាក់ពាក្យសុំដូចបណ្តឹងដើមដែរ។ ក្នុងករណីដើមចោទនៃបណ្តឹងតបមិនបង់ពន្ធដាក់ពាក្យសុំទេ

តុលាការត្រូវបង្គាប់ឱ្យបង់ហើយ ប្រសិនបើមិនបង់តាមការកំណត់ទេតុលាការត្រូវលើកពាក្យបណ្តឹងនោះចោលដោយដីកាសម្រេច។

### ២.២ ការចាត់ចែងលើពាក្យបណ្តឹង

#### ២.២.១ តុលាការចេញដីកាសម្រេចបង្គាប់ឱ្យកែតម្រូវ

ដូចបានបង្ហាញខាងលើរួចមកហើយក្នុងករណីពាក្យបណ្តឹងពុំបានសរសេរ ឬ សរសេរមិនត្រឹមត្រូវចំពោះចំណុចស្តីពីភាគីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារព្រមទាំងមិនបង់ពន្ធដាក់ពាក្យសុំតុលាការត្រូវ និងចេញដីកាសម្រេចបង្គាប់ឱ្យកែតម្រូវដោយកំណត់អំឡុងពេលសមរម្យ ផ្អែកតាមបញ្ញត្តិនៃមាត្រា៧៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ឧទាហរណ៍៖ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ លោក ក បានលក់កុំព្យូទ័រ មួយគ្រឿងតម្លៃ ១.០០០ ដុល្លារអាមេរិកឱ្យលោក ខ ហើយបានប្រគល់ កុំព្យូទ័រនោះឱ្យលោក ខ រួចរាល់ ប៉ុន្តែ កំណត់ពេលបង់ប្រាក់បានមកដល់ លោក ខ មិនបង់ថ្លៃលក់នោះទេទោះបីជា លោក ក បានធ្វើការដាស់តឿនច្រើនដងក៏ដោយ។ ក្នុងករណីនេះ លោក ក បានដាក់ពាក្យបណ្តឹងសុំរំលាយកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ រវាងដើមចោទ និងចុងចម្លើយ ប៉ុន្តែការទាមទារឱ្យរំលាយកិច្ចសន្យា ជាពាក្យបណ្តឹងដែលមាន ចំណុចខ្វះខាត មិនស្របនឹងទម្រង់នៃពាក្យបណ្តឹងដូចជាមិនបានបញ្ជាក់អាសយដ្ឋានជាដើម។

#### ២.២.២ តុលាការចេញដីកាសម្រេចលើកចោលពាក្យបណ្តឹង

ក្នុងករណីពាក្យបណ្តឹងមានចំណុចខ្វះខាត ជាអាទិ៍ ហើយតុលាការបានចេញដីកាសម្រេចបង្គាប់ឱ្យកែតម្រូវ ប៉ុន្តែភាគីពុំបានធ្វើការកែតម្រូវ ក្នុងអំឡុងពេលដែលបានកំណត់ទេតុលាការត្រូវលើកពាក្យបណ្តឹងចោលដោយដីកាសម្រេច ស្របតាមបញ្ញត្តិនៃមាត្រា៧៨ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

# ជំពូកទី២

# ដំណើរការនីតិវិធីនៃការ

# ជម្រះក្តីលើកទី១

# ជំពូកទី២
# ដំណើរការនីតិវិធីនៃការជម្រះក្តីលើកទី១

ក្រោយពីបានបញ្ចប់នូវនីតិវិធីនៃការចាប់ផ្តើមបណ្តឹងរួចរាល់ហើយ គឺជាជំហានបន្ទាប់នៃនីតិវិធីនៃការជំនុំជម្រះក្តីក៏ត្រូវបាន ចាប់ផ្តើមស្របតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាផងដែរ ដោយនីតិវិធីនៃការជំនុំ ដោយដំណាក់កាលនេះ ជាការរៀបចំដើម្បីដំណើរការរឿងក្តីនៅក្នុងសវនាការ ដែលភាគីខាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ពាក្យបណ្តឹងទាមទារឱ្យតុលាការជួយធ្វើការដោះស្រាយវិវាទដែលកើតមានឡើង និងក៏ជាឱកាសរបស់ចុងចម្លើយក្នុងការ ឆ្លើយតតាំងនឹងការចោទប្រកាន់របស់ដើមចោទដែរ ដោយភាគីនីមួយៗធ្វើការអះអាងដោយផ្ទាល់មាត់ដោយ បញ្ជាក់ពីហេតុផល និងដំណោះស្រាយរៀងៗខ្លួន ដើម្បីការពារផលប្រយោជន៍របស់ពួកគេ។ នៅក្នុងដំណាក់ កាលនៃដំណើរការនីតិវិធីនៃការជម្រះក្តីលើកទី១ ឬ ដំណើរការនីតិវិធីនៃការជម្រះក្តីនៅសាលាដំបូង ត្រូវបានចែក ចេញជា២នីតិវិធីសំខាន់ៗ គឺនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (ផ្នែកទី១) និងនីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់(ផ្នែកទី២)។ ដូចនេះយើងនឹងធ្វើការសិក្សា និងអត្ថាធិប្បាយបន្តលើនីតិវិធីនៃការជំនុំជម្រះក្តីដូចតទៅៈ

## ផ្នែកទី១. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីរៀបចំនូវការអះអាងរបស់ភាគី និងរៀបចំ ឬ កំណត់នូវចំណុចវិវាទនៃរឿងក្តីព្រមទាំងរៀបចំនូវភស្តុតាងដែលពាក់ព័ន្ធ នឹងចំណុចវិវាទដើម្បីឱ្យតុលាការអាចធ្វើការពិនិត្យភស្តុតាងដោយសមូហវិធីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ [26] ។ ហើយនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមាន ប៉ុន្តែមិនចាំបាច់ទាមទារឱ្យធ្វើជាសាធារណៈឡើយ ដោយជាធម្មតាគឺគេប្រើបន្ទប់ក្រៅពីសាលសវនាការដូចជាការអនុវត្តជាក់ស្តែង គឺគេប្រើប្រាស់បន្ទប់របស់ចៅក្រមដើម្បីធ្វើនីតិវិធីនេះ ជាអាទិ៍។

ជាគោលការណ៍ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការមិនអាចធ្វើការពិនិត្យភស្តុតាងបានទេ លុះត្រាតែការពិនិត្យភស្តុតាងនោះ គឺជាការពិនិត្យភស្តុតាងជាឯកសារ ដែលជាករណីចាំបាច់ត្រូវរៀបចំ ឬ កំណត់នូវចំណុចវិវាទ និង ភស្តុតាង ដូចនេះតុលាការអាចធ្វើការពិនិត្យភស្តុតាងជាឯកសារបាននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ផ្ទុយមកវិញ ចំពោះការពិនិត្យភស្តុតាងដទៃទៀត ដូចជា ការសាកសួរសាក្សី, ការសាកសួរសាមីភាគី, ការធ្វើកោសល្យវិច័យ និងការត្រួតពិនិត្យ គឺមិនអាចធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ។

[26] មាត្រា១០៣ (គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ហេតុដូច្នេះហើយ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្ដីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្ដីដែលគូភាគីយល់មិនស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្ដីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្ដីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យ បានល្អិតល្អន់ ។មុននឹងចូលទៅកាន់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយើងគួរស្វែងយល់ពីសំណុំឯកសារត្រៀម (កថាភាគទី១) និងសកម្មភាពក្នុងពេល ដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល(កថាភាគទី២)។

**កថាភាគទី១. សំណុំឯកសារត្រៀម**

សំណុំឯកសារត្រៀម គឺឯកសារដែលត្រៀមសម្រាប់ចូលទៅកាន់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីធ្វើការបង្ហាញ និងដាក់ជូនទៅកាន់តុលាការអំពីអង្គហេតុនៃចំណុចវិវាទ កម្មវត្ថុនៃការទាមទារ និងមូល ហេតុនៃការទាមទាររបស់ភាគី និងសំណុំភស្តុតាងជាឯកសារសំខាន់ផ្សេងៗទៀតដើម្បីឱ្យតុលាការបានត្រួតពិនិត្យ និងរក្សាទុកឯកសារទាំងអស់នោះសម្រាប់ជាភស្តុតាងដើម្បីបន្តនីតិវិធីដំណាក់កាលដទៃទៀតបានដែរដែលជាទូទៅ នៅក្នុងសំណុំនៃឯកសារត្រៀមនោះមានដូចជា ឯកសារត្រៀម (១) និងចំណុចដែលត្រូវសរសេរនៅក្នុងឯកសារត្រៀម(២)។

**១. ឯកសារត្រៀម**

បទបញ្ញត្តិស្តីពីឯកសារត្រៀមត្រូវបានបញ្ញត្តិនៅក្នុងមាត្រា ១០១ និងមាត្រា១០២ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែលខ្លឹមសារជារួមបានចែង អំពីសិទ្ធិអំណាចរបស់តុលាការ ក្នុងការបង្គាប់ឲ្យភាគីដាក់ឯកសារត្រៀម ក៏ដូចជាចែងអំពីខ្លឹមសារនៃឯកសារត្រៀមរបស់ដើមចោទ និងចុងចម្លើយផងដែរ[27]។ ឯកសារត្រៀម គឺជាឯកសារផ្ទុកនូវចំណុចជាក់លាក់សម្រាប់ការពារការទាមទារ ឬតទល់រវាងភាគី។ ឯកសារត្រៀមមានសារៈសំខាន់ណាស់សម្រាប់ដំណើរការដោះស្រាយនីតិវិធីបណ្ដឹងឲ្យបានឆាប់រហ័ស ដោយហេតុថាតុលាការពឹងផ្អែកលើឯកសារនេះ ដើម្បីរៀបចំនូវសេចក្ដីអះអាងរបស់ភាគី បំភ្លឺចំណុចវិវាទនៃរឿងក្ដី រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទ ក៏ដូចជាអង្គហេតុដែលមាន ឬ គ្មានវិវាទ ដើម្បីឈានដល់ដំណាក់កាលបន្ទាប់នៃនីតិវិធី។ ឯកសារត្រៀម មិនត្រូវបានកំណត់ចំនួនប៉ុន្មានច្បាប់ទេ ដោយនៅក្នុងរឿងក្ដីដែលមានលក្ខណៈស្មុគស្មាញមួយចំនួន ក៏មានការដាក់ឯកសារត្រៀមច្រើនដងផងដែរ។

**ការដាក់ឯកសារត្រៀមរបស់ចុងចម្លើយ ធ្វើឡើងដើម្បី៖**

- ឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្ដឹង។
- ការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង។
- បញ្ជាក់អំពីអង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុ ដែលមានសរសេរនៅក្នុងពាក្យបណ្ដឹងរបស់ដើមចោទ។
- ឆ្លើយតបចំពោះឯកសារត្រៀមរបស់ដើមចោទ។

[27] មាត្រា១០១ (ឯកសារត្រៀម) កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

**ចំណែកឯការដាក់ឯកសារត្រៀមរបស់ដើមចោទ ធ្វើឡើងដើម្បី៖**

- ទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះអង្គហេតុតវ៉ា ក្នុងករណីចុងចម្លើយបានអះអាងអំពីអង្គហេតុតវ៉ា។
- តវ៉ាតប ចំពោះការអះអាងរបស់ចុងចម្លើយ។
- ឆ្លើយតបចំពោះឯកសារចម្លើយ (ឯកសារត្រៀមលើកទី១) ឬឯកសារត្រៀម របស់ចុងចម្លើយ។
- អះអាងអំពីអង្គហេតុផ្សេងទៀត ដែលមានប្រយោជន៍ចំពោះខ្លួន។

ជាទូទៅឯកសារត្រៀមត្រូវដាក់តាមរយៈការបង្គាប់ឲ្យដាក់ពីតុលាការ ដែលអាចត្រូវបានដាក់នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល រហូតដល់ដំណាក់កាលចុងក្រោយនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ អាស្រ័យ ទៅលើភាពស្មុគស្មាញនៃរឿងក្តី។ ប៉ុន្តែទោះបីជា ការដាក់ឯកសារត្រៀមអាចដាក់បានច្រើនដង និង គ្រប់ពេលក៏ដោយ ប៉ុន្តែដាក់ស្តែងដើម្បីកុំឲ្យអូសបន្លាយពេលវេលាយូរ តុលាការជាអ្នកកំណត់ពេលសមរម្យណាមួយ មុនពេលធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ (បើកសវនាការជំនុំជម្រះ) ក្នុងការឲ្យគូភាគីដាក់ឯកសារត្រៀមនេះ។

## ២. ចំណុចដែលត្រូវសរសេរនៅក្នុងឯកសារត្រៀម

ផ្អែកតាមមាត្រា ១០១ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឯកសារត្រៀមត្រូវសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួន និងសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ និងការពារខ្លួនរបស់ភាគីម្ខាងទៀត។ ស្តែងចេញពីន័យនេះ អាចកំណត់ថា ការសរសេរអំពីសេចក្តីថ្លែងការណ៍ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនរបស់ភាគីម្ខាងទៀត គឺជាការសរសេរអំពីការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះអង្គហេតុដែលភាគី ម្ខាងទៀតបានអះអាង ឬ ជាការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះ អង្គហេតុនោះ។ ហើយយើងធ្វើការកត់សម្គាល់ពីចំណុចដែលយើងត្រូវសរសេរនោះមាន៖

- មធ្យោបាយតទល់៖ មានន័យថាភាគីក្នុងបណ្តឹងគួរសរសេររៀបរាប់ពីវិធីសាស្ត្រនៃការតទល់ ទៅនឹងការទាមទាររបស់ភាគីម្ខាងទៀត ដោយភាគីខាងដើមចោទ គួរសរសេររៀបរាប់ពីការតទល់ទៅនឹងមូលហេតុដែលអះអាងដោយភាគីខាងចុងចម្លើយ ដែលជាមូលហេតុនាំឱ្យមានការរំលត់សិទ្ធិរបស់ខ្លួន។
- មធ្យោបាយការពារ៖ មានន័យថាភាគីក្នុងបណ្តឹងគួរសរសេររៀបរាប់ពីវិធីសាស្ត្រនៃការការពារខ្លួនពីការចោទប្រកាន់របស់ភាគីម្ខាងទៀតដោយភាគីខាងចុងចម្លើយត្រូវសរសេររៀបរាប់ពីការការពារខ្លួន ទាក់ទងនឹងមូលហេតុដែលជាការចោទប្រកាន់របស់ភាគីខាងដើមចោទ ដែលបានសរសេរនៅក្នុងពាក្យបណ្តឹង។

ជារួមមក ឯកសារត្រៀម គឺជាឯកសារដែលគូភាគីដាក់ចូលក្នុងនីតិវិធី ក្នុងគោលបំណងធ្វើសេចក្តីថ្លែងការណ៍ទទួលស្គាល់ ឬ មិនទទួលស្គាល់អង្គហេតុដែលអះអាងដោយភាគីម្ខាងទៀត ក៏ដូចជារៀបចំមធ្យោបាយតទល់ ឬ ការពារខ្លួនផងដែរ។ ការដាក់ឯកសារត្រៀមនេះមានប្រយោជន៍ច្រើនដល់ដំណើរការនីតិវិធីដោយសារ

ការដាក់ឯកសារត្រៀមអាចផ្តល់នូវភាពងាយស្រួលដល់ភាគី ក្នុងការស្វែងយល់ពីការអះអាងរបស់ភាគីម្ខាង ក៏ដូចជាឆ្លើយតបទៅវិញ ហើយចំពោះតុលាការវិញ គឺមានភាពងាយស្រួលក្នុងការស្វែងយល់ពីការអះអាងរបស់ភាគីក៏ដូចជាឈានដល់ការកំណត់ចំណុចវិវាទ ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានឆាប់រហ័សផងដែរ។

**កថាភាគទី២. ដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

ដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រព្រឹត្តទៅបានដោយការកំណត់អំឡុងពេលនៃ កាលបរិច្ឆេទណាមួយ ឱ្យបានច្បាស់លាស់ និងសមរម្យដោយតុលាការផ្ទាល់ ដែលកាលបរិច្ឆេទនោះដែរត្រូវស្ថិត ក្នុងអំឡុងពេល៣០ថ្ងៃ[28] បន្ទាប់ពីថ្ងៃដែលភាគីបានដាក់ពាក្យបណ្តឹង ហើយភាគី ឬអ្នកតំណាងនៃភាគីទាំងសងខាងត្រូវមានវត្តមានតាមការកោះហៅរបស់តុលាការ ដើម្បីឱ្យដំណើរការនៃនីតិវិធី អាចប្រព្រឹត្តបានដោយ រលូន និងឆាប់រហ័ស។ ដូច្នេះ ដើម្បីឱ្យមានភាពកាន់តែងាយស្រួលក្នុងការស្វែងយល់ត្រង់ចំណុចនេះ យើងបាន ធ្វើការបែងចែកសកម្មភាពជា២ គឺសកម្មភាពរបស់តុលាការ(១) និងសកម្មភាពរបស់ភាគី(២)។

**១. សកម្មភាពរបស់តុលាការ**

តុលាការ គឺត្រូវបានទទួលអំណាចឯករាជ្យមួយ ដែលអំណាចនេះមានវិសាលភាពអនុវត្តលើគ្រប់រឿងក្តីទាំងអស់ ហើយអំណាចនេះដែរ ត្រូវបានប្រគល់ឱ្យដើម្បីការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋគ្រប់រូប ដូច្នេះហើយទើបតុលាការត្រូវតែបំពេញតួនាទីរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន និងត្រឹមត្រូវយុត្តិធម៌។ នៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការ គឺមានតួនាទីយ៉ាងសកម្ម និងសំខាន់ក្នុងដំណើរការនៃនីតិវិធីមួយនេះ ព្រោះតុលាការត្រូវអនុវត្តតួនាទីតាមអ្វីដែលច្បាប់បានកំណត់ នៅក្នុងអំឡុងពេលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលមានដូចខាងក្រោម៖

- **ការផ្សះផ្សា៖** នៅក្នុងរឿងក្តីរដ្ឋប្បវេណីទាំងអស់ បើតុលាការយល់ឃើញថាសមរម្យ នោះដំណាក់កាលនៃការសាកល្បងផ្សះផ្សារវាងភាគីទាំងពីរ នឹងត្រូវលើកឡើងដោយតុលាការ[29]។ ដោយមិនខ្វល់ថាការសាកល្បងលើការផ្សះផ្សានោះជោគជ័យ ឬ បរាជ័យទេ ព្រោះថាបើការផ្សះផ្សានោះបានផល ភាគីទាំងសងខាងនឹងចំណេញពេលវេលា និងថវិកា ដែលធ្លាប់តែខ្ជះខ្ជាយទៅលើការប្តឹងផ្តល់នេះ។
- **ការស្នើសុំឱ្យបំភ្លឺអង្គហេតុនៃចំណុចវិវាទ៖** បើការផ្សះផ្សារមិនបានជោគជ័យវិញ នោះតុលាការនឹងបន្តដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយធ្វើការស្នើសុំឱ្យភាគីទាំងពីរ បំភ្លឺអង្គហេតុដែលនាំឱ្យចំណុចវិវាទកើតមានឡើង។ ភាគីដើមបណ្តឹងត្រូវធ្វើសេចក្តីបំភ្លឺអំពីកម្មវត្ថុនៃការទាមទារ និងមូលហេតុដែលនាំឱ្យមានការទាមទារ រីឯភាគីចុងចម្លើយវិញ ត្រូវធ្វើសេចក្តីបំភ្លឺអំពីការឆ្លើយតបនឹង

[28] មាត្រា៨០ (ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[29] មាត្រា១០៤ (ការសាកល្បងផ្សះផ្សាក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ពាក្យបណ្តឹងរបស់ភាគីដើមបណ្តឹង និងមូលហេតុដែលទាមទារឱ្យតុលាការចេញសាលក្រមច្រានចោលការទាមទាររបស់ដើមបណ្តឹង។

- **ការស្នើសុំឱ្យដាក់ឯកសារត្រៀម៖** តុលាការនឹងធ្វើការបង្គាប់ឱ្យភាគីនីមួយៗ ដាក់ជូនឯកសារត្រៀមរបស់ខ្លួន ដែលនៅក្នុងឯកសារត្រៀមនោះមានដូចជាមធ្យោបាយតទល់ មធ្យោបាយការពារខ្លួន និងសេចក្តីថ្លែងការណ៍អំពីមធ្យោបាយទាំងនោះ ដែលមានបញ្ញត្តិក្នុងមាត្រា១០១ នៃក្រមរដ្ឋប្បវេណី។
- **ការបញ្ជាក់ពីអង្គហេតុដែលត្រូវបំភ្លឺ៖** មុននឹងបញ្ចប់ដំណាក់កាល នៃដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវប្រកាសបញ្ជាក់ពីអង្គហេតុ ដែលភាគីបានបំភ្លឺកន្លងមក ថាពិតជាត្រឹមត្រូវ និងមិនមានការកែប្រែអ្វីផ្សេងទៀតឡើយ ព្រោះក្រោមមូលហេតុមួយថា អង្គហេតុដែលភាគីបានបំភ្លឺក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ នឹងយកទៅប្រើការបន្តទៀតនាដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់[30]។

**កំណត់ហេតុ៖** រាល់កំណត់ហេតុ និងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនីមួយៗ ត្រូវបានកត់ត្រាដោយក្រឡាបញ្ជីនៃតុលាការនោះ[31]។

### ២. សកម្មភាពរបស់ភាគី

ក្នុងដំណាក់កាលនៃដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះដដែល ប៉ុន្តែមិនមែនជាការ ធ្វើសកម្មភាពរបស់តុលាការដូចមុនទេដោយលើកនេះយើងនឹងស្វែងយល់ពីសកម្មភាពរបស់ភាគីវិញម្តងថាតើភាគីមានសកម្មភាព ឬតួនាទីសំខាន់យ៉ាងដូចម្តេច? ព្រោះថាភាគីបណ្តឹងក៏ជាផ្នែកមួយដ៏សំខាន់ក្នុងដំណើរការនៃនីតិវិធីមួយនេះដែរ ពោលគឺបើមិនមានវត្តមានរបស់ភាគីបណ្តឹងណាម្ខាងចូលរួមទេ ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក៏មិនអាចប្រព្រឹត្តទៅបានដោយមានភាពរលូននោះដែរ ដូច្នេះ សកម្មភាព សិទ្ធិ និងតួនាទីរបស់ភាគី មានដូចចែងខាងក្រោមនេះ៖

- **ការមានសិទ្ធិបដិសេធលើការផ្សះផ្សា៖** ភាគីទាំងសងខាង មានសិទ្ធិក្នុងការឆ្លើយបដិសេធលើការផ្សះផ្សាដែលដាក់ចេញដោយតុលាការបាននៅក្នុងដំណាក់កាលនៃការផ្សះផ្សា ព្រោះថាតុលាការមានសិទ្ធិក្នុង ការលើកឡើងដំណាក់កាលនៃការផ្សះផ្សាជូនទៅដល់ភាគីទាំងសងខាងបានដែរ គឺទៅតាមឆន្ទានុសិទ្ធិ ដែលយល់ឃើញថាសមរម្យដូចដែលបានរៀបរាប់ខាងលើ ប៉ុន្តែតុលាការក៏ត្រូវយល់ស្របតាមការ សម្រេចចិត្តរបស់ភាគីដែរក្នុងករណីដែលភាគីមិនយល់ព្រមលើការផ្សះផ្សានោះ។

[30] មាត្រា១០៧ (ការបញ្ជាក់ពីអង្គហេតុដែលនឹងត្រូវបំភ្លឺជាអាទិ៍) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[31] មាត្រា១០៩ (កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

- **ការថ្លែងការណ៍អំពីអង្គហេតុៈ** ភាគីដើមបណ្តឹងក្តី ឬ ភាគីចុងចម្លើយក្តី សុទ្ធតែអាចមានសិទ្ធិក្នុងការអះអាងពីវិវាទ ដែលកើតមាននៅក្នុងអង្គហេតុជូនទៅតុលាការដោយលម្អិត ឬ ដោយសង្ខេបបាន ឬ ដែលមាននៅក្នុងពាក្យបណ្តឹងស្រាប់ បើយល់ថាចំបាច់ និងមានសារៈសំខាន់សម្រាប់រឿងក្តីរបស់ខ្លួន ដែលកំពុងដំណើរការក្នុងនីតិវិធីនេះ។
- **ការដាក់ឯកសារត្រៀមៈ** ភាគីត្រូវដាក់ឯកសារត្រៀមតាមការបង្គាប់របស់តុលាការ ប៉ុន្តែភាគីផ្ទាល់មានសិទ្ធិក្នុងការដាក់ឯកសារត្រៀមដោយចង់សរសេររៀបរាប់យ៉ាងដូចម្តេចក៏បានដែរ ឱ្យតែការនិយាយរៀបរាប់នៅក្នុងឯកសារត្រៀមនោះជាភស្តុតាងសំខាន់ និងមានតម្លៃហើយទាក់ទងនឹងមធ្យោបាយតទល់ មធ្យោបាយការពារខ្លួន ផ្អែកលើហេតុផល និងមូលហេតុសមរម្យស្របតាមច្បាប់។

## ផ្នែកទី២. ការទាញហេតុផលដោយផ្ទាល់មាត់

បន្ទាប់ពីដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានបញ្ចប់សព្វគ្រប់រួចរាល់អស់ ហើយនីតិវិធីបន្ទាប់ គឺជានីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ដោយនីតិវិធីនេះមានគោលបំណងឱ្យភាគីទាំងសងខាង មានឱកាសក្នុងការអះអាងសេចក្តីថ្លែងការណ៍ដែលខ្លួនបានធ្វើឡើង ដើម្បីការពារផលប្រយោជន៍របស់ពួកគេរៀងៗខ្លួន និងងាយស្រួលសម្រាប់តុលាការក្នុងការវិនិច្ឆ័យស្វែងរកការពិត ដោយស្តាប់ការអះអាងរបស់ភាគី។ ហើយនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ បើអាចត្រូវធ្វើឡើងជាសាធារណៈ ព្រោះថាការជម្រះរឿងក្តីជាសាធារណៈនេះគឺមានគោលដៅចង់បង្ហាញឱ្យឃើញពីការកាត់ក្តីដោយមានភាពយុត្តធម៌ពោលគឺមិនមានការកាត់ក្តីដោយលាក់កំបាំង ឬជាសម្ងាត់ឡើយ លើកលែងតែក្នុងករណីនៃការជម្រះក្តីជាសាធារណៈនេះ ធ្វើឱ្យប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ឬ មានចែងក្នុងច្បាប់ផ្សេងពីការមិនអនុញ្ញាតជាសាធារណៈ[32]។ ការសម្រេចចេញសាលក្រមលើរឿងក្តីមួយដោយតុលាការបាន ចាំបាច់ត្រូវធ្វើឡើងដោយឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់[33] ដូច្នេះដើម្បីងាយស្រួលក្នុងការសិក្សាស្វែងយល់ពីនីតិវិធីនៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់នេះ យើងបានធ្វើការបែងចែកចេញជា២សកម្មភាព គឺមុនអំឡុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់ (កថាភាគទី១) និងអំឡុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់(កថាភាគទី២)។

### កថាភាគទី១. មុនពេលនៃការទាញហេតុផលដោយផ្ទាល់មាត់

មុននឹងឈានទៅកាន់ដំណាក់កាលនៃការដំណើរការនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នេះ ថាតើក្នុងនាមជាភាគីបណ្តឹងគួរត្រៀមលក្ខណៈទុកជាមុនដូចម្តេចខ្លះ ដើម្បីជាប្រយោជន៍ដល់ការជម្រះក្តីដែលនឹងប្រព្រឹត្ត

[32] មាត្រា១១៥ (ការទាញហេតុផលដោយផ្ទាល់មាត់) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[33] មាត្រា១១៤ (ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់) កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ទៅក្នុងពេលខាងមុខ? យើងគួរសិក្សាស្វែងយល់ចំណុចមួយចំនួនដូចជាកាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ (១) និងភស្តុតាងត្រៀមសម្រាប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ (២)។

### ១. កាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់

ជាដំបូងក្នុងនាមជាភាគីត្រូវទទួលព័ត៌មានឱ្យបានច្បាស់លាស់ទាក់ទង នឹងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ព្រោះថាភាគីណាមួយមិនគួរអវត្តមានឡើយ ក្នុងកាលបរិច្ឆេទដ៏សំខាន់មួយនេះដែលអាចបណ្ដាលឱ្យប៉ះពាល់ដល់ដំណើរការនៃរឿងក្ដីបាន។ កាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវបានរៀបចំឡើងដោយតុលាការដោយកាលបរិច្ឆេទនោះ តុលាការគួរត្រូវរកពេលវេលាណាមួយឱ្យបានសមរម្យមួយសម្រាប់ភាគីទាំងសងខាងអាចមានវត្តមានចូលរួមបាន[34] ដើម្បីធានាឱ្យបានការអនុវត្តការកាត់ក្ដីដោយផ្អែកលើគោលការណ៍ចំពោះមុខសម្រាប់ភាគីទាំងសងខាងធ្វើការអះអាងពីការការពារផលប្រយោជន៍របស់ពួកគេ។

### ២. ភស្តុតាងត្រៀម

សម្រាប់ភស្តុតាងត្រៀមនេះក្នុងនាមជាភាគីយើងក៏ត្រូវត្រៀមឱ្យស្រេច ពីភស្តុតាងដែលនឹងត្រូវដាក់ជូនតុលាការ ត្រួតពិនិត្យដើម្បីឱ្យការជម្រះក្ដីរបស់ភាគីមានប្រៀបជាងភាគីម្ខាងទៀត ប៉ុន្តែត្រង់ចំណុចនៃការត្រៀមដាក់ភស្តុតាងនេះ ភាគីត្រូវប្រាកដឱ្យបានច្បាស់លាស់ថា ភស្តុតាងដែលត្រៀមនឹងដាក់ឱ្យតុលាការពិនិត្យ ត្រូវតែមានសារៈសំខាន់ និងជាភស្តុតាងដែលមានតម្លៃដែលអាចប្រើការជាប្រយោជន៍សម្រាប់ភាគីនៅក្នុងរឿងក្ដីបាន។ ដោយឡែកការត្រៀមភស្តុតាងលើកនេះ មានលក្ខណៈខុសពីឯកសារត្រៀមនៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលមានការអនុញ្ញាតត្រឹមតែភស្តុតាងជាឯកសារប៉ុណ្ណោះ ដោយការអនុញ្ញាតឱ្យដាក់ ភស្តុតាងនៅក្នុង ដំណាក់កាលនៃការដំណើរការនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់វិញមានដូចជា សាក្សី កោសល្យវិច័យ និងរួមទាំងភស្តុតាងជាឯកសារជាដើម។

## កថាភាគទី២. នៅក្នុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់

នៅក្នុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់ គឺជាពេលវេលាមួយដែលតុលាការ បានធ្វើការបើកសវនាការ ដើម្បីជំនុំជម្រះរឿងក្ដីដែលកំពុងមានវិវាទ និងដើម្បីចេញសាលក្រមអំពីភាពត្រឹមត្រូវនៃបណ្ដឹងនោះ ដោយអំឡុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់នោះ ត្រូវបានកំណត់ និងធ្វើការបែងចែកជាសកម្មភាពសំខាន់ៗ ចំនួន៣ ដែលមានដូចជាសេចក្ដីថ្លែងការណ៍របស់ភាគី(១) ការពិនិត្យភស្តុតាង(២) និងការវិនិច្ឆ័យរបស់ចៅក្រម (៣)។

[34] មាត្រា១១៥ (ការទាញហេតុផលដោយផ្ទាល់មាត់) កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### ១. សេចក្តីថ្លែងការណ៍របស់ភាគី

ភាគីនីមួយៗ ត្រូវធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួន ពីលទ្ធផលដែលទទួលបាននៅក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយសេចក្តីថ្លែងការណ៍នេះ ដែរភាគីអាចនិយាយរួមបញ្ចូលជាមួយអង្គហេតុ និងភស្តុតាងថ្មីបានបើមាន[35] ដើម្បីជាជំនួយសម្រាប់រឿងក្តីដែលកំពុងដំណើរការនោះ និងអាចប្រព្រឹត្តទៅបានដូចខាងក្រោមនេះ៖

- **សេចក្តីថ្លែងការណ៍ដោយសង្ខេបលើអង្គហេតុ៖** ភាគីទាំងសងខាងត្រូវធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និងដោយសង្ខេបលើអង្គហេតុ ដែលនាំឱ្យមានវិវាទកើតឡើង ជូនទៅកាន់អង្គតុលាការទាំងមូល ដោយភាគីខាងដើមចោទ ត្រូវធ្វើសេចក្តីថ្លែងការណ៍ពីមូលហេតុ និងកម្មវត្ថុនៃការទាមទារ រីឯភាគីខាងចុងចម្លើយត្រូវធ្វើសេចក្តីថ្លែងការណ៍ពីមូលហេតុ និងការច្រានចោលការទាមទាររបស់ភាគីម្ខាងទៀត។
- **សេចក្តីថ្លែងការណ៍លើភស្តុតាងបន្ថែម៖** ភាគីក៏ត្រូវថ្លែងការណ៍ពីការដាក់ស្នើសុំតុលាការនូវភស្តុតាងបន្ថែម ដែលជាជំនួយក្នុងរឿងក្តីផងដែរ។

### ២. ការពិនិត្យភស្តុតាង

ការពិនិត្យភស្តុតាងគឺជានីតិវិធីដើម្បីទទួលនូវធនធានភស្តុតាងដូចជាចម្លើយជាកសិណសាក្សី មតិយោបល់នៃកោសល្យវិច័យសេចក្តីថ្លែងការណ៍របស់សាមីភាគី ខ្លឹមសារដែលសរសេរក្នុងឯកសារលទ្ធផលនៃការពិនិត្យជាអាទិ៍ មកពីវិធីភស្តុតាងដូចជាសាក្សី អ្នកធ្វើកោសល្យវិច័យ សាមីភាគី ឯកសារ ឬវត្ថុដែលត្រូវបានពិនិត្យជាអាទិ៍[36]។ ដោយការត្រួតពិនិត្យភស្តុតាងនេះត្រូវធ្វើឡើងនៅក្នុងអំឡុងពេលនៃការទាញហេតុផលដោយផ្ទាល់មាត់ដំបូង និងព្រមទាំងតម្រូវ ឱ្យតុលាការ ត្រូវតែធ្វើឡើងដោយសមូហវិធី[37] ដែលមានដូចជា៖

- **ការសាកសួរសាក្សី៖** ការសាកសួរសាក្សីក៏ចាត់ទុកថាជាការពិនិត្យភស្តុតាងដែរព្រោះសាក្សី គឺជាភស្តុតាងរស់ ដែលអាចផ្តល់ចម្លើយនៅក្នុងអង្គហេតុបាន និងមានសារៈសំខាន់សម្រាប់ដំណើរការកាត់ក្តីក្នុងការស្វែងរកការពិត ដោយមុននឹងផ្តល់ចម្លើយសាក្សីត្រូវធ្វើសម្បថជាមុនសិន ព្រោះនេះជាវិធីតែមួយគត់ ដែលអាចធានាបានថា សាក្សីប្រាកដជាបានផ្តល់ចម្លើយពិត និងមិនក្លែងបន្លំអង្គហេតុ។
- **ការសាកសួរសាមីភាគី៖** ការសាកសួរភាគី គឺជាការពិនិត្យភស្តុតាងដែលធ្វើឡើងដោយតុលាការ ដើម្បីទទួលនូវធនធានភស្តុតាង ដោយយកសាមីភាគីមកធ្វើជាវិធីភស្តុតាង ដោយឱ្យធ្វើសេចក្តីថ្លែងការណ៍អំពីអង្គហេតុដែលខ្លួនបានជួបផ្ទាល់នោះតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់

[35] មាត្រា១១៦ (សេចក្តីថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលការទាញហេតុផលដោយផ្ទាល់មាត់) កថាខណ្ឌទី៣។ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[36] មាត្រា១២៤ (ការពិនិត្យភស្តុតាង)កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[37] មាត្រា១២៧ (ការពិនិត្យភស្តុតាងដោយសមូហវិធី)កថាខណ្ឌទី១ និងកថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

តុលាការ។ ការសាកសួរភាគី គឺជានីតិវិធីដែលមានគោលបំណងទទួលយកនូវធនធានភស្តុតាងដោយយកសាមីភាគីជាកម្មវត្ថុនៃការពិនិត្យ។ ខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់ភាគីក្នុងការសាកសួរភាគីនេះ គឺជាធនធានភស្តុតាង ហើយមានអត្ថន័យខុសគ្នានឹងការអះអាងរបស់ ភាគីក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ក្នុងការទាញហេតុផលដោយផ្ទាល់មាត់។ ឧទាហរណ៍ នៅក្នុងការសាកសួរភាគីទោះជាភាគីបានថ្លែងការណ៍ស្របទៅនឹងការអះអាងរបស់ភាគីម្ខាងទៀត ដែលធ្វើឱ្យខូចផលប្រយោជន៍របស់ខ្លួនក៏ដោយ ក៏សេចក្តីថ្លែងការណ៍នោះមិនមែនក្លាយទៅជាការសារភាពតាមផ្លូវបណ្តឹងទេគឺការថ្លែងការណ៍នោះគ្រាន់តែជាធនធានភស្តុតាងមួយដែលចៅក្រមនឹងធ្វើការវាយតម្លៃដោយជំនឿទុកចិត្តរបស់ខ្លួនប៉ុណ្ណោះ។ ម្យ៉ាងទៀតផ្ទុយទៅវិញក្រោមគោលការណ៍នៃការទាញហេតុផលទោះជាធ្វើសេចក្តីថ្លែងការណ៍អំពីអង្គហេតុណាមួយ នៅពេលសាកសួរភាគីក៏ដោយតែប្រសិនបើមិនបានអះអាងនៅក្នុងនីតិវិធីការទាញហេតុផលរបស់ភាគីទេ តុលាការមិនអាចយកមកគិតពិចារណាជាធនធានសម្រាប់ធ្វើការវិនិច្ឆ័យក្នុងការចេញសាលក្រមបានទេ។

- **កោសល្យវិច័យដោយតុលាការ៖** តុលាការនឹងធ្វើកោសល្យវិច័យដោយផ្អែកលើការស្នើសុំរបស់ភាគី និងត្រូវសួរយោបល់ទៅកាន់ភាគីម្ខាងទៀតពីការធ្វើកោសល្យវិច័យនោះ[38] ដើម្បីធ្វើការស្វែងរកភស្តុតាងបន្ថែមសម្រាប់ដាក់ឱ្យត្រួតពិនិត្យក្នុងសវនាការ។
- **ភស្តុតាងជាឯកសារ៖** ភស្តុតាងជាឯកសារត្រូវបានស្នើសុំត្រួតពិនិត្យដោយតុលាការឯកសារដែលសាមីភាគីមាន ឬ ឯកសារពីភាគីផ្សេងទៀត ដែលមិនមែនជាភាគីក្នុងបណ្តឹង ដែលតុលាការត្រូវធ្វើការស្នើសុំឱ្យភាគីដែលជាម្ចាស់ឯកសារ ផ្តល់ឯកសារនោះមកកាន់តុលាការបាន[39]។

## ៣. ការវិនិច្ឆ័យរបស់ចៅក្រម

បន្ទាប់ពីបានបញ្ចប់សេចក្តីថ្លែងការណ៍របស់ភាគី និងការពិនិត្យភស្តុតាងរួចរាល់ហើយតុលាការអាចអនុញ្ញាតឱ្យភាគីនីមួយៗ ធ្វើការទាញហេតុផលជាចុងក្រោយបាននៅមុនពេលដែលតុលាការបិទបញ្ចប់នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់នេះ[40] ។ ដោយសារថា ការទាញហេតុផលចុងក្រោយ គឺជាឱកាសដែលភាគីនីមួយៗអាចលើកឡើងនូវមតិចុងក្រោយរបស់ខ្លួន ពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទាររបស់ ដើមចោទ ដោយផ្អែកលើលទ្ធផលនៃការពិនិត្យភស្តុតាង ដូច្នេះ តុលាការគួរតែផ្តល់ឱកាសឱ្យភាគីនីមួយៗ លើកឡើងនូវការទាញហេតុផលចុងក្រោយរបស់ខ្លួន ឱ្យតែអាចធ្វើទៅបាន។ ព្រោះថាបន្ទាប់ពីបានឆ្លងកាត់ដំណាក់កាល

[38] មាត្រា១៤៣ (ការស្នើសុំឱ្យធ្វើកោសល្យវិច័យ)កថាខណ្ឌទី១ និងកថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[39] មាត្រា១៤៨ (ការស្នើសុំឱ្យធ្វើកោសលវិច័យជាឯកសារ) កថាខណ្ឌទី១ និងកថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[40] មាត្រា១១៦ (សេចក្តីថ្លែងការណ៍ពីលទ្ធផលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់) កថាខណ្ឌទី៥ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

នេះហើយភាគីនីមួយៗ អាចនឹងមានគំនិត និងការពិចារណាថ្មីដោយផ្អែកលើលទ្ធផលនៃរកការឃើញនៅក្នុងចំណុចវិវាទ។ បន្ទាប់ពីការទាញហេតុផលដោយផ្ទាល់មាត់បានចប់រួចរាល់ជាស្ថាពរ នោះតុលាការនឹងអាចបញ្ចេញ សកម្មភាពវិនិច្ឆ័យ១ ក្នុងចំណោម២ដែលមានដូចជា៖

→ ការប្រកាសដោយផ្ទាល់មាត់ពីសាលក្រមចុងក្រោយ ដោយផ្អែកលើលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងលទ្ធផលពិនិត្យភស្តុតាងកន្លងមក។

→ ដោយផ្អែកលើលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងលទ្ធផលពិនិត្យភស្តុតាងកន្លងមក មិនទាន់អាចឱ្យតុលាការចេញសាលក្រមចុងក្រោយបាន នោះតុលាការនឹងសម្រេចឱ្យធ្វើនីតិវិធីសម្រាប់ការទាញហេតុផលសារឡើងវិញ ដើម្បីរៀបចំចំណុចវិវាទ[41]។

[41] មាត្រា១១៦ (សេចក្តីថ្លែងការណ៍ពីលទ្ធផលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់) កថាខណ្ឌទី៤ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

# ជំពូកទី៣
# ការបញ្ចប់បណ្តឹង

# ជំពូកទី៣
# ការបញ្ចប់បណ្ដឹង

ជាគោលការណ៍ នីតិវិធីបណ្ដឹងត្រូវបញ្ចប់ដោយសាលក្រមចុងក្រោយ ក៏ប៉ុន្តែមូលហេតុនៃការបញ្ចប់នីតិវិធីបណ្ដឹងមានមិនត្រឹមប៉ុណ្ណោះទេ គឺអាចទទួលស្គាល់នូវការបញ្ចប់នីតិវិធីបណ្ដឹងដោយសកម្មភាពរបស់ភាគីបាន ។ នេះគឺជាខ្លឹមសារមួយភាគនៃគោលការណ៍នៃសិទ្ធិចាត់ចែង ហើយនេះក៏ជាការអនុវត្តតាមគោលការណ៍នៃស្វ័យភាពរបស់បុគ្គលឯកជននៅក្នុងនីតិវិធីបណ្ដឹងដែរ ។ ហើយការបញ្ចប់បណ្ដឹងនេះមានលក្ខណៈដាច់ដោយឡែកពីគ្នាហើយដើម្បីយល់ដឹងអំពីលក្ខណៈខុសប្លែកពីគ្នារវាងការបញ្ចប់បណ្ដឹងទាំងពីរនេះយើងនឹងធ្វើការរៀបរាប់ពីការបញ្ចប់បណ្ដឹងដោយសកម្មភាពភាគី(ផ្នែកទី១) ការបញ្ចប់បណ្ដឹងដោយសកម្មភាពតុលាការ(ផ្នែកទី២) និងនីតិវិធីនៃការអនុវត្តផ្សេងទៀត(ផ្នែកទី៣)។

## ផ្នែកទី១. ការបញ្ចប់បណ្ដឹងដោយសកម្មភាពភាគី

ការបញ្ចប់បណ្ដឹងដោយសកម្មភាពរបស់ភាគី មានន័យថាជាការបញ្ចប់បណ្ដឹងដោយគូភាគី ឬក៏ភាគីណាម្ខាងបានធ្វើសកម្មភាពមួយចំនួនដែលនាំឱ្យបណ្ដឹងនោះមានការរលត់ ឬត្រូវបានបញ្ចប់ ឬក្រោមហេតុផលផ្សេងទៀតដែលច្បាប់បានធ្វើការសន្មតថាបណ្ដឹងនោះបញ្ចប់បាន។ មានសេចក្ដីថាយល់ព្រមដោយមកដល់ចំណុចនេះ យើងនឹងធ្វើការសិក្សាស្វែងយល់ពីការបញ្ចប់ដោយភាគី(កថាភាគទី១) និងការបញ្ចប់បណ្ដឹងដោយស្វ័យប្រវត្តិ(កថាភាគទី២)។

### កថាភាគទី១. ការបញ្ចប់បណ្ដឹងដោយភាគី

ការបញ្ចប់បណ្ដឹងដោយភាគីមានន័យថា ជាការបញ្ចប់បណ្ដឹងដោយភាគីនីមួយៗ ឬភាគីណាម្ខាង ទទួលសារភាព ឬទទួលស្គាល់ការទាមទារ ឬលះបង់ការទាមទារ ដោយនៅក្នុងកថាខណ្ឌនេះ យើងនឹងស្វែង យល់ចំណុចនៃការបញ្ចប់បណ្ដឹងដោយភាគី ដែលមានដូចជា (១)ការដកពាក្យបណ្ដឹង (២)ការសះជាតាមផ្លូវបណ្ដឹង និង (៣)ការលះបង់ ឬ ការទទួលស្គាល់ការទាមទារ។

#### ១. ការដកពាក្យបណ្ដឹង

កាដកពាក្យបណ្ដឹងក្នុងរឿងក្ដីរដ្ឋប្បវេណី គឺជាសកម្មភាពដកមួយភាគ ឬ ទាំងស្រុង នូវពាក្យសុំទាមទារឲ្យចេញសាលក្រមតាមរយៈបណ្ដឹងដោយដើមចោទ។ មុននឹងឈានទៅរកភាពស៊ីជម្រៅនៃនីតិវិធីដកពាក្យបណ្ដឹង យើងខ្ញុំសូមបង្ហាញនូវនិយមន័យនៃបណ្ដឹងជាមុន "បណ្ដឹង" គឺជាសកម្មភាពដែលដើមចោទធ្វើការទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់មួយហេតុនេះហើយការដកពាក្យបណ្ដឹងនេះក៏ជាគោលការណ៍អាចធ្វើទៅបានតែដោយឆន្ទៈរបស់ដើមចោទតែម្ខាងប៉ុណ្ណោះ។ ការដកពាក្យបណ្ដឹងនេះមានន័យថាឈប់ប្ដឹងចុងចម្លើយវិញបាន ស្ថិតក្រោមហេតុផលដែលភាគីខ្លួនឯងផ្ទាល់យល់ឃើញថាត្រឹមត្រូវ និងសមរម្យ ព្រោះថានៅក្នុង

ក្រមរដ្ឋប្បវេណីយើងបានគោរពគោលការណ៍ស្វ័យភាពរបស់បុគ្គលនីមួយៗ ប៉ុន្តែការដកពាក្យបណ្តឹងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនេះដែរក៏ត្រូវគោរពតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ពោលគឺមិនអាចចេះតែដកតាមតែការយល់ឃើញរបស់ភាគីបាននោះទេ គឺត្រូវស្របតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- **ការដកពាក្យបណ្តឹងរបស់ដើមចោទ** ត្រូវមានអានុភាពលុះត្រាតែការដកពាក្យបណ្តឹងនេះបានដកមុនពេលចុងចម្លើយ បានដាក់ឯសារត្រៀម អំពីអង្គសេចក្តី មានន័យថា អំពីការទាមទាររបស់ដើមចោទ ឬបានធ្វើសេចក្តីថ្លែងការណ៍អំពីអង្គសេចក្តីក្នុងនីតិវិធីត្រៀមសម្រាប់ ការទាញហេតុផលដោយផ្ទាល់ មាត់ ដើម្បីដកពាក្យបណ្តឹង ចាំបាច់ត្រូវមានការយល់ព្រមពីចុងចម្លើយ ។
- **ការដកពាក្យបណ្តឹងរបស់ដើមចោទ** នឹងមានអានុភាពនៅពេលដែលចុងចម្លើយមិនបានប្តឹងតវ៉ាលើការដកពាក្យបណ្តឹងនោះ ក្នុងរយៈពេល២សប្តាហ៍ គិតចាប់ពីថ្ងៃដែលតុលាការ បានបញ្ជូនលិខិតអំពីការដកពាក្យបណ្តឹងនោះទៅចុងចម្លើយ[42]។
- **ចាត់ទុកថាដកពាក្យបណ្តឹង** មានអានុភាពលុះត្រាតែក្នុងករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀម សម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយ មិន បានដាក់ពាក្យសុំឱ្យតុលាការកំណត់កាលបរិច្ឆេទជាថ្មីទៀត ក្នុងអំឡុងពេល ១ (មួយ) ខែ ទេ នោះត្រូវចាត់ទុកថាបានដកពាក្យបណ្តឹង។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ពីរដងជាប់គ្នា[43]។

ក្រោមលក្ខខណ្ឌទាំងអស់នេះហើយ នាំឱ្យការដកពាក្យបណ្តឹងរបស់ភាគីដែលបានដាក់ពាក្យបណ្តឹងនោះមានអានុភាពស្របតាមច្បាប់កំណត់ និងជាលទ្ធផលមួយដែលនាំឱ្យបណ្តឹងនោះត្រូវបានបញ្ចប់ដែរ ឬហៅម៉្យាងទៀតថាការបញ្ចប់បណ្តឹងដោយការដកពាក្យបណ្តឹងរបស់ភាគី។

### ២. ការសះជាតាមផ្លូវបណ្តឹង

ការសះជាតាមផ្លូវបណ្តឹង គឺជាសកម្មភាពដែលដើមចោទ និង ចុងចម្លើយ ធ្វើសម្បទានគ្នាទៅវិញទៅមក ឬ ធ្វើការលះបង់រៀងៗខ្លួន នូវការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹង និងព្រមព្រៀងបញ្ចប់វិវាទនៅក្នុងនីតិវិធីបណ្តឹងហើយធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនោះ ដោយ

[42] មាត្រា២១៧ (ការដកពាក្យបណ្តឹង) កថាខណ្ឌទី៥ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[43] មាត្រា២១៨ (ការចាត់ទុកថាដកពាក្យបណ្តឹង) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ឯកភាពគ្នាចំពោះមុខតុលាការ[44]។ ដូចនេះការសះជា គឺជាមូលហេតុសំខាន់មួយនៃការបញ្ចប់បណ្ដឹងដូចទៅនឹងសាលក្រមដែរ។ ការសះជាតាមផ្លូវបណ្ដឹងអាចកើតមានឡើងនៅគ្រប់នីតិវិធីបណ្ដឹងរបស់តុលាការដូចជា៖

- ការសាកល្បងធ្វើការផ្សះផ្សា[45]។
- ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល[46]។
- ការផ្សះផ្សាលើបណ្ដឹង[47]។

ដូចនេះ ប្រសិនបើមានការសះជាគ្នារវាងភាគីនៃវិវាទហើយ តុលាការត្រូវតែកត់ត្រាចំណុចដែលសះជាគ្នានោះនៅក្នុងកំណត់ហេតុហើយកំណត់ហេតុនោះនឹងមានអានុភាពដូចគ្នាទៅនឹងសាលក្រមស្ថាពរផងដែរ[48]។ ចំពោះការសះជាតាមផ្លូវបណ្ដឹងនេះ គឺមានអត្ថប្រយោជន៍ខ្លាំងចំពោះការដោះស្រាយវិវាទនៅតុលាការ ដោយសារតែនីតិវិធីនៃការផ្សះផ្សារនេះ ធ្វើឱ្យចំណេញនូវពេលវេលា និង ភាគីទទួលបានផលប្រយោជន៍រៀងៗខ្លួន ដោយពុំបានមានការកាត់សេចក្ដីលម្អៀងទៅភាគីណាម្ខាង ពីព្រោះថាជាការព្រមព្រៀងផ្សះផ្សាគ្នារវាងភាគីផ្ទាល់ ហើយអាចរក្សានូវទំនាក់ទំនងល្អរវាងភាគីនៃវិវាទបានថែមទៀតផង។ ប្រសិនបើយើងធ្វើការប្រៀបធៀបការសះជានេះ ទៅនឹងការដោះស្រាយជម្លោះតាមរយៈការចេញសាលក្រមវិញ គឺការសះជានេះមានគុណសម្បត្តិច្រើនជាង។

### ៣. ការលះបង់ ឬ ការទទួលស្គាល់ការទាមទារ

ការលះបង់ ឬការទទួលស្គាល់ការទាមទារ គឺជាការលះបង់ការទាមទាររបស់ដើមចោទទៅលើចុងចម្លើយដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង ត្រង់ចំណុចកម្មវត្ថុនៃការទាមទារដែលបានធ្វើឡើងដោយភាគី ខាងដើមចោទ ឬជាការទទួលស្គាល់របស់ចុងចម្លើយលើការទាមទាររបស់ដើមចោទនៅក្នុងពាក្យបណ្ដឹង។ ការលះបង់ ឬការទទួលស្គាល់ការទាមទាររបស់ភាគីដើមចោទ ឬ ចុងចម្លើយភាគីណាម្ខាងត្រូវថ្លែងការណ៍ដោយផ្ទាល់មាត់ក្នុងពេលដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការត្រៀមហេតុផល ឬ នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់[49]។

## កថាភាគទី២. ការបញ្ចប់បណ្ដឹងដោយស្វ័យប្រវត្តិ

ការបញ្ចប់បណ្ដឹងដោយស្វ័យប្រវត្តិនៅត្រង់នេះ ក៏បានកើតចេញពីសកម្មភាពរបស់ភាគីដែរ មានន័យថាបណ្ដឹងនឹងត្រូវរលត់ ឬបញ្ចប់បើភាគីនោះ លែងមានវត្តមានសម្រាប់បន្តការដំណើរការក្ដី ដោយសារមរណភាពរបស់ភាគី(១) និង (ព្យាកុលភាព)ការរួមបញ្ចូលនូវឋានៈរបស់ភាគីទាំងសងខាង(២) ។

[44] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៨ ទំព័រ១៦៤ កថាខណ្ឌទី៥ កថាខណ្ឌទី១

[45] មាត្រា៩៧ (ការសាកល្បងធ្វើការផ្សះផ្សា) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[46] មាត្រា១០៤ (ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[47] មាត្រា២២០ (ការផ្សះផ្សាបណ្ដឹង) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[48] មាត្រា២២២ (អានុភាពនៃកំណត់ហេតុស្ដីពីការសះជា ជាអាទិ៍) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[49] មាត្រា២២១ (ការលះបង់ ឬការទទួលស្គាល់ការទាមទារ) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

**១. មរណភាពរបស់ភាគីណាមួយ**

នៅក្នុងករណីដែលភាគីណាម្ខាងបានទទួលមរណភាព ហើយគ្មានអ្នកទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនោះ។ តាមធម្មតាទោះជាភាគីណាម្ខាងបានទទួលមរណភាពក៏ដោយសន្តតិជន ជាអាទិ៍ នឹងទទួលបន្តនូវនីតិវិធីនៃបណ្តឹង (មាត្រា១៧៣ កថាខណ្ឌទី១ និងទី២) ដូច្នេះនីតិវិធីនៃបណ្តឹងនោះមិនត្រូវបានបញ្ចប់ទេ។ ក៏ប៉ុន្តែអាចមានករណីដែលពុំមានអ្នកដែលត្រូវទទួលបន្តនូវនីតិវិធីនៃបណ្តឹងដោយសារលក្ខណៈនៃសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង។ ឧទាហរណ៍ ករណីបណ្តឹងលែងលះ បើភាគីម្ខាងនៅក្នុងបណ្តឹងលែងលះត្រូវបានទទួលមរណភាព នោះមិនអាចមានភាគីផ្សេងទៀត ឬ អ្នកតំណាងតាមផ្លូវបណ្តឹងណាមួយ មកលែងលះជំនួសឱ្យភាគីស្លាប់ទេ។

**២. ការរួមបញ្ចូលនូវឋានៈរបស់ភាគីទាំងសងខាង (ព្យាកុលភាព)**

ករណីដែលភាគី បានរលត់ដោយសារការរួមបញ្ចូលនៃនូវឋានៈហើយសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង នោះត្រូវធ្លាក់ទៅលើបុគ្គលតែម្នាក់ ។ នេះគឺជាករណីដែល ដើមចោទ និង ចុងចម្លើយ បានក្លាយទៅជាបុគ្គលតែម្នាក់ ដោយសារតែភាគីណាម្ខាងបានទទួលបន្តនូវឋានៈតាមផ្លូវបណ្តឹង របស់ភាគីម្ខាងទៀត ដោយសារសន្តតិកម្ម ឬ ការរួមបញ្ចូលនូវឋានៈ។

**កំណត់ចំណាំ៖** ក្នុងករណីទាំងនេះ គ្មានន័យអ្វីទៀតនឹងបន្តនីតិវិធីនៃបណ្តឹងទេដូច្នេះហើយបណ្តឹងនឹងត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ ។ ក៏ប៉ុន្តែ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់នូវការបញ្ចប់នៃនីតិវិធីបណ្តឹងនោះតុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារថា "បណ្តឹងត្រូវបានបញ្ចប់ដោយសារមរណភាពនៃភាគី" ឬ "បណ្តឹងត្រូវបានបញ្ចប់ដោយសារតែសិទ្ធិ និង កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនោះ ត្រូវធ្លាក់ទៅលើបុគ្គលតែម្នាក់" ។

## ផ្នែកទី២. ការបញ្ចប់បណ្តឹងដោយសកម្មភាពតុលាការ

ការបញ្ចប់បណ្តឹងដោយសកម្មភាពតុលាការជាទូទៅត្រូវបានគេដឹងថាមាន ៣ដំណាក់កាលសំខាន់ៗ ដូចជា ទី១នីតិវិធីនៃការដាក់ពាក្យបណ្តឹង ទី២នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងទី៣នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ដោយរួមបញ្ចូលវិធីសាស្ត្រដែលបានរៀបរាប់ខាងលើ តុលាការនឹងធ្វើការបញ្ចប់ បណ្តឹងដោយការប្រកាសសាលក្រមចុងក្រោយមួយ។ ដោយហេតុថានៅក្នុងនីតិវិធីនៃការដាក់ពាក្យបណ្តឹងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់យើងបានសិក្សា និងឆ្លងកាត់ខាងលើរួចហើយ ដូច្នេះយើងនឹងធ្វើការស្វែងយល់ពីសកម្មភាពមួយចុងក្រោយរបស់តុលាការវិញម្តង គឺការប្រកាសសាលក្រម (កថាភាគទី១) និងការអនុវត្តដោយបង្ខំ(កថាភាគទី២)។

### កថាភាគទី១. ការចេញសាលក្រម

ការប្រកាសសាលក្រមត្រូវធ្វើឡើងដោយការប្រកាសរបស់តុលាការ បន្ទាប់ពីបានឆ្លងកាត់នូវនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់រួចមក ដោយសាលក្រមនោះនឹង

មានអានុភាពបន្ទាប់ពីបានប្រកាស[50]។ ដូច្នេះមានចំណុចពិសេសមួយចំនួនដែលទាក់ទងនឹងការប្រកាសសាលក្រមដោយតុលាការ ដែលយើងគួរសិក្សាស្វែងយល់បន្ថែមដូចជាប្រភេទនៃសាលក្រម(១) និងការប្រកាសសាលក្រមចុងក្រោយ(២)។

**១. ប្រភេទនៃសាលក្រម**

មុននឹងឈានចូលទៅកាន់ការប្រកាសសាលក្រមដោយតុលាការ យើងគួរសិក្សាស្វែងយល់ប្រភេទនៃសាលក្រមជាមុនសិន ដែលសាលក្រមនៅក្នុងរឿងក្តីរដ្ឋប្បវេណីនីមួយៗ សុទ្ធតែមានគោលបំណង និងខ្លឹមសារផ្សេងៗគ្នាទៅតាមករណីនៃបណ្តឹងនីមួយៗ ដោយការសម្រេចចេញសាលក្រមប្រភេទណាមួយ គឺត្រូវបានចៅក្រមជាអ្នកសម្រេចដោយផ្អែកតាមការយល់ឃើញក្នុងរឿងក្តី ឬក៏អាចហៅម៉្យាងទៀតថា ការសម្រេចដោយផ្អែកតាមឆន្ទានុសិទ្ធិរបស់ចៅក្រម។ ដូច្នេះ ថាតើសាលក្រមមានប៉ុន្មានប្រភេទ? អ្វីខ្លះ? ក្រមមិនបានធ្វើការរៀបរាប់ ឬ ផ្តល់ចម្លើយត្រង់ៗ សម្រាប់សំណួរមួយនេះទេ ក៏ប៉ុន្តែគេសង្កេតឃើញថានៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមានកំណត់ពីសាលក្រមដែលតុលាការត្រូវប្រកាស មានលក្ខណៈផ្សេងៗគ្នាតាមមាត្រានីមួយៗ ស្តីពីសាលក្រមនោះ។ ដូច្នេះ គេក៏បានសន្និតថា សាលក្រមក្នុងរឿងក្តីរដ្ឋប្បវេណីមានច្រើនប្រភេទគឺដូចជា៖

- **សាលក្រមចុងក្រោយ៖** គឺជាសាលក្រមដែលធ្វើឡើងដោយតុលាការ បន្ទាប់ពីបានឆ្លងកាត់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាងកន្លងមក[51]។ សាលក្រមនេះជាសាលក្រមដែលបិទបញ្ចប់រឿងក្តីនៅសាលាដំបូង ប៉ុន្តែបើភាគីនីមួយៗមិនពេញចិត្តនឹងសាលក្រមចុងក្រោយរបស់តុលាការសាលាដំបូង ឬ ការជម្រះក្តីលើកទី១នេះទេ ពួកគេអាចធ្វើបណ្តឹងទៅតុលាការជាន់ខ្ពស់ពីការមិនសុខចិត្តលើសាលក្រមចុងក្រោយនេះជាបន្តបាន[52]។
- **សាលក្រមរបៀប៖** សាលក្រមដែលគ្មានអានុភាពបញ្ចប់បណ្តឹងទេ ដោយគ្រាន់តែជាសេចក្តីសម្រេចចំពោះចំណុចដែលជាលក្ខខណ្ឌសម្រាប់ការចេញសាលក្រមចុងក្រោយ។ សាលក្រមប្រភេទនេះមានគោលបំណងរៀបចំ និងសម្រួលធ្វើឲ្យការវិនិច្ឆ័យលើបណ្តឹងមានសណ្តាប់ធ្នាប់ ហើយតុលាការអាចចេញសាលក្រមនេះបានតែចំពោះចំណុចដែលត្រូវនឹងគោលបំណងនោះតែប៉ុណ្ណោះ ។យោងមាត្រា ១៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំណុចដែលអាចចេញសាលក្រមចាត់របៀបបានមាន៤ គឺ៖
  - → **អត្ថិភាពនៃការទាមទារក្នុងករណីមានវិវាទអំពីអត្ថិភាព និងចំនួនទឹកប្រាក់នៃការទាមទារ៖** មានន័យថា តុលាការអាចចេញសាលក្រមរបៀបបាន លើការវិនិច្ឆ័យវិវាទអំពីអត្ថិភាពនៃ សិទ្ធិជាមុនសិន។

[50] មាត្រា១៨៦ (កំណើតអានុភាពនៃសាលក្រម) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[51] មាត្រា១៨០ (សាលក្រមចុងក្រោយ) កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[52] មាត្រា២៦០ (សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បានជាអាទិ៍) កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

→ **មធ្យោបាយតទល់ ឬការពារខ្លួន ដែលអាចវិនិច្ឆ័យជាឯកភាពបាន៖** មធ្យោបាយដែលអាចវិនិច្ឆ័យជាឯកភាពបានមានន័យថា មធ្យោបាយនោះមានអានុភាពគតិយុត្ត ដែលអាចធ្វើការអះអាងបាននៅក្នុងរឿងក្តី។

→ **អត្ថិភាព ឬនត្ថិភាពនៃលក្ខខណ្ឌបណ្តឹង៖** ចំណុចនេះតុលាការគួរចេញសាលក្រមរបៀបបើលក្ខខណ្ឌនៃបណ្តឹងមានភាពមិនត្រឹមត្រូវ ដូចជាដែនសមត្ថកិច្ចនៃសាលាជម្រះក្តី ឬ អសមត្ថភាពក្នុងការធ្វើបណ្តឹងរបស់ភាគីជាដើម ដែលជាមូលហេតុនាំឱ្យការជម្រះក្តី នៅតុលាការនោះ មិនមានអានុភាពតាមផ្លូវច្បាប់។

→ **ហេតុដែលទាក់ទងនឹងការបញ្ចប់បណ្តឹង៖** លក្ខខណ្ឌចុងក្រោយនេះ គឺជាសាលក្រមរបៀប ដែលតុលាការចេញ ដើម្បីបញ្ចប់បណ្តឹង ឬក៏អាចហៅម្យ៉ាងទៀតថា សាលក្រមរបៀបនៃ ការបញ្ចប់បណ្តឹងដោយតុលាការសម្រេចចេញសាលក្រមនេះក្នុងករណីដែលភាគីបាន ដកពាក្យបណ្តឹង មានការសះជាតាមផ្លូវបណ្តឹង ឬមរណភាពរបស់ភាគីជាដើម[53]។

- **សាលក្រមចំពោះមុខ៖** គឺជាប្រភេទនៃសាលក្រមមួយដែលចេញ និងប្រកាសចំពោះមុខដើមចោទ ឬចុងចម្លើយ ឬចំពោះមុខអ្នកតំណាងរបស់ដើមចោទ ឬ ចុងចម្លើយ ក្នុងករណីដែលភាគី ឬ អ្នកតំណាងមានវត្តមាននៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។

- **សាលក្រមកំបាំងមុខ៖** គឺជាប្រភេទនៃសាលក្រមដែលចេញ និងប្រកាសកំបាំងមុខដើមចោទ ឬ ចុងចម្លើយ ក្នុងករណីដែលដើមចោទ ឬចុងចម្លើយមិនបានបង្ហាញខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់លើកទីមួយ និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ មានន័យថានៅពេលដែលដើមចោទ ឬ ចុងចម្លើយបានទទួលការកោះហៅពីតុលាការឲ្យចូលក្នុងនីតិវិធីត្រៀមសម្រាប់ការទាយហេតុផលលើកទី១ ហើយដើមចោទ ឬ ចុងចម្លើយមិនបានចូលរួមតាមកាលបរិច្ឆេទកំណត់នោះតុលាការអាចបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយបើដើមចោទ ឬ ចុងចម្លើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់នេះទៀត នោះតុលាការនឹងច្រានចោលការទាមទារ ឬចាត់ទុកថាបានសារភាព ដោយចេញសាលក្រមកំបាំងមុខ។ នៅក្នុងក្រមនីតិរដ្ឋប្បវេណីឆ្នាំ ២០០៦ ក៏បានចែងអំពីរយៈពេលប្តឹងផងដែរ គឺត្រូវធ្វើឡើងក្នុងរយៈពេល២ (ពីរ) សប្តាហ៍ដោយគិតចាប់ពីថ្ងៃដែលទទួលបានការបញ្ជូនសាលក្រមកំបាំងមុខនោះ[54]។ អំឡុងពេលនេះពុំអាចពន្យារបានឡើយ។

[53] មាត្រា១៨១ (សាលក្រមរបៀប) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[54] មាត្រា២០៤ (បណ្តឹងទាស់) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

### ២. ការប្រកាសសាលក្រមចុងក្រោយ

ការប្រកាសសាលចុងក្រោយត្រូវធ្វើការប្រកាសដោយតុលាការផ្ទាល់ បន្ទាប់ពីបានស្តាប់ការបកស្រាយ និងការអះអាងពីការ ទាញហេតុផលដោយផ្ទាល់មាត់របស់ភាគីរួចមក ក៏ដូចជាបានត្រួតពិនិត្យភស្តុតាងដោយសាកសួរសាក្សី សាមីភាគី ការពិនិត្យភស្តុតាងជាឯកសារ និងកោសល្យវិច័យជាដើម[55]។

សាលក្រមចុងក្រោយនេះ អាចមានអត្ថន័យ២ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីនៅពេលប្រកាស គឺទី១ សាលក្រមចុងក្រោយដែលមានអត្ថន័យទទួលស្គាល់ការទាមទាររបស់ដើមចោទ និងទី២ សាលក្រមចុងក្រោយដែលមានអត្ថន័យច្រានចោលនូវការទាមទាររបស់ដើមចោទដែលតុលាការសម្រេចសេចក្តីនេះឡើង ផ្អែកតាមអំណះអំណាង និងភស្តុតាងដែលភាគីនីមួយៗបានថ្លែងការណ៍កន្លងមក និងក៏ជាការវិនិច្ឆ័យ ការយល់ឃើញ ដែលកើតចេញពីឆន្ទានុសិទ្ធិរបស់តុលាការដែរ។

សាលក្រមចុងក្រោយនឹងមានអានុភាពចូលជាសាលក្រមស្ថាពរក្នុងអំឡុងពេលមួយខែ បើភាគីមិនបានធ្វើបណ្តឹងឧបាស្រ័យទៅកាន់តុលាការជាន់ខ្ពស់ទេនោះ[56] ហើយសាលក្រមដែលចូលជាស្ថាពរនេះ នឹងវិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ សាលក្រមស្ថាពរមានអានុភាពចំពោះបុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ ៖

- ភាគី
- តតិយជន ក្នុងករណីដែលភាគីធ្វើជាដើមចោទ ឬ ចុងចម្លើយនៃបណ្តឹងជំនួស តតិយជននោះ ។
- បុគ្គលដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ច ពីអ្នកដែលបានកំណត់ក្នុងចំណុច ទាំងពីរខាងលើនេះក្រោយពីបណ្តឹងត្រូវបានចាត់ការ ។
- បុគ្គលដែលកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការទាមទារ សម្រាប់ផលប្រយោជន៍ របស់បុគ្គលដែលបានកំណត់ក្នុងចំណុចទាំងបីខាងលើនេះ[57]។

### កថាភាគទី២. ការអនុវត្តដោយបង្ខំ

មូលហេតុដែលយើងបានសរសេរនូវចំណុចការអនុវត្តបង្ខំនេះឡើង ក្នុងគោលបំណងរំលេចពីនីតិវិធីដែលត្រូវបន្តពេលដែលភាគីឈ្នះក្តីត្រូវអនុវត្ត។ ការអនុវត្តដោយបង្ខំ គឺជានីតិវិធីដែលតុលាការក៏ដូចជាច្បាប់បានអនុញ្ញាតឱ្យភាគីដែលមានសិទ្ធិ ទាមទារ ឬសិទ្ធិប្រាតិភោគអាចធ្វើការទាមទារពីភាគីម្ខាងទៀត ដោយអនុវត្តការទាមទារដោយបង្ខំបាន [58] ដើម្បីសម្រេចទទួលបានសិទ្ធិ ឬ ការទាមទារដែលធ្វើឡើងដោយការស្នើសុំមកកាន់

[55] មាត្រា១៨០ (សាលក្រមចុងក្រោយ) កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[56] មាត្រា២៦៤ (អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍) កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[57] មាត្រា១៩៨ (វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[58] មាត្រា៣៣៤ (គោលគំនិត) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

តុលាការរបស់ភាគីដែលមានសិទ្ធិ ក្នុងករណីដែលភាគីម្ខាងទៀតនោះមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ដូច្នេះ ដើម្បីស្វែងយល់ និងសិក្សាបន្ថែមការអនុវត្តដោយបង្ខំ យើងនឹងសិក្សាចំណុចមួយចំនួន ដូចជាលក្ខខណ្ឌចំពោះ ដូចជារបៀបដាក់ពាក្យសុំអនុវត្តដោយបង្ខំ(១) លក្ខខណ្ឌចំពោះការអនុវត្តដោយបង្ខំ(២) និងកិច្ចការនៅពេល ដែលអនុវត្តដោយបង្ខំ (៣)។

## ១. របៀបដាក់ពាក្យសុំអនុវត្តដោយបង្ខំ

ដើម្បីសុំអនុវត្តដោយបង្ខំយើងត្រូវដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ហើយពាក្យសុំត្រូវធ្វើឡើងជាលាយ លក្ខណ៍អក្សរ ។ នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវមានសរសេរបញ្ជាក់នូវចំណុចសំខាន់ៗ ដូចខាងក្រោម នេះ ហើយត្រូវភ្ជាប់ជាមួយនឹងលិខិត ចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តៈ

- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។
- សញ្ញាណនៃលិខិតអនុវត្ត ។
- សេចក្តីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល ។
- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និង វិធីអនុវត្តដោយបង្ខំដែលម្ចាស់ បំណុលនៃ ការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ។
- ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំ តាមការអនុវត្ត ជំនួស ឬ វិធានបង្ខំដោយប្រយោល ។

ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តសុំឱ្យអនុវត្តដោយបង្ខំចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែល បាន សរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់អំពី សេចក្តីសុំ និងទំហំនៃសេចក្តីសុំនោះក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ[59]។

## ២. លក្ខខណ្ឌចំពោះការអនុវត្តដោយបង្ខំ

លក្ខខណ្ឌចំពោះការអនុវត្តដោយបង្ខំ ឬការទាមទារឱ្យអនុវត្តដោយបង្ខំ គឺមានចែងក្នុងច្បាប់ និងធ្វើយ៉ាង ណាឱ្យស្របតាមច្បាប់ ពោលគឺបង្ការកុំឱ្យមានការប៉ះពាល់ដល់សិទ្ធិបុគ្គលក្នុងពេលដែលអនុវត្តដោយបង្ខំ ព្រោះ ថាបើកាលណាការអនុវត្តច្បាប់មិនបានត្រឹមត្រូវទេនោះនឹងនាំឱ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និង សិទ្ធិមនុស្ស។ ហើយសញ្ញាណទូទៅ និងលក្ខខណ្ឌមួយចំនួនដែលត្រូវដឹងពីការអនុវត្តដោយបង្ខំនេះមានដូច ខាងក្រោមៈ

[59] មាត្រា៣៤៩ (របៀបដាក់ពាក្យសុំអនុវត្តដោយបង្ខំ) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

- ការអនុវត្តដោយបង្ខំ ត្រូវបានធ្វើឡើងដោយតុលាការអនុវត្ត ឬ អាជ្ញាសាលាដោយផ្អែកតាមការស្នើសុំរបស់ភាគីដែលទាមទារនោះ[60]។
- ការអនុវត្តដោយបង្ខំ គឺត្រូវអនុវត្តដោយរដ្ឋប្បវេណីមាត្រា៣៥០ កថាខណ្ឌទី២ ដើម្បីស្វែងយល់ពីលិខិតអនុវត្ត)។
- ការអនុវត្តដោយបង្ខំ មានវិសាលភាពលើភាគី ដែលមានចុះឈ្មោះ ឬនាមករណ៍នៅក្នុងលិខិតអនុវត្ត ឬ បុគ្គលដែលទទួលបន្តសិទ្ធិ ឬកាន់កាប់កម្មវត្ថុនៃការទាមដែលបានកំណត់តាមច្បាប់[61]។

### ៣. កិច្ចការនៅពេលដែលអនុវត្តដោយបង្ខំ

កិច្ចការនៅពេលដែលអនុវត្តដោយបង្ខំត្រូវគោរពតាមលក្ខខណ្ឌ និងនីតិវិធីដែលមានចែងក្នុងច្បាប់ដែរជាពិសេសក្រមនីតិវិធីរដ្ឋប្បវេណី ព្រោះក្រមនេះមានចែងពីកាតព្វកិច្ចរបស់អ្នកមានសមត្ថកិច្ច និងរបៀបរបបនៃការអនុវត្តនីតិវិធីមួយនេះដែលមានដូចតទៅ៖

- បើក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវបានរារាំង អាជ្ញាសាលាអាចប្រើប្រាស់កម្លាំងសមត្ថកិច្ចបានដូចជាកម្លាំងនគរបាលជាដើម[62]។
- បើពេលទៅដល់កន្លែងចុះសង្កេតការតែបែរជាមិនជួបម្ចាស់កន្លែង ឬ គ្មាននរណាម្នាក់នៅចាំកន្លែងនោះទេ អាជ្ញាសាលាចាំបាច់ត្រូវរកមេភូមិ ឬ មេឃុំ ឬ មន្ត្រីដែលប្រចាំការនៅទីនោះ មកធ្វើជាសាក្សីក្នុងការអនុវត្តនីតិវិធីនេះ[63]។

**ចំណាំ៖** បើកាលបរិច្ឆេទនៃការអនុវត្តត្រូវនឹងថ្ងៃសម្រាក អាជ្ញាសាលាត្រូវសុំការអនុញ្ញាតពីតុលាការដែលបង្គាប់ឱ្យចុះអនុវត្តនោះ ឬ សាលាដំបូងដែលខ្លួនស្ថិតនៅ និងត្រូវបង្ហាញលិខិតអនុញ្ញាតនោះដែរ[64]។

## ផ្នែកទី៣. នីតិវិធីនៃការអនុវត្តផ្សេងទៀត

ក្រៅពីនីតិវិធីនៃការប្រកាសសាលក្រមចុងក្រោយ ឬការអនុវត្តសាលក្រមស្ថាពរ ក្រមនីតិវិធីរដ្ឋប្បវេណីក៏មានចែងនីតិវិធីផ្សេងទៀត ដើម្បីធ្វើការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធិភាពលើវិវាទរដ្ឋប្បវេណីដែរ ព្រោះថាទោះបីជាសាលក្រមត្រូវបានតុលាការសម្រេចឱ្យអនុវត្តហើយក្តី ក៏នៅមានឧបសគ្គមួយចំនួនដែលបង្កឱ្យមានការរាំងស្ទះដល់ការអនុវត្តដែរ។ ដូច្នេះហើយទើបច្បាប់រដ្ឋប្បវេណីបានបង្កើតឱ្យមានវិធានការការពារមួយចំនួនដើម្បីអនុវត្តកុំ

---

[60] មាត្រា៣៣៦ (ស្ថាប័នអនុវត្ត) កថាខណ្ឌទី២ ក្រមនីតីវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[61] មាត្រា៣៥១ (វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[62] មាត្រា៣៣៨ (ការធានាក្នុងការបំពេញមុខងារនាទីរបស់អាជ្ញាសាលា ជាអាទិ៍) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[63] មាត្រា៣៣៩ (អ្នកសង្កេតការណ៍) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[64] មាត្រា៣៤០ (ការអនុវត្តនៅថ្ងៃឈប់សម្រាកឬពេលយប់) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ឱ្យមានការកកស្ទះដល់ការអនុវត្តច្បាប់ដោយការអនុវត្តនោះមាននីតិវិធីផ្សេងៗ មួយចំនួនដូចជានីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច(កថាភាគទី១) និង នីតិវិធីដាស់តឿន(កថាភាគទី២) ។

### កថាភាគទី១. នីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច

#### ១. គោលគំនិត និងកម្មវត្ថុនៃនីតិវិធីបណ្តឹងចំនួនទឹកប្រាក់តិច

នីតិវិធីបណ្តឹងចំនួនទឹកប្រាក់តិច ដែលជានីតិវិធីពិសេសដើម្បីដោះស្រាយឱ្យបានឆាប់រហ័សនូវវិវាទចំនួនទឹកប្រាក់តិចដែលមានតម្លៃសេដ្ឋកិច្ចទាបតាមនីតិវិធីសង្ខេប[65]។ គោលគំនិតនៃការបង្កើតនីតិវិធីនៃរឿងក្តីទឹកប្រាក់តិចគឺការបង្កើតនូវនីតិវិធីដោះស្រាយឱ្យបានងាយស្រួល និងឆាប់រហ័សនូវវិវាទស្តីពីការបង់ទឹកប្រាក់ចំនួនតិចដែលកើតឡើងច្រើននៅក្នុងជីវភាពសង្គមប្រជាពលរដ្ឋរស់នៅ ដើម្បីឱ្យប្រជាពលរដ្ឋធម្មតាអាចយករឿងក្តីដែលជាប់ជិតស្និទ្ធនឹងជីវភាព របស់ខ្លួនឡើងតុលាការ និងទទួលនូវការសង្គ្រោះសិទ្ធិរបស់ខ្លួន។ យោងតាមគោលគំនិតនេះ ក្រមនីតិវិធីរដ្ឋប្បវេណីបានបង្កើតបញ្ញត្តិពិសេសជាច្រើនដែលផ្សេងពីនីតិវិធីបណ្តឹងធម្មតា ដើម្បីឱ្យអាចទទួលនូវទាមទារសិទ្ធិរបស់ខ្លួននៅតុលាការបានដោយចំណាយពេលវេលា និងសោហ៊ុយដែលសមស្របនឹងតម្លៃសេដ្ឋកិច្ចនៃរឿងក្តីចំពោះនីតិវិធីបណ្តឹងចំនួនទឹកប្រាក់តិច ។

**កំណត់សម្គាល់៖** រឿងក្តីដែលអាចប្រើនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិចបានគឺរឿងក្តីដែលមានគោលបំណងទាមទារឱ្យបង់ជាប្រាក់ ហើយដែលចំនួនទឹកប្រាក់នៃកម្មវត្ថុនៃបណ្តឹងនោះមិនលើសពី១ លានរៀលឡើយ[66]។

#### ២. ការដាក់ពាក្យបណ្តឹង

នៅក្នុងនីតិវិធីនៃបណ្តឹងធម្មតា ការដាក់ពាក្យបណ្តឹងត្រូវធ្វើដោយដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅតុលាការ (មាត្រា ៧៥ កថាខណ្ឌទី១) ប៉ុន្តែក្នុងនីតិវិធីបណ្តឹងនៃរឿងក្តីចំនួនទឹកប្រាក់តិចអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់បានដែរ[67]។ ក្នុងករណីនេះក្រឡាបញ្ជីត្រូវកត់ត្រានូវសេចក្តីថ្លែងការណ៍ ដោយផ្ទាល់មាត់របស់ដើមចោទក្នុងកំណត់ហេតុហើយកំណត់ហេតុនេះត្រូវបានចាត់ទុកថាជាពាក្យបណ្តឹង[68]។ នេះគឺដើម្បីឱ្យប្រជាជនដែលមិនចេះអក្សរក៏អាចទាមទារឱ្យតុលាការការពារសិទ្ធិរបស់ខ្លួនបាន។ ម្យ៉ាងទៀតពេលដែលដាក់ពាក្យបណ្តឹងទោះជាដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរក៏ដោយ ឬ ដោយផ្ទាល់មាត់ក៏ដោយ ដើមចោទមិនចាំបាច់បញ្ជាក់អំពីខ្លឹមសារនៃសាលក្រមដែលខ្លួនទាមទារ ឬ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារទេគ្រាន់តែបង្ហាញឱ្យច្បាស់លាស់អំពីចំណុចសំខាន់ៗ នៃវិវាទជាការគ្រប់គ្រាន់[69]។ ក៏ប៉ុន្តែដើម្បីទាមទារឱ្យតុលាការធ្វើការ

---

[65] មាត្រា ២២៣ (គោលបំណងនៃនីតិវិធី) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[66] មាត្រា ២២៤ កថាខណ្ឌទី១ (ល័ក្ខខណ្ឌនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[67] មាត្រា ២២៥ កថាខណ្ឌទី១ (ការដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[68] មាត្រា ២២៥ កថាខណ្ឌទី៣ (ការដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[69] មាត្រា ២២៥ កថាខណ្ឌទី២ (ការដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

វិនិច្ឆ័យ និងសម្រេចសេចក្តីតាមនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ដើមចោទត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីចំណុចនេះនៅពេលដាក់ពាក្យបណ្តឹង (មាត្រា២២៤ កថាខណ្ឌទី ២) ។

## ៣. ភាពមិនចាំបាច់មាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ចំពោះនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច មិនធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ ហើយការវិនិច្ឆ័យត្រូវធ្វើនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់តែប៉ុណ្ណោះ[70]។ រឿងក្តី ដែលត្រូវបានវិនិច្ឆ័យតាមនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ជាទូទៅគឺជារឿងក្តីដែលមានទំនាក់ទំនងអង្គហេតុមិនស្មុគស្មាញទេ ដូច្នេះមិនចាំបាច់ធ្វើការរៀបចំចំណុចវិវាទ ឬ ភស្តុតាងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ។ ហេតុដូច្នេះពេលដែលពាក្យបណ្តឹងត្រូវបានដាក់តុលាការត្រូវកំណត់ឱ្យបានឆាប់រហ័សនូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅភាគីទាំងសងខាង។

**កំណត់សម្គាល់៖** បន្ទាប់បានដាក់ពាក្យរួចរាល់តុលាការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងលើកលែងតែក្នុងករណីដែលមានសភាពការណ៍ពិសេស។

## ៤. គោលការណ៍នៃការជំនុំជម្រះតាមកាលបរិច្ឆេទតែមួយថ្ងៃ

ក្នុងនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចជាគោលការណ៍តុលាការត្រូវបញ្ចប់នូវការជំនុំជម្រះ នៅកាលបរិច្ឆេទ លើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់[71]។ មានន័យថាជាគោលការណ៍កាលបរិច្ឆេទសម្រាប់ធ្វើការវិនិច្ឆ័យមានតែមួយដងប៉ុណ្ណោះ។នេះគឺជាគោលគំនិតដែលឱ្យធ្វើនីតិវិធីដោយសង្ខេប និងឱ្យបានឆាប់រហ័ស។ ដោយសារតែមានការចាំបាច់ធ្វើការវិនិច្ឆ័យតាមកាលបរិច្ឆេទតែមួយ ក្នុងនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ចុងចម្លើយមិនអាចប្តឹងតបបានទេ[72]។ ការកម្រិតនូវការពិនិត្យភស្តុតាង ជាអាទិ៍ ការពិនិត្យភស្តុតាងអាចធ្វើបានចំពោះតែភស្តុតាងដែលអាចពិនិត្យបានភ្លាមៗប៉ុណ្ណោះ។ ពេលធ្វើការស្នើសុំឱ្យធ្វើការសាកសួរសាក្សីគឺ គ្រាន់តែនាំសាក្សី ទៅចូលរួមក្នុងកាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយស្នើសុំឱ្យធ្វើការសាកសួរសាក្សីដោយផ្ទាល់មាត់ពេលនោះបានហើយ។ តុលាការអាចធ្វើការសាកសួរសាក្សីដោយមិនចាំបាច់ឱ្យអ្នកនោះធ្វើសម្បថបាន។

70 មាត្រា ២៣៩ (គោលការណ៍នៃការជំនុំជម្រះតាមកាលបរិច្ឆេទតែមួយថ្ងៃ)ក្រមនីតីវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

71 មាត្រា២២៩ កថាខណ្ឌទី ១ (គោលការណ៍នៃការជំនុំជម្រះតាមកាលបរិច្ឆេទតែមួយថ្ងៃ) ក្រមនីតីវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

72 មាត្រា២២៧ (ការហាមឃាត់ចំពោះបណ្តឹងតប) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

### ៥. បញ្ញត្តិពិសេសស្តីពីសាលក្រម

ជាគោលការណ៍ តុលាការត្រូវប្រកាសសាលក្រមភ្លាមៗ ក្រោយពេលដែលការទាញហេតុផលដោយផ្ទាល់មាត់បានបញ្ចប់[73]។ ក្នុងករណីនេះតុលាការអាចប្រកាសសាលក្រមដោយប្រាប់សេចក្តីសម្រេចបញ្ចប់ និងខ្លឹមសារនៃសំអាងហេតុបាន[74] ដោយមិនចាំបាច់ធ្វើលិខិតសាលក្រម (មាត្រា១៨៨ និង១៨៩) ។ ក្នុងករណីនេះ តុលាការត្រូវបង្គាប់ឱ្យក្រឡាបញ្ជីឱ្យធ្វើកំណត់ហេតុជំនួសលិខិតសាលក្រម[75]។ នៅក្នុងសាលក្រមនៃរឿងក្តីចំនួនទឹកប្រាក់តិច ឬ កំណត់ហេតុជំនួសសាលក្រម ត្រូវសរសេរថាជាសាលក្រមនៃរឿងក្តីចំនួនទឹកប្រាក់តិច[76]។

### ៦. បណ្តឹងឧបាស្រ័យចំពោះសាលក្រម

ចំពោះសាលក្រមចុងក្រោយនៃរឿងក្តីចំនួនទឹកប្រាក់តិចភាគីមិនអាចប្តឹងឧបាស្រ័យបានឡើយលើកលែងតែការប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ[77]។ នេះគឺដោយសារតែមានគោលបំណងឱ្យមានការជួយសង្គ្រោះសិទ្ធិដោយងាយស្រួល និងឱ្យបានឆាប់រហ័យតាមរយៈនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច។

## កថាភាគទី២. នីតិវិធីដាស់តឿន

នីតិវិធីដាស់តឿន គឺជានីតិវិធីមួយដែលតុលាការចេញដីកាសម្រេចលើការដាស់តឿនកូនបំណុលអំពីកាតព្វ កិច្ចសងជាប្រាក់តាមការទាមទាររបស់ម្ចាស់បំណុល ដែលការអនុវត្តនីតិវិធីដាស់តឿនមានគោលបំណងចង់ឱ្យម្ចាស់បំណុលអនុវត្តសិទ្ធិរបស់ខ្លួនបានកាន់តែឆាប់រហ័ស ក្នុងករណីដែលកូនបំណុលបដិសេធមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ នីតិវិធីដាស់តឿននេះ មានគោលដៅដាស់តឿនបុគ្គលដែលមិនព្រមធ្វើការអនុវត្តកាតព្វកិច្ចរបស់ខ្លួនបើបុគ្គលរូបនោះមិនព្រមអនុវត្ត បន្ទាប់ពីទទួលបានដីកាសម្រេចដាស់តឿននេះទៀត នោះតុលាការនឹងចាត់វិធានការបន្ទាប់។ ដើម្បីឱ្យបានកាន់តែជ្រាបច្បាស់ជាងនេះ យើងនឹងសិក្សាស្វែងយល់បន្ថែមនូវ លក្ខខណ្ឌចំពោះនីតិវិធីនៃការដាស់តឿន (១) និងអានុភាពនៃដីកាសម្រេចដាស់តឿន(២)។

### ១. លក្ខខណ្ឌចំពោះនីតិវិធីនៃការដាស់តឿន

ដើម្បីចេញសាលដីកាសម្រេចដាស់តឿនបានតុលាការត្រូវគោរពតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- កម្មវត្ថុសម្រេចឱ្យដាស់តឿន៖ កម្មវត្ថុដែលសម្រេចស្នើសុំឱ្យតុលាការចេញដីកាសម្រេចលើការដាស់តឿននោះត្រូវតែជាការទាមទារឱ្យសងប្រាក់ ឬ ការទាមទារឱ្យផ្តល់តាវកាលិក[78] ។

[73] មាត្រា២៣៦ កថាខណ្ឌទី១ (សាលក្រម និងការប្រកាសសាលក្រម) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[74] មាត្រា២៣៦ កថាខណ្ឌទី២ (សាលក្រម និងការប្រកាសសាលក្រម) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[75] មាត្រា២៣៦ កថាខណ្ឌទី៣ (សាលក្រម និងការប្រកាសសាលក្រម) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[76] មាត្រា២៣៦ កថាខណ្ឌទី២៤ (សាលក្រម និងការប្រកាសសាលក្រម) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[77] មាត្រា ២៣៨ (ការហាមឃាត់ចំពោះឧបាស្រ័យ) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[78] មាត្រា៣១៩ (លក្ខខណ្ឌនៃដីកាសម្រេចដាស់តឿន) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

- កូនបំណុលមិនអនុវត្តកាតព្វកិច្ច៖ កូនបំណុលបិសេធដោយស្ម័គ្រចិត្ត លើការមិនអនុវត្តកាតព្វកិច្ច ដែលមានក្នុងកិច្ចសន្យា ដោយមិនសងប្រាក់ទៅម្ចាស់បំណុលជាដើម។
- ចំណុចដែលត្រូវសរសេរបញ្ជាក់ក្នុងដីកាសម្រេចដាស់តឿនដែលមានដូចខាងក្រោមនេះ៖
  - → ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ឬអ្នកតំណាង
  - → ដីកាដែលសម្រេចឱ្យតុលាការចេញតាមការទាមទាររបស់ម្ចាស់បំណុល
  - → អង្គហេតុចាំបាច់មួយចំនួន ដើម្បីបញ្ជាក់ការទាមទារ
  - → ចំនួនទឹកប្រាក់ដែលត្រូវសង
  - → បញ្ជាក់អំឡុងពេលនៃការធ្វើបណ្តឹងតវ៉ាលើដីកាដាស់តឿន បើភាគីពុំប្តឹងតវ៉ាក្នុងអំឡុងពេលកំណត់ នោះតុលាការនឹងអនុវត្តជាបណ្តោះអាសន្នតាមឆន្ទានុសិទ្ធិ[79]។
- បញ្ជូនដីកាសម្រេចនោះឱ្យដល់កូនបំណុល[80]។

## ២. អានុភាពនៃដីកាសម្រេចដាស់តឿន

ដីកាសម្រេចដាស់តឿន នឹងមានអានុភាពភ្លាម បន្ទាប់ពីបានបញ្ជូនទៅដល់កូនបំណុល[81] បើកូនបំណុលមិនព្រមធ្វើវិវាទលើដីកាសម្រេចដាស់តឿន នៅមុនអំឡុងពេល ២សប្តាហ៍ នៃការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នទេ នោះដីកាសម្រេចឱ្យដាស់តឿននឹងចូលជាស្ថាពរអំពីការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដែលការចូលជាស្ថាពរនេះនឹងមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពររបស់តុលាការដែរ[82] ហើយតុលាការនឹងអនុវត្តជាបណ្តោះអាសន្នតាមឆន្ទានុសិទ្ធិរបស់ខ្លួន។

[79] មាត្រា៣២៤ (ចំណុចដែលត្រូវសរសេរបញ្ជាក់ក្នុងដីការសម្រេចដាស់តឿន) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[80] មាត្រា៣២៥ (ការបញ្ជូនដីការសម្រេចដាស់តឿន) កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[81] មាត្រា៣២៥ (ការបញ្ជូនដីការសម្រេចដាស់តឿន) កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[82] មាត្រា៣៣៣ (អានុភាពនៃដីការសម្រេចដាស់តឿន) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយមកខាងលើយើងអាចធ្វើការសន្និដ្ឋានបានថាការដំណើរការនីតិវិធីនៃការដោះស្រាយរឿងក្ដីរដ្ឋប្បវេណីចាត់តាំងពីការផ្ដើមនៃការដាក់ពាក្យបណ្ដឹង រហូតដល់ការបញ្ចប់បណ្ដឹងនេះ បានឱ្យឃើញថាវាពិតជាមានភាពស្មុគស្មាញបន្ដិចក៏ពិតមែន អំពីដំណើរការនីតិវិធីនៃការជម្រះក្ដីលើកទី១ និងការអនុវត្តសាលក្រម។ យ៉ាងណាមិញទោះនីតិវិធីរដ្ឋប្បវេណីនេះមានភាពស្មុគស្មាញ និងពិបាកយល់ជាច្រើនក្នុងនីតិវិធីក៏ពិតមែនប៉ុន្តែនៅក្នុងអត្ថបទ និងអត្ថន័យក៏ដូចជាការពន្យល់ទាំងអស់នេះមិនមានពាក្យពេចន៍ស្មុគស្មាញ និងក្នុងការពិបាកយល់ប៉ុន្មានទេ ពោលគឺយើងបានរៀបរៀងយ៉ាងម៉ត់ចត់អំពីលំដាប់លំដោយទៅតាមនីតិវិធីក្នុងរឿងក្ដីរដ្ឋប្បវេណីនៅសាលាដំបូងរាជធានីភ្នំពេញចាត់តាំងពីផ្ដើមរហូតដល់ការបញ្ចប់បណ្ដឹងតែម្ដង ពោលគឺក្នុងនេះបានពន្យល់ឬនិយាយតាំងពីទម្រង់នៃពាក្យបណ្ដឹង ដូចជាការសរសេរក្នុងពាក្យបណ្ដឹងដែលវាជារឿងដ៏សំខាន់មួយដំណាក់កាលដែរដើម្បីដំណើរការនៃការកាត់ក្ដី និងដើម្បីអាចបន្តដំណាក់កាលផ្សេងទៀតបាន។ មិនតែប៉ុណ្ណោះក្នុងការសរសេរពាក្យបណ្ដឹងក៏មានការសរសេរទាមទារតាវកាលិក(កម្មវត្ថុ) និងមូលហេតុនៃការទាមទារនិងមូលហេតុនៃការទាមទារក៏ដូចជាអង្គហេតុដែលនាំឱ្យមានវិវាទតាមផ្លូវច្បាប់កើតមានឡើងដែរ។

លើសពីនេះទៅទៀតចំណុចសំខាន់មួយទៀតនិងវាមានភាពស្មុគស្មាញផងដែរនោះគឺដំណើរការនីតិវិធីនៃការជម្រះក្ដីលើកទី១នោះ គឺចៅក្រមត្រូវកំណត់ឱ្យបាននូវចំណុចវិវាទនៃរឿងក្ដីតាមរយៈការរៀបចំការអះអាងរបស់គូភាគីនៃរឿងក្ដី ព្រមទាំងរៀបចំនូវភស្តុតាងទាំងឡាយដែលទាក់ទងទៅនឹងចំណុចវិវាទនោះ ក្នុងគោលបំណងមួយដើម្បីឱ្យការដំណើរការនៃការទាញហេតុផលមានភាពឆាប់រហ័ស ងាយស្រួល និងមិនស្មុគស្មាញ ហើយនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់វិញ ចៅក្រមត្រូវពិនិត្យភស្តុតាងដែលបានរៀបចំរួចមកហើយនោះ ដើម្បីដោះស្រាយនូវចំណុចវិវាទដែលបានកំណត់នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ផ្ទុយទៅវិញប្រសិនបើតុលាការបានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានល្អ ពោលគឺតុលាការកំណត់បាននូវចំណុចវិវាទនៃរឿងក្ដីបាន ហើយតុលាការបានរៀបចំភស្តុតាងដែលទាក់ទង នឹងចំណុចវិវាទនោះបានល្អ នោះការដំណើរការនៃការទាញហេតុផលដោយផ្ទាល់មាត់ នឹងមានភាពឆាប់រហ័ស ដំណើរការមានភាពងាយស្រួល ការដោះស្រាយរឿងក្ដីមានគោលដៅ និងអាចផ្ដល់យុត្តធម៌ជូនគូភាគីបាន ។

ទន្ទឹមនឹងនេះផងដែរក្នុងនេះក៏មានការនិយាយអំពីការបញ្ចប់បណ្ដឹង គឺជាដំណាក់កាលចុងក្រោយដែលបានឆ្លងកាត់ដំណាក់កាលនៃដំណើរការដាក់ពាក្យបណ្ដឹងពីដំបូង រហូតឈានមកកាន់ការបញ្ចប់បណ្ដឹងវិញម្ដងដោយព្រោះបណ្ដឹងត្រូវបានចាប់ផ្ដើម ដោយការទាមទាររបស់ដើមចោទ តាមរយៈពាក្យបណ្ដឹងសុំឱ្យ តុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់ណាមួយ ជាគោលការណ៍ បណ្ដឹងត្រូវបញ្ចប់ដោយសាលក្រម របស់

តុលាការដែលជាការឆ្លើយតបចំពោះការទាមទាររបស់ដើមចោទនោះ ។នៅពេលដែលការវិនិច្ឆ័យចប់ ជាមួយការបញ្ចប់នូវការទាញហេតុផល និង ការពិនិត្យភស្តុតាង តុលាការត្រូវ បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ កំណត់កាលបរិច្ឆេទសម្រាប់ការប្រកាសសាលក្រម និង ត្រូវប្រកាស សាលក្រម។ ពេលដែលសាលក្រមនោះចូលជាស្ថាពរ គោលដៅនៃបណ្តឹង ក៏ត្រូវបានសម្រេច ហើយបណ្តឹងនោះត្រូវចប់ ។ ក៏ប៉ុន្តែសាលក្រមដែលមានអានុភាពបញ្ចប់បណ្តឹងចាំបាច់ត្រូវ ជាសាលក្រមបញ្ចប់រឿងក្តីទាំងមូល ឬ មួយភាគ ។ សាលក្រមដែលបញ្ចប់រឿងក្តីទាំងមូល ឬ មួយភាគនោះ គេហៅថា សាលក្រមចុងក្រោយ ។

ដូច្នេះគ្រប់ដំណាក់កាលនៃនីតិវិធី សុទ្ធតែមានសារៈសំខាន់ ដែលទាមទារឱ្យចៅក្រម ក៏ដូចជាភាគីយល់ឱ្យច្បាស់អំពីនីតិវិធីនីមួយៗចាប់តាំងពីការដាក់ពាក្យបណ្តឹង រហូតដល់ការបញ្ចប់បណ្តឹង ដូច្នេះទើបការដោះស្រាយរឿងក្តីរដ្ឋប្បវេណីតាមរយៈប្រព័ន្ធតុលាការប្រកបទៅដោយភាពច្បាស់លាស់និងមិនមានភាពស្មុគស្មាញ។

# អនុសាសន៍

# អនុសាសន៍

យើងបានដឹងហើយថា នីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីនៅសាលាដំបូងរាជធានីភ្នំពេញនេះ ជាប្រធានបទមួយដែលមានសារៈសំខាន់ណាស់ សម្រាប់មជ្ឈដ្ឋានទូទៅហើយយើងបានសង្កេតឃើញថា នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ នៅក្នុងប្រទេសកម្ពុជាយើង នៅមិនទាន់បានយល់ដឹងផ្នែកច្បាប់ ក៏ដូចជានីតិវិធីច្បាប់ឱ្យបានទូលំទូលាយនៅឡើយទេ។ ថ្វីត្បិតតែច្បាប់បាន បង្កើតឡើងក៏ពិតមែន តែបើប្រជាពលរដ្ឋនៅមិនទាន់បានយល់ដឹងអំពីច្បាប់ដែលជាហេតុធ្វើឱ្យកើតមានជម្លោះនិងការស្មុគស្មាញមិនយល់នៅក្នុងនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីជាបន្តបន្ទាប់។

ជាការពិតណាស់ ក្នុងនីតិវិធីនេះវាពិតជាមានការស្មុគស្មាញក្នុងការស្វែងយល់ ដោយមានលំហូរនីតិវិធីជាបន្តបន្ទាប់ចាប់តាំងពីការដាក់ពាក្យបណ្តឹងរហូតដល់ការបញ្ចប់បណ្តឹង។ ក្នុងនេះក៏បាននិយាយការចាត់ចែងរក្សាការពារ គឺជានីតិវិធីមួយដែលយើងគួរគប្បីស្នើដាក់រក្សារកម្មវត្ថុនៃវិវាទដែលមានការ ស្នើសុំពីភាគីដើម្បីឱ្យមានការចាត់ចែងរក្សាការពារនេះឡើងក្នុងគោលដៅការពារកម្មវត្ថុនោះកុំឱ្យមានការប្រែប្រួលបច្ចុប្បន្នភាពរបស់វាដែលជាហេតុនាំឱ្យមានការប៉ះពាល់ដល់ដំណើរការរឿងក្តីដែរនិងជាផលប្រយោជន៍ដល់ដើមបណ្តឹងជាសវាងបាត់បង់នូវកម្មវត្ថុនៅពេលអនុវត្តសិទ្ធិ។ លើសពីនេះទៅទៀតក៏មាននៅទម្រង់ពាក្យបណ្តឹងក្នុងការដាក់ពាក្យបណ្តឹងឱ្យបានត្រឹមត្រូវទៅតាមក្បួនខ្នាតដោយការសរសេរពាក្យបណ្តឹងរួមមានការសរសេរឬបំពេញអង្គហេតុ ភស្តុតាង កម្មវត្ថុនិងមូលហេតុនៃការទាមទារ។ដូច្នេះនៅពេលដែលបណ្តុំឯកសារដែលត្រូវរៀបចំនិងបំពេញឱ្យបានត្រឹមត្រូវទើបតុលាការសម្រេចទទួលនិងមានភាពរលូន។រីឯក្នុងនីតិវិធីជំនុំជម្រះលើកទី១ នៅពេលដែលភាគីដល់ថ្ងៃ នៅក្នុងកាលបរិច្ឆេទ នៃនីតិវិធីនីមួយៗ តុលាការត្រូវផ្តល់នូវសិទ្ធិស្មើគ្នាចំពោះភាគី ដូចជា ការផ្តល់សិទ្ធិឱ្យភាគីបានធ្វើការអះអាង, តវ៉ា, ថ្លែងការណ៍, តទល់ និង ការបង្ហាញភស្តុតាងឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យតុលាការទទួលបាននូវគោល គំនិតពីសកម្មភាពដែលបានធ្វើឡើងនោះ សម្រាប់យកមកធ្វើជាមូលដ្ឋានក្នុងការពិចារណា និង វិនិច្ឆ័យសម្រេចសេចក្តី ហើយនិងកុំឱ្យភាគីមានអារម្មណ៍ថា តុលាការបានបិទសិទ្ធិភាគីណាម្ខាងមិនឱ្យធ្វើសកម្មភាព។ ការជម្រះក្តីត្រូវតែធានាឱ្យបានថា ត្រូវធ្វើឡើងដោយគោរពតាម គោលការណ៍ចំពោះមុខ ដើម្បីធានាឱ្យបាន នូវតម្លាភាព ក៏ដូចជាទំនុកចិត្តជាសាធារណៈ និងដំណើរការទៅប្រកបដោយប្រសិទ្ធិភាព គុណភាព ឆាប់រហ័សនិងយុត្តិធម៌។

មួយវិញទៀតការប្រកាសសាលក្រមត្រូវធ្វើឡើងដោយការប្រកាសរបស់តុលាការ បន្ទាប់ពីបានឆ្លងកាត់នីតិវិធីត្រៀម សម្រាប់ការទាញហេតុផល និងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់រួចមក ដោយសាលក្រមនោះនឹង មានអានុភាពបន្ទាប់ពីបានប្រកាស។ហើយយើងត្រូវអនុវត្តទៅតាមអត្ថន័យរបស់សាលក្រមនោះក្នុងករណីមានភាគីនីមួយៗមិនពេញចិត្តនឹងសាលក្រមចុងក្រោយរបស់ តុលាការសាលាដំបូង ឬការជម្រះក្តី

លើកទី១ នេះទេ ពួកគេអាចធ្វើបណ្តឹងទៅតុលាការជាន់ខ្ពស់ពីការមិនសុខចិត្តលើសាលក្រមចុងក្រោយនេះជាបន្តបាន និងសាលក្រមចុងក្រោយ ដែលធ្វើការសម្រេចសេចក្តីអំពីវិវាទរបស់ភាគីនោះ ត្រូវធានាឱ្យថាបានធ្វើតាមដំណើរការនៃនីតិវិធីទៅតាមលំដាប់លំដោយតាមបទបញ្ញត្តិច្បាប់ដែលមានចែងជាធរមាន។

# ឯកសារយោង

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

- ក្រមរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ប្រកាសឱ្យប្រើ០៨ ធ្នូ ២០០៧ ។
- ក្រមនីតិវិធីរដ្ឋប្បវេណី ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ប្រកាសឱ្យប្រើ០៦ កក្កដា ២០០៦ ។
- ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ប្រកាសឱ្យប្រើ២២ សីហា ១៩៩៥ ។

## ២. ឯកសារផ្សេងៗ

- សេចក្តីពន្យល់ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីចេញសាលក្រម។
- សេចក្តីពន្យល់ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ ។
- សៀវភៅមេរៀនរបស់វិភាគទានច្បាប់ ។

# ឧបសម្ព័ន្ធ

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

**ឧបសម្ព័ន្ធទី១**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមរដ្ឋប្បវេណី

លេខ ៩៦០ “ធ”

ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩

សំណុំរឿងរដ្ឋប្បវេណីលេខ ៨៤៧

ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ **នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង៣០នាទីព្រឹក នៅសាលសវនាការទី២** លើសំណុំរឿងរដ្ឋប្បវេណីលេខ ៨៤៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក **គោ វណ្ណី** អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ។

**ក្រឡាបញ្ជីសវនាការ**

លោកស្រី **អ៊ូ គាវ៉ាន់** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ ។

-រវាងដើមចោទ និងជាចុងបណ្តឹងតបឈ្មោះ ជ ភេទស្រី ឆ្នាំកំណើត១៩៨១ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ រាជធានីភ្នំពេញ ។

-មានកញ្ញា **អ៊ុយ ច័ន្ទធារី** ជាមេធាវីតំណាងដោយអាណត្តិ ។

-ចុងចម្លើយ និងជាដើមបណ្តឹងតបឈ្មោះ ច ភេទស្រី អាយុ៤១ឆ្នាំ ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ

រាជធានីភ្នំពេញ ។

-មានលោកស្រី **ទី គឹមស្រ៊ាន** ជាមេធាវីតំណាងដោយអាណត្តិ ។

**I-អង្គហេតុ និងចំនុចវិវាទ**

**១-ខ្លឹមសារនៃសាលក្រមដែលដើមចោទ និងជាចុងបណ្តឹងតបទាមទារឱ្យតុលាការចេញ**

១.១-ឱ្យចុងចម្លើយសងប្រាក់ចំនួន $៧៤០,៩៣៦(ប្រាំពីររយសែសិបពាន់ប្រាំបួនរយសាមសិបប្រាំមួយដុល្លារអាមេរិក) ។

១.២-ឱ្យចុងចម្លើយសងសំណងការខូចខាត សំណងជម្ងឺចិត្ត និងការចំណាយផ្សេងៗក្នុងរឿងក្តី សរុបចំនួន $២០០,០០០(ពីររយពាន់ដុល្លារអាមេរិក)។

១.៣-ប្រកាសអនុវត្តជាបណ្តោះអាសន្ន។

១.៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**២-ខ្លឹមសារនៃសាលក្រមដែលចុងចម្លើយ និងជាដើមបណ្តឹងតបទាមទារឱ្យតុលាការចេញ**

-ប្តឹងសុំឱ្យភាគីចុងបណ្តឹងតបឈ្មោះ ជ គោរពកិច្ចសន្យាទទួលស្គាល់បំណុល ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៤ ដោយសុំសងបំណុលជាការបង់រំលោះរហូតដល់ចប់កិច្ចសន្យា។

**៣-ការពន្យល់ត្រួសៗអំពីរឿងក្តី**

កន្លងមកចុងចម្លើយឈ្មោះ ច បានទិញគ្រឿងអលង្ការពីដើមចោទ ប៉ុន្តែចុងចម្លើយមិនទាន់បានទូទាត់ប្រាក់ឱ្យដើមចោទនោះទេ។ ទើបនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៤ ចុងចម្លើយឈ្មោះ ច បានធ្វើ

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្ដីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

កិច្ចសន្យាទទួលស្គាល់បំណុល ដែលមានខ្លឹមសារថា ចុងចម្លើយពិតជាបានជំពាក់ប្រាក់ដើមចោទថ្លៃទិញគ្រឿងអលង្ការ ហើយមិនទាន់បានទូទាត់ប្រាកដមែន ហើយដើមចោទក៏បានយល់ព្រមឱ្យចុងចម្លើយឈ្មោះ ច សងរំលោះប្រាក់ជំពាក់ថ្លៃទិញគ្រឿងអលង្ការ ក្នុងរយៈពេល១៥(ដប់ប្រាំ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៨។ ចុងចម្លើយបានចេញមូលប្បទានប័ត្ររបស់ធនាគារ • ចំនួន **១៨០ (មួយរយប៉ែតសិប)សន្លឹក** ទុកជាការធានា និងទុកឱ្យដើមចោទយកទៅបើកប្រាក់រៀងរាល់ខែ ដោយមូលប្បទានប័ត្រនីមួយៗមានទឹកប្រាក់ ចំនួន $៥,៦៥៦(ប្រាំពាន់ប្រាំមួយរយហាសិបប្រាំមួយដុល្លារអាមេរិក)។ ក្រោយពីធ្វើកិច្ចសន្យាទទួលស្គាល់បំណុល និងលិខិតតម្កល់មូលប្បទានប័ត្រនោះរួចមក ដើមចោទតែងតែបើកប្រាក់តាមមូលប្បទានប័ត្រនោះជារៀងរាល់ខែ ប៉ុន្តែចុងចម្លើយតែងតែមានការយឺតយ៉ាវនៅក្នុងការសងរំលោះជានិច្ច។

៣-<u>អង្គហេតុដែលអះអាងដោយដើមចោទ និងជាចុងបណ្ដឹងតប</u>

-កញ្ញា **អ៊ុយ ច័ន្ទធារី** ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ និងជាចុងបណ្ដឹងតបឈ្មោះ ជ បានធ្វើសេចក្ដីថ្លែងការណ៍ថា: កន្លងមកចុងចម្លើយឈ្មោះ ច បានទិញគ្រឿងអលង្ការពីកូនក្ដីខ្លួន ប៉ុន្តែចុងចម្លើយ និងជាដើមបណ្ដឹងតប មិនទាន់បានទូទាត់ប្រាក់ឱ្យកូនក្ដីខ្លួនទេ។ ទើបនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៤ ចុងចម្លើយ និងជាដើមបណ្ដឹងតបឈ្មោះ ច បានធ្វើកិច្ចសន្យាទទួលស្គាល់បំណុល ដែលមានខ្លឹមសារថា ចុងចម្លើយ និងជាដើមបណ្ដឹងតប ពិតជាបានជំពាក់ប្រាក់កូនក្ដីខ្លួនថ្លៃទិញគ្រឿងអលង្ការ ហើយមិនទាន់បានទូទាត់ប្រាកដមែន ហើយកូនក្ដីខ្លួនក៏បានយល់ព្រមឱ្យចុងចម្លើយ និងជាដើមបណ្ដឹងតបឈ្មោះ ច សងរំលោះប្រាក់ជំពាក់ថ្លៃទិញគ្រឿងអលង្ការ ក្នុងរយៈពេល១៥(ដប់ប្រាំ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៨។ ចុងចម្លើយ និងជាដើមបណ្ដឹងតប បានចេញមូលប្បទានប័ត្ររបស់ធនាគារ • ចំនួន១៨០(មួយរយប៉ែតសិប)សន្លឹក ទុកជាការធានា និងទុកឱ្យកូនក្ដីខ្លួនយកទៅបើកប្រាក់ជារៀងរាល់ខែ ដោយមូលប្បទានប័ត្រនីមួយៗមានទឹកប្រាក់ចំនួន $៥,៦៥៦(ប្រាំពាន់ប្រាំមួយរយហាសិបប្រាំមួយ)ដុល្លារអាមេរិក។ ក្រោយពីបានធ្វើកិច្ចសន្យាទទួលស្គាល់បំណុល និងលិខិតតម្កល់មូលប្បទានប័ត្រនោះរួចមក កូនក្ដីខ្លួនតែងតែបើកប្រាក់តាមរយៈមូលប្បទានប័ត្រនោះជារៀងរាល់ខែ ប៉ុន្តែចុងចម្លើយតែងតែមានការយឺតយ៉ាវ នៅក្នុងការសងរំលោះជានិច្ច។ ដោយឡែកនៅរយៈពេល២ខែចុងក្រោយនេះ គឺនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ កូនក្ដីខ្លួនបានយកមូលប្បទានប័ត្រលេខ ទៅបើកប្រាក់ដូចរាល់ខែ ប៉ុន្តែត្រូវបានខាងធនាគារចេញ លិខិតបញ្ជាក់ថា គណនីរបស់ចុងចម្លើយ និងជាដើមបណ្ដឹងតប មិនមានទឹកប្រាក់គ្រប់គ្រាន់សម្រាប់ឱ្យកូនក្ដីខ្លួនបើកឡើយ។ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ កូនក្ដីខ្លួនក៏បានយកមូលប្បទានប័ត្រលេខ ទៅបើកទៀត ប៉ុន្តែត្រូវបានខាងធនាគារចេញលិខិតបញ្ជាក់ថា គណនីរបស់ចុងចម្លើយ និងជាដើមបណ្ដឹងតប មិនមានទឹកប្រាក់គ្រប់គ្រាន់សម្រាប់ឱ្យកូនក្ដីខ្លួនបើក ដើម្បីធ្វើការទូទាត់សងរំលោះឱ្យកូនក្ដីខ្លួន តាមកិច្ចសន្យាទទួលស្គាល់បំណុល ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៤ និងលិខិតតម្កល់មូលប្បទានប័ត្រ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៤ នោះឡើយ។ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១ និងលើកទី២ ខាងចុងចម្លើយបានទទួលដីកាកោះ ប៉ុន្តែមានចេតនាគេចវេសមកចូលក្នុងនីតិវិធីរបស់តុលាការដែលបានកំណត់ឡើយ ដោយមាត្រា ៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ថាជាការចាត់ទុកថាបានសារភាព នៅក្នុងកថាខណ្ឌទី១ ក្នុងករណីដែលភាគីមិនបានបង្ហាញច្បាស់លាស់ នូវឆន្ទៈតវ៉ាអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុ និងការទាញហេតុផលដោយផ្ទាល់មាត់ទេ ភាគីនោះត្រូវបានចាត់ទុកថា បានសារភាពអំពីអង្គហេតុនោះ ដោយហេតុថា

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគីចុងចម្លើយ និងមេធាវីមិនបានចូលតាមការកោះហៅរបស់តុលាការ ដូចនេះត្រូវចាត់ទុកបានសារភាពថា ខ្លួនពិតជាជំពាក់បំណុលកូនក្តីរបស់ខ្លួន ចំនួន $៧៤០,៩៣៦(ប្រាំពីររយសែសិបពាន់ប្រាំបួនរយសាមសិបប្រាំមួយដុល្លារអាមេរិក) ទើបនាំឲ្យពុំមានចំណុចវិវាទឡើយចំពោះពាក្យបណ្តឹងនេះ។

<u>សំណូមពរ:</u>

-បង្គាប់អោយចុងចម្លើយសងប្រាក់ ចំនួន **$៧៤០,៩៣៦(ប្រាំពីររយសែសិបពាន់ប្រាំបួនរយសាមសិបប្រាំមួយដុល្លារអាមេរិក)** មកកូនក្តីរបស់ខ្លួនឈ្មោះ ជ

-បង្គាប់អោយចុងចម្លើយសងសំណងការខូចខាត សំណងជំងឺចិត្ត និងការចំណាយផ្សេងៗក្នុងរឿងក្តីសរុបចំនួន **$២០០,០០០(ពីររយពាន់ដុល្លារអាមេរិក)**។

-ប្រកាសអនុវត្តជាបណ្តោះអាសន្ន។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**<u>៤-អង្គហេតុដែលអះអាងដោយចុងចម្លើយ និងជាដើមបណ្តឹងតប</u>**

-លោកស្រី **ទី គឹមស្រ៊ាន** មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ និងជាដើមបណ្តឹងតបឈ្មោះ ច បានធ្វើសេចក្តីថ្លែងការណ៍តបថា: ពេលនេះកូនក្តីខ្លួនយល់ព្រមសងប្រាក់ ចំនួន **$៤៨០,០០០(សែសិបប្រាំបីម៉ឺនដុល្លារអាមេរិក)** ទៅឲ្យដើមចោទ ប្រាក់នេះខ្លួនមេធាវីជាអ្នកធានា និងយកមូលប្បទានប័ត្រដែលជាកម្មសិទ្ធិរបស់ខ្លួន មកតម្កល់នៅតុលាការ។ សុំឲ្យដើមចោទ និងជាចុងបណ្តឹងតប បំពេញនីតិវិធីលុបដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ១៨៣"ឥ"ដរ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ឲ្យកូនក្តីខ្លួនតាមផ្លូវតុលាការរួចរាល់ ហើយតុលាការចេញដីកាសម្រេចលុបដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ១៨៣"ឥ"ដរ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ រួចរាល់ជាមុនសិន ទើបអាចបើកប្រាក់ចំនួន **$៤៨០,០០០ (សែសិបប្រាំបីម៉ឺនដុល្លារអាមេរិក)** នេះបាន ។

**៥-ចំនុចគ្មានវិវាទ:**

-ចំពោះទឹកប្រាក់ចំនួន **$៤៨០,០០០(សែសិបប្រាំបី ម៉ឺនដុល្លារអាមេរិក)**។

**៦-ចំនុចវិវាទ:**

-លើទឹកប្រាក់ចំនួន **$២៦០,៩៣៦(ពីររយហុកសិបពាន់ប្រាំបួនរយសាមសិបប្រាំមួយដុល្លារអាមេរិក)** ។

-តើដើមចោទទាមទារលើទឹកប្រាក់ចំនួន **$២៦០,៩៣៦(ពីររយហុកសិបពាន់ប្រាំបួនរយសាមសិបប្រាំមួយដុល្លារអាមេរិក)** ពីចុងចម្លើយនេះ ត្រឹមត្រូវដែរឬទេ?

## II-**<u>ការពិនិត្យភស្តុតាង</u>**

**១-ភស្តុតាងជាឯកសាររបស់ដើមចោទ**

១.១.កិច្ចសន្យាទទួលស្គាល់បំណុល ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៤ ។

១.២.លិខិតតម្កល់មូលប្បទានប័ត្រ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៤ ។

១.៣.មូលប្បទានប័ត្រ លេខ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ ។

១.៤.មូលប្បទានប័ត្រ លេខ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ។

**២-ភស្តុតាងជាឯកសាររបស់ចុងចម្លើយ:** គ្មាន ។

**៣-ការសាកសួរសាក្សី:** គ្មាន ។

*កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ*

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

១-ពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ របស់ឈ្មោះ ជ តុលាការលើកយកមកចាត់ការបាន តាមបញ្ញត្តិមាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**២**-តាមការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ និងជាចុងបណ្តឹងតប បានបញ្ជាក់ថា: កន្លងមកចុងចម្លើយឈ្មោះ ច បានទិញគ្រឿងអលង្ការពីកូនក្តីខ្លួន ប៉ុន្តែចុងចម្លើយ និងជាដើមបណ្តឹងតប មិនទាន់បានទូទាត់ប្រាក់ឱ្យកូនក្តីខ្លួនទេ។ ទើបនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៤ ចុងចម្លើយ និងជាដើមបណ្តឹងតប ឈ្មោះ ច បានធ្វើកិច្ចសន្យាទទួលស្គាល់បំណុល ដែលមានខ្លឹមសារថា ចុងចម្លើយ និងជាដើមបណ្តឹងតប ពិតជាបានជំពាក់ប្រាក់កូនក្តីខ្លួនថ្លៃទិញគ្រឿងអលង្ការ ហើយមិនទាន់បានទូទាត់ប្រាកដមែន ហើយកូនក្តីខ្លួនក៏បានយល់ព្រមឱ្យចុងចម្លើយ និងជាដើមបណ្តឹងតបឈ្មោះ ច សងរំលោះប្រាក់ជំពាក់ថ្លៃទិញគ្រឿងអលង្ការ ក្នុងរយៈពេល១៥(ដប់ប្រាំ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៨ ដែលការអះអាងតុលាការអាចជឿបាន ព្រោះស្របនឹងភស្តុតាងដែលផ្តល់ដោយភាគីដើមចោទ គឺកិច្ចសន្យាទទួលស្គាល់បំណុល ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៤ ។

៣-តាមពាក្យបណ្តឹងតប ចុះថ្ងៃទី២៧ ខែសីហា ឆ្នា២០១៨ របស់ភាគីចុងចម្លើយ បានអះអាងថា ខ្លួនបានទិញគ្រឿងអលង្ការពីដើមចោទឈ្មោះ ជ ក្នុងតម្លៃប្រហែល **៤០ម៉ឺនដុល្លារអាមេរិក** ពុំមែនមានទឹកប្រាក់ដូចការទាមទាររបស់ដើមចោទឡើយ ព្រោះពុំមានភស្តុតាងណាមួយបង្ហាញតុលាការដើម្បីធ្វើការពិនិត្យ ពិចារណាឡើយ។

៤-ចំពោះទឹកប្រាក់នៃចំណុចវិវាទ ចំនួន **២៦០,៩៣៦ដុល្លារអាមេរិក** ដែលដើមចោទធ្វើការទាមទារឱ្យភាគីចុងចម្លើយសងនេះ មានភស្តុតាងបញ្ជាក់ថា ភាគីចុងចម្លើយពិតជាជំពាក់ដើមចោទមែន គឺតាមរយៈភស្តុតាងកិច្ចសន្យាទទួលស្គាល់បំណុល ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៤ ។

៥-ការអះអាងរបស់ដើមចោទថា ខ្លួនសុំទាមទារប្រាក់ថ្លៃលក់គ្រឿងអលង្ការពីភាគីចុងចម្លើយ ដោយហេតុថា ភាគីចុងចម្លើយមិនបានទូទាត់ប្រាក់ឱ្យខ្លួនតាមកិច្ចសន្យា ដែលការអះអាងនេះតុលាការអាចជឿបាន ព្រោះស៊ីសង្វាក់នឹងការអះអាងរបស់ភាគីចុងចម្លើយថា ខ្លួនពិតជាបានទិញគ្រឿងអលង្ការពីដើមចោទមែន ដោយធ្វើការទូទាត់តាមរយៈការដាក់តម្កល់មូលប្បទានប័ត្រ ចំនួន**១៨០សន្លឹក** ត្រង់អង្គហេតុនេះបញ្ជាក់ថា ភាគីចុងចម្លើយ គឺជាភាគីអ្នកទិញតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។

៦-តាមមាត្រា ៥៥៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ចែងថា: អ្នកទិញមានករណីកិច្ចបង់ថ្លៃជាប្រាក់ដែលកំណត់ក្នុងកិច្ចសន្យា តាមកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់ក្នុងកិច្ចសន្យា ក្នុងអង្គហេតុនេះ ឃើញថា ភាគីចុងចម្លើយដែលជាអ្នកទិញ ពុំបានបំពេញកាតព្វកិច្ចពេញលេញតាមកិច្ចសន្យាឡើយ ។

៧-តាមប្រការ ៥ នៃកិច្ចសន្យាទទួលស្គាល់បំណុល ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៤ ចែងថា: " ចំពោះមូលប្បទានប័ត្រចំនួន **១៨០(មួយរយប៉ែតសិប)**សន្លឹក ដែល **ភាគី "ខ"** បានចេញជូន **ភាគី "ក"** ជាមុនទុកជាការធានា និងដើម្បីទុកឱ្យ **ភាគី "ក"** យកទៅបើកប្រាក់រៀងរាល់ខែនោះ គឺបណ្តាលមកពីកំហុស ឬចេតនាទុច្ចរិតណាមួយរបស់ **ភាគី "ខ"** នោះ **ភាគី "ខ"** ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយ **ភាគី "ក"** មានសិទ្ធិទាមទារឱ្យ **ភាគី"ខ"** សងប្រាក់ដែលជំពាក់ទាំងអស់មកវិញតែម្តង ។" ហើយនៅក្នុងអង្គហេតុនេះឃើញថា មូលប្បទានប័ត្រលេខ និងលេខ ពុំមានទឹកប្រាក់អាចឱ្យដើមចោទបើកបានឡើយ ត្រង់ចំណុចនេះបញ្ជាក់ថា ដើមចោទអាចប្តឹងទាមទារប្រាក់ទាំងអស់តាមផ្លូវតុលាការបាន។

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគម្រូទេ

៨-ការប្ដឹងទាមទារជម្ងឺចិត្ត ចំនួន **$២០០,០០០(ពីររយពាន់ដុល្លារអាមេរិក)** ពីភាគីចុងចម្លើយមានលក្ខណៈសមស្រប គប្បីតុលាការពិនិត្យ និងសម្រេចតាមភាពជាក់ស្ដែង ។

៩-តាមអង្គហេតុឃើញថា ដើមចោទសុំទាមទារអនុវត្តបណ្ដោះអាសន្ន លើប្រាក់ជំពាក់តាមកិច្ចសន្យាទទួលស្គាល់បំណុល ចំនួន **$៧៤០,៩៣៦(ប្រាំពីររយសែសិបពាន់ប្រាំបួនរយសាមសិបប្រាំមួយដុល្លារអាមេរិក)** តាមមាត្រា **១៩៦** នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការពិចារណា លើការប្ដឹងសុំរបស់ដើមចោទបាន ។

១០-ប្រាក់ប្រដាប់ក្ដីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## **សេចក្ដីសម្រេចបញ្ចប់**

១-បង្គាប់ឲ្យចុងចម្លើយ និងជាដើមបណ្ដឹតបណ្ដឹងតបឈ្មោះ ច (មានលោកស្រី **ទី គឹមស្រ៊ាន** ជាមេធាវីតំណាងដោយអាណត្តិ) សងប្រាក់ចំនួន **$៧៤០,៩៣៦(ប្រាំពីររយសែសិបពាន់ប្រាំបួនរយសាមសិបប្រាំមួយ) ដុល្លារអាមេរិក** ទៅដើមចោទ និងជាចុងបណ្ដឹងតបឈ្មោះ សុ ដ ទកញ្ញា **អ៊ុយ ច័ន្ទធារី** ជាមេធាវីតំណាងដោយអាណត្តិ ។

**២**-បង្គាប់ឲ្យចុងចម្លើយ និងជាដើមបណ្ដឹងតបឈ្មោះ ច (មានលោកស្រី **ទី គឹមស្រ៊ាន** ជាមេធាវីតំណាងដោយអាណត្តិ) សងការខូចខាត សំណងជម្ងឺចិត្ត និងការចំណាយផ្សេងៗក្នុងរឿងក្ដី ចំនួន $៨០,០០០ (ប្រាំបីម៉ឺន)**ដុល្លារអាមេរិក** ទៅដើមចោទ និងជាចុងបណ្ដឹងតបឈ្មោះ ដ (មានកញ្ញា **អ៊ុយ ច័ន្ទធារី** ជាមេធាវីតំណាងដោយអាណត្តិ) ការសុំលើសពីនេះត្រូវច្រានចោល ។

៣-សាលក្រមនេះអាចអនុវត្តបណ្ដោះអាសន្នបាន ត្រង់ចំណុចទី(១) នៃសេចក្ដីសម្រេចបញ្ចប់ ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ និងជាដើមបណ្ដឹងតបឈ្មោះ ច ។

-សាលក្រមនេះទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ ចំពោះមុខមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ និងជាចុងបណ្ដឹងតប កញ្ញា **អ៊ុយ ច័ន្ទធារី** និងមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ និងជាដើមបណ្ដឹងតប លោកស្រី **ទី គឹមស្រ៊ាន** និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ ។

-គូភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: **គោ វណ្ណី**

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

គោ.វណ្ណី

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ៥កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

ទូ.គារ៉ាន់

**ឧបសម្ព័ន្ធទី២**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**
**សាលក្រមរដ្ឋប្បវេណី**
-លេខ: **១៥៤៦ "ត"**
ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩
សំណុំរឿងរដ្ឋប្បវេណីលេខ: ២៣៥០
ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨

# សាលក្រម
# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០១៩ វេលាម៉ោង១០ និង៤៥នាទី ។

**ចៅក្រមជំនុំជម្រះ**

លោក **រស់ ពិសិដ្ឋ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី **ឌី លីឡា** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើមចោទឈ្មោះ ដ អាយុ៦៥ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ រាជធានីភ្នំពេញ ។

ដោយមានអ្នកតំណាងដោយអាណត្តិលោក **ទន់ តារាវិឆាន** អត្តលេខ១៤៩៩T មានការិយាល័យមេធាវីស៊ីនហាន មានទីតាំងនៅផ្សារទំនើបស៊ីធីម៉ល ជាន់ទី៣ ផ្លូវ២១៧ (មហាវិថីមុនីរ៉េត) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

សហចុងចម្លើយឈ្មោះ ច១ ភេទប្រុស អាយុ៤៧ឆ្នាំ សញ្ជាតិខ្មែរ និងប្រពន្ធឈ្មោះ ច២ ភេទស្រី អាយុ៤៧ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានផ្ទះលេខ រាជធានីភ្នំពេញ។

ដោយមានអ្នកតំណាងដោយអាណត្តិលោក **ស៊ឹម ស៊ីថាន** អត្តលេខ១៨៧ មានការិយាល័យមេធាវី ស៊ឹម ស៊ីថាន អាសយដ្ឋានផ្ទះលេខB២ ផ្លូវ៣៧១ ភូមិត្នោតជ្រុំ៤ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

## អង្គហេតុ និងចំណុចវិវាទ

**១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារៈ**

ទី១-បង្គាប់ឱ្យសហចុងចម្លើយ ច១ និងប្រពន្ធឈ្មោះ ៣ៗ សងប្រាក់ដើមចំនួន ៦.០០០( ប្រាំមួយពាន់) ដុល្លារអាម៉េរិក ទៅឱ្យដើមចោទឈ្មោះ ដ វិញ។

ទី២-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ បង់ការប្រាក់ចំនួន១៥០( មួយរយហាសិប) ដុល្លាអាម៉េរិក ក្នុងមួយខែ គិតចាប់ពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ទៅឱ្យដើមចោទឈ្មោះ ដ រហូតសងប្រាក់គ្រប់ចំនួន។

*កំណត់សម្គាល់: សាលក្រមនេះគឺជារឿងកំដាក់សែង ហើយមិនមែនជាសាលក្រមពិតទេ*

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគម្រូទេ

ទី៣-បង្គាប់ឱ្យសហចុងចម្លើយ សងប្រាក់ថ្លៃការខាតបង់ពេវេលា ជំងឺចិត្ត និងសេវាផ្នែកច្បាប់ចំនួន២០.០០០ (ពីរម៉ឺន) ដុល្លារអាម៉េរិក ទៅឱ្យដើមចោទឈ្មោះ ដ ។

ទី៤-ប្រាក់ពន្ធលើពាក្យបណ្ដឹង និងប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

ទី៥-សុំឱ្យតុលាការប្រកាសអនុវត្តជាបណ្ដោះអាសន្នលើប្រាក់ដើមចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាម៉េរិក ។

## ២.ដំណើររឿងក្ដី និងចំណុចវិវាទ

### ២.១.ការសង្ខេបអំពីរឿងក្ដី

ដើមចោទប្ដឹងទាមទារបង្គាប់ឱ្យសងចុងចម្លើយ ច១ និងប្រពន្ធឈ្មោះ ច២ សងប្រាក់ដើម ការប្រាក់ ការខាតបង់ពេលវេលា និងជម្ងឺចិត្ត ដោយផ្អែកលើកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ និងកំណត់ហេតុផ្សះផ្សា សម្រុះសម្រួល ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ។

### ២.២.អង្គហេតុដែលគ្មានវិវាទ

-កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ រវាងឈ្មោះ ច១ និងឈ្មោះ ច២ បានបង្កើតកិច្ចសន្យាខ្ចីប្រាក់ជាមួយឈ្មោះ ដ ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាម៉េរិក គិតអាត្រាការប្រាក់ចំនួន ១៥០ (មួយរយហាសិប) ដុល្លារអាម៉េរិក ក្នុងមួយខែ ដោយមានរយៈពេលខ្ចី ៦ (ប្រាំមួយ) ខែ គឺពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ។

### ២.៣.ចំណុចវិវាទ

-តើការទាមទាររបស់ដើមចោទ ឲ្យចុងចម្លើយអនុវត្តសិទ្ធិលើបំណុលនេះរលត់អាជ្ញាយុកាលហើយ ឬនៅ?

### ២.៤.ការអះអាងរបស់ភាគី

២.៤.១-អ្នកតំណាងដោយអាណត្តិឱ្យភាគីដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ថា: កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ សហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ បានខ្ចីប្រាក់ពីកូនក្ដីខ្លួនចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាម៉េរិក ព្រមទាំងភ្ជាប់ការប្រាក់ចំនួន ១៥០ (មួយរយហាសិប) ដុល្លារអាម៉េរិក ក្នុងមួយខែ ។ ថ្ងៃចុះកិច្ចសន្យាខ្ចីប្រាក់ សហចុងចម្លើយបានយកប្លង់មកដាក់ធានាបំណុលខាងលើនៅកូនក្ដីខ្លួនរួមមាន: ប្លង់ផ្ទះចំនួន០១ប្លង់ ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ របស់មេឃុំ ភ្ជាប់ជាមួយគំនូសប្លង់បង្ហាញទីតាំងដីលេខ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ របស់មេឃុំ និងដីស្រែ០១ប្លង់ មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៨ របស់មេឃុំ ព្រមទាំងភ្ជាប់គំនូសប្លង់បង្ហាញទីតាំងដី និងរូបរាងដីលេខ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៨ របស់មេឃុំ ។

បន្ទាប់ពីថ្ងៃចុះកិច្ចសន្យាខ្ចីប្រាក់រួច សហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ ពុំដែលបង់ការប្រាក់ ឬបង់រំលោះប្រាក់ដើមមកឱ្យកូនក្ដីខ្លួនវិញនោះទេ ហើយកូនក្ដីខ្លួនតែងតែទំនាក់ទំនងទៅសហចុងចម្លើយរហូត តាមរយៈការទំនាក់ទំនងតាមទូរសព្ទ និងការជួបគ្នាជាក់ស្ដែង ដើម្បីដោះស្រាយគ្នាពាក់ព័ន្ធនឹងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ដែលសហចុងចម្លើយពុំបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ។ ពេលនោះសហចុងចម្លើយ តែងតែរកលេសម្ដងជាពីរដង

ម្តងថ្ងៃនេះ ម្តងថ្ងៃនោះ សន្យាថានឹងសងប្រាក់ត្រឡប់មកឱ្យកូនក្តីខ្លួនវិញ ជាបន្តបន្ទាប់រហូតមក ប៉ុន្តែរាល់ការសន្យាទាំងឡាយរបស់សហចុងចម្លើយ គឺសហចុងចម្លើយពុំដែលបានអនុវត្តតាមការសន្យាម្តងណានោះទេ ។ កូនក្តីខ្លួនតែងតែអត់ធ្មត់ និងទុកឱកាសជានិច្ចដល់សហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ ជាច្រើនលើកច្រើនសារ ក្នុងការចូលរួមដោះស្រាយគ្នា ប៉ុន្តែសហចុងចម្លើយនៅតែគ្មានឆន្ទៈក្នុងការសងប្រាក់ត្រឡប់មកឱ្យកូនក្តីខ្លួននោះទេ ។ ទើបនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១៨ កូនក្តីខ្លួន បានប្រគល់សិទ្ធិឱ្យខ្លួន ដើម្បីដាក់បណ្តឹងសម្របសម្រួលគ្នានៅសាលាសង្កាត់ ដើម្បីឱ្យសាលាសង្កាត់ ជួយដោះស្រាយ ជៀសវាងការប្តឹងផ្តល់គ្នាវែងឆ្ងាយនៅតុលាការ ។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ គណៈកម្មការដោះស្រាយទំនាស់សង្កាត់ ដោយមានលោក ●១ , លោក ●២ , និងលោក ●៣ បានធ្វើកំណត់ហេតុផ្សះផ្សា និងសម្របសម្រួល ពេលនោះសហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ បានទទួលស្គាល់ថា ខ្លួនពិតជាបានខ្ចីប្រាក់ពីកូនក្តីខ្លួនពិតប្រាកដមែន និងយល់ព្រមយកដីមួយកន្លែងទទឹង២៥ម៉ែត្រ បណ្តោយ ៥០ ម៉ែត្រ នៅភូមិ សម្រាប់កាត់ទូទាត់សងបំណុលខាងលើទៀតផង ប៉ុន្តែក្រោយមក នៅពេលដែលខ្លួនបានទំនាក់ទំនងទៅសហចុងចម្លើយសួរនាំពីទីតាំងដីនោះ សហចុងចម្លើយពុំបានសហការក្នុងការបង្ហាញទីតាំងដីជាក់លាក់ណាមួយនោះទេ ។

ទង្វើ និងសកម្មភាពរបស់សហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ បានសបញ្ជាក់ឱ្យឃើញនូវចេតនាគេចវេសក្នុងការបំបាត់យកប្រាក់របស់កូនក្តីខ្លួន ដោយប្រើលេសដោះសារតាមគ្រប់រូបភាព បណ្តាលឱ្យកូនក្តីខ្លួនបាត់បង់ផលប្រយោជន៍យ៉ាងធំធេង ។

២.៤.២-អ្នកតំណាងដោយអាណត្តិឱ្យភាគីចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា:

ក-ចម្លើយចំពោះសាលក្រមដែលទាមទារដោយដើមចោទ៖

-សុំឲ្យតុលាការចេញសាលក្រមលើកចោលពាក្យបណ្តឹង ចុះថ្ងៃទី១២-១១-២០១៨ របស់ដើមចោទជាអសារបង់។

-ដើមចោទត្រូវទទួលរ៉ាប់រងនូវប្រាក់ប្រាក់ដាប់ក្តី ។

ខ-ការទទួលស្គាល់ឬមិនទទួលស្គាល់នូវអង្គហេតុដែលអះអាញដោយដើមចោទ៖

-មិនទទួលស្គាល់នូវអង្គហេតុដែលអះអាងដោយដើមចោទ តាមពាក្យបណ្តឹងចុះថ្ងៃទី១២-១១-២០១៨ ដោយខុសច្បាប់ និងភស្តុតាងកំណត់ហេតុផ្សះផ្សារសម្រុះសម្រួល ចុះថ្ងៃទី២២-១០-២០១៨ ដោយខុសច្បាប់ ។

គ-សេចក្តីអះអាងរបស់ចុងចម្លើយ៖

ដើមចោទឈ្មោះ ដ និងចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ បានបង្កើតកិច្ចសន្យាខ្ចីប្រាក់នៅថ្ងៃទី៣០-១២-២០០៨ ។

នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ ដើមចោទឈ្មោះ ដ បានធ្វើពាក្យបណ្តឹងប្តឹងចូលសាលាសង្កាត់ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ សាលាសង្កាត់ ចំណាត់ការបានកំណត់ហេតុផ្សះផ្សារសម្រុះសម្រួលឲ្យចុងចម្លើយ ច១ បានទទួលស្គាល់ថាពិតជាបានខ្ចីប្រាក់ដើមចោទ ដ ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាម៉េរិក ពិតប្រាកដមែន ។

ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ ដើមចោទឈ្មោះ ច័ន្ទ ធរណី បានធ្វើពាក្យបណ្តឹង ចូលតុលាការ ប្តឹងទាមទារប្រាក់ពីចុងចម្លើយ (ផៃ សារ៉ន) និងប្រពន្ធ ប៉ិច ចិន្តា តាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។ ដ

អង្គហេតុដូចខាងលើ ច១ ាកចៅក្រ ច២ ន្ទុករឿងក្តីមេត្តាពិចារណា

ដើមចោទឈ្មោះ ច័ន្ទ ធរណី និងចុងចម្លើយឈ្មោះ ផៃ សារ៉ន និងប្រពន្ធឈ្មោះ ប៉ិច ចិន្តា បាន បង្កើតកិច្ចសន្យាខ្ចីប្រាក់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។

លុះមកដល់ថ្ងៃទី ដ ក្រា ឆ្នាំ២០១៨ ដើមចេ ច១ ពាក្យបណ្តឹងចូល ច២ ង្កាត់ ពន្សាំប្តឹងទាមទារប្រាក់ គឺរយៈពេលកន្លងទៅ១០ឆ្នាំហើយ មកដល់អំឡុងពេលអនុវត្តសិទ្ធិធ្វើពាក្យ បណ្តឹងទាមទារប្រាក់នៅពេលនេះ មិនមានភាពត្រឹមត្រូវតាមច្បាប់នោះទេ បញ្ញត្តិមាត្រា៤៨០ មាត្រា មាត្រា៤៨២ នៃក្រមរដ្ឋប្បវេណី ។

លុះមកដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ សាលាសង្កាត់ពន្សាំងលោកចំណាត់ការបានផ្សះ ផ្សារសម្រុះសម្រួលលើកិច្ចសន្យាខ្ចីប្រាក់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨ ។ ឲ្យចុងចម្លើយឈ្មោះ ផៃ សារ៉ន និងទទួលពិតជាបានខ្ចីប្រាក់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។ ឲ្យចុងច ឈ្មោះ ផៃ សារ៉ន និងទទួល ពិតជាបានខ្ចីប្រាក់ដើមចោទ (ច័ន្ទធរណី) ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាម៉េរិក ។ នោះក៏ ច១ ត្រឹមត្រូវតាមច្បាប់នោះដែរ បញ្ញត្តិមាត្រា៤៨០ មាត្រា៤៨១ និងមាត្រា៤៨២ ក្រមរ ច១ ។

ដូចនេះចំពោះឯកស ដ ជាកំណត់ហេតុផ្សះផ្សារសម្រុះសម្រួលចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ របស់សាលាសង្កាត់ពន្សាំង ដែលលោកមេធាវី ទន់ តារាវិឆាន តំណាងដោយអាណត្តិឲ្យ ដើមចោទ ដាក់ជូនមកតុលាការនោះ នោះពុំមានភាពត្រឹមត្រូវទេ សុំបដិសេធន៍ចោលដោយខុសច្បាប់ បញ្ញត្តិ៤៨០ មាត្រា៤៨១ និងមា ២ ក្រមរដ្ឋប្បវេណី ។

លុះដល់ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៨ ដើមចោទឈ្មោះ ច័ន្ទ ធរណី បានដាក់ពាក្យបណ្តឹងចូល មកតុលាការ ប្តឹងទាមទារប្រាក់ពីចុងចម្លើយ (ផៃ សារ៉ន) និងប្រពន្ធឈ្មោះ ប៊ិន ចន្តា តាមកិច្ចសន្យាខ្ចី ប្រាក់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។ ហើយមកដល់អំឡុងពេ ដ ទ្ធិធ្វើពាក្យបណ្តឹង ទាមទារ ប្រាក់នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅរ ច១ មានភាពត្រឹមត្រូវ ច២ ទេ គឺផុតអាជ្ញាយុ កាល នៃបណ្តឹងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល បញ្ញត្តិ៤៨០ មាត្រា៤៨១ និងមាត្រា៤៨២ ក្រមរដ្ឋប្បវេណី ។ គប្បីសុំឱ្យតុលាការលើកបណ្តឹងចោលតាមបញ្ញាត្តិមាត្រា៨១ ក្រមនីតិវិធីរប្បវេណី ។

អ្នកតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍តបថាៈ ខ្លួនសូមឱ្យលោក ចៅក្រម ខ្លួនសូមជម្រាបប្រាប់អង្គសវនាការនូវចំណុចវិវាទនៅក្នុងនីតិវិធីត្រៀម ។ នៅក្នុងថ្ងៃនេះ ភាគី ទាំងពីរបានបង្ហាញឆន្ទៈកត់សម្គាល់ គឺពាក់ព័ន្ធសិទ្ធិលើបំណុលនេះ ពាក់ព័ន្ធនឹងកិច្ចសន្យាខ្ចីប្រាក់គឺ ចុះ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ បើយើងក្រឡេងមើលនៅក្នុងពាក្យបណ្តឹង ក៏ប៉ុន្តែមិនមែនមានន័យថាកូន ក្តីរបស់ខ្លួន គាត់មិនបានប្រើប្រាស់សិទ្ធិនៅក្នុងការទាមទារឲ្យចុងចម្លើយបង់ប្រាក់ ព្រមទាំងការប្រាក់ នោះទេ គឺគាត់ទាមទារជារៀងរាល់ថ្ងៃ ដោយសារតែជាកូនចៅទុកឲ្យឱកាសឲ្យស្រីហាចុងចម្លើយ សង ប្រាក់ដើម និងការមកឲ្យខ្លួនវិញ ម្តងមួយថ្ងៃ ឬពីរថ្ងៃ គឺមិនមែនមានន័យថាគាត់បោះបង់សិទ្ធិគាត់ ក្នុង ការមិនអនុវត្តកាតព្វកិច្ចសងតាំងពីឆ្នាំ២០០៨ ចឹងនោះទេ គឺគាត់នៅតែទាមទារ ដោយសារតាំងពីគាត់

កំណត់សម្គាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

មកខ្ចីប្រាក់នោះមក ទំនាក់ទំនងរវាងកូនក្តីខ្លួន និងចុងចម្លើយក៏នៅតែបន្តការងារនឹងគ្នាដែរ ។ គាត់បានសន្យានឹងសងប្រាក់ សងប្រាក់ ។ តែក្នុងករណីដែលចុងចម្លើយអះអាងថាមិនសងទេ តែបើកូនក្តីខ្លួនមិនប្តឹងនោះពេលហ្នឹង ធ្វើឲ្យផុតសិទ្ធិលើបំណុល ខ្លួនទទួលស្គាល់ សិទ្ធិលើបំណុលក្នុងរយៈ ៥ ឆ្នាំហ្នឹងគឺដាច់ ។ ប៉ុន្តែចុងចម្លើយនៅតែទទួលស្គាល់ជានិច្ច នៅពេលកូនក្តីខ្ញុំទាមទារ ហើយចុងចម្លើយសុំម្តងថ្ងៃនេះ សុំម្តងថ្ងៃនេះ ជាហេតុធ្វើឲ្យកូនក្តីខ្លួនមិនបានធ្វើពាក្យបណ្តឹង ។ ក៏ប៉ុន្តែបើគាត់និយាយថាខ្លួនឈប់សងហើយ អ្នកឯងចង់ប្តឹងទៅណាទៅប្តឹងទៅ កូនក្តីរបស់ខ្លួនមិនប្រើប្រាស់សិទ្ធិនៅពេលហ្នឹងខ្លួនទទួលស្គាល់ ។ តែផ្ទុយទៅវិញកូនក្តីខ្លួនបានទុកពេលកូនបំណុលរកលុយមកសងខ្លួន ម្តងដងជាពីរដង សហចុងចម្លើយមួយទៀតក៏ទទួលស្គាល់ដែលថា នឹងសងនឹងសង ដែលជាហេតុជាកូនចៅគាត់មិនទាន់ដាក់ពាក្យប្តឹងទេ ។ រហូតដល់ថ្ងៃដែលខ្លួនដាក់ពាក្យបណ្តឹងសម្របសម្រួលនៅសង្កាត់ ពីខែកញ្ញា ឆ្នាំ២០១៨ គឺជាថ្ងៃដែល ចុងចម្លើយហាក់ដូចជាប្រងើយក្រតើយនឹងការសងប្រាក់ ទើបកូនក្តីខ្លួនសម្រេចចិត្តដាក់ពាក្យបណ្តឹង ។ ដូច្នេះខ្លួនគ្រាន់តែទាញចំណាប់អារម្មណ៍ពាក់ព័ន្ធទៅនឹងការទទួលស្គាល់សិទ្ធិលើបំណុលនេះ គឺចុងចម្លើយនៅតែមានឆន្ទៈទទួលស្គាល់ការសង មិនមែនមានរឿងថាកូនក្តីខ្លួនបានបង់បោះសិទ្ធិក្នុងទាមបំណុល ត្រង់ចំណុចនេះខ្លួនគាត់តែការទាញចំណាប់អារម្មណ៍ជូនអង្គសវនាការ ។

អ្នកតំណាងដោយអាណត្តិឲ្យសហចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍តបវិញថា: ខ្លួនសូមគោរពលោកចៅក្រម ការលើឡើងរបស់មេធាវីការចោទប្រកាន់លើកូនក្តីខ្លួន មិនមានអ្វីជាពិតប្រាកដជាលាយលក្ខអក្សរទេ ខ្លួនសុំបដិសេធចោល ។ ហេតុផលដែលជាលាយល័ក្ខណ៍អក្សរនោះ ជាហេតុផលពិតតាមទៅផ្លូវច្បាប់ ទី១សូមពិនិត្យមើលបញ្ញត្តិមាត្រា ៤៨០ មាត្រា ៤៨១ មាត្រា ៤៨២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ពិនិត្យទៅលើ មាត្រា៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០០៨ ពាក្យបណ្តឹងចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១៨ មានន័យថា១០ ឆ្នាំជាង ដាក់ចូលសង្កាត់ ចឹងកំណត់ហេតុផ្សះផ្សារនេះខុសច្បាប់ ពាក្យបណ្តឹងក៏ខុសច្បាប់ ។ ចឹងពាក្យបណ្តឹងមួយទៀតត្រូវចូលតុលាការ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ ដប់ឆ្នាំជាង ឯកសារចម្លើយរបស់ខ្លួនចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៩ កំណត់ហេតុស្តីពីនីតិវិធីត្រៀមចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០១៩ ឯកសារចម្លើយស្តីពីនិតិវិធីត្រៀមទាញហេតុផលចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ ឯកសារចម្លើយស្តីពីនីតិវិធីត្រៀមចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ ពាក់ព័ន្ធមកដល់សវនាការនេះខ្លួនសុទ្ធសឹងធ្វើជាលាយល័ក្ខណ៍អក្សរ និងពាក់ព័ន្ធនឹងច្បាប់ទាំងអស់ បើចឹងមានន័យថា បើសិននិយាយអំពីផ្លូវច្បាប់ ចូលមកដល់តុលាការហើយ ត្រូវនិយាយពីច្បាប់ទាំងមេធាវី និងតុលាការ ។

អ្នកតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍តបថា: ខ្លួនគន្លងមកតាំងពីនីតិវិធីត្រៀមរហូតដល់មកដល់ទាញហេតុផលដោយផ្ទាលើមាត់ លោកមេធាវីសហភាគី នៅតែប្រើពាក្យបណ្តឹងរបស់ខ្លួនផ្ទុយនឹងច្បាប់ ត្រង់ចំណុចនេះខ្ញុំគិតថា ជាឆន្ទានុសិទ្ធិរបស់តុលាការ លោកចៅក្រមជាអ្នកពិនិត្យថា ពាក្យបណ្តឹងនេះផ្ទុយពីច្បាប់ ឬមិនផ្ទុយពីច្បាប់យ៉ាងម៉េច ។ ប្រសិនជាភាគីទាមទារសិទ្ធិលើបំណុលរបស់ខ្លួនផុតរយៈ គប្បីតុលាការលើការទាមទារលើកពាក្យបណ្តឹងចោល ក៏ប៉ុន្តែពាក្យបណ្តឹងផ្ទុយច្បាប់ ស្តាប់ទៅហាក់បីដូចជាខ្លួន ការតាក់តែងពាក្យបណ្តឹងមុន គឺខុសច្បាប់ទាំងស្រុង

តែម្តង ត្រង់ចំណុចនេះខ្លួនគិតថា ការប្រើប្រាស់ពាក្យពេជ្រមួយនេះ តែជាឆន្ទានុសិទ្ធិរបស់លោកចៅក្រម ប្រសិនយល់ឃើញថា ពាក្យបណ្តឹងរបស់ខ្ញុំផុតរយៈពេលនៃការទាមទារ ខាងកូនក្តីខ្ញុំក៏អត់ចិត្តទៅតាមហ្នឹងដែរ ។ ក៏ប៉ុន្តែការប្រើប្រាស់ពាក្យពេជ្ររបស់លោកមេធាវី ធ្វើឲ្យខ្ញុំយល់ឃើញថាហាក់ដូចជាវាធ្ងន់ ។

អ្នកតំណាងដោយអាណត្តិឱ្យភាគីចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍តបវិញថា: បើផ្អែកលើផ្លូវច្បាប់ មាត្រា៤៨០ មាត្រា៤៨១ មាត្រា ៤៨២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការផុតអាជ្ញាយុកាលនៃបណ្តឹង ។

អ្នកតំណាងដោយអាណត្តិឱ្យភាគីដើមចោទបានធ្វើសេចក្តីថ្លែងការណ៍តបថា: ខ្លួនមិនចង់វែកញែកបញ្ហាផ្លូវច្បាប់ជាមួយមេធាវីចុងចម្លើយដែរ ប៉ុន្តែខ្លួនយល់ថាពាក្យបណ្តឹងរបស់ខ្ញុំបាទគឺធ្វើស្របទៅនឹងមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដូច្នេះចំណុចខ្វះខាតនៅក្នុងពាក្យបណ្តឹងមើលទៅ ពុំមានភាពខ្វះខាតក្នុងការកែតម្រូវទេ ។ ចំពោះមានត្រាមាត្រា ៤៨០ មាត្រា ៤៨១ មាត្រា ៤៨២ នៃក្រមរដ្ឋប្បវេណី គឺនិយាយសិទ្ធិលើបំណុល រយៈពេលអនុវត្តសិទ្ធិលើបំណុល ដូច្នេះការសម្រេចអំពីពាក្យបណ្តឹង បើពាក្យបណ្តឹងនេះផុតសិទ្ធិលើបំណុលតុលាការអាចសម្រេចលើកចោលបាន ប៉ុន្តែលោកមេធាវីសហាភាពលើថាពាក្យបណ្តឹងខ្លួនផ្ទុយច្បាប់ មានន័យថាវាខុស ព្រោះបណ្តឹងខ្លួនមិនខុស តែសហាភាតាថា ខុសខ្លួនមិនដឹងថាយ៉ាងម៉េចទេ ព្រោះមេធាវីមិនមែនជាអ្នកសម្រេចបែបណានោះទេ ។

## សំអាងហេតុ

### ក-ការវិនិច្ឆ័យចំពោះចំណុចវិវាទៈ

-តើការទាមទាររបស់ដើមចោទឲ្យចុងចម្លើយអនុវត្តសិទ្ធិលើបំណុលនេះ រលត់អាជ្ញាយុកាលហើយ ឬនៅ ?

១-អ្នកតំណាងដោយអាណត្តិឲ្យភាគីដើមចោទបានអះអាងថា: កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ សហាចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ បានខ្ចីប្រាក់ពីកូនក្តីខ្លួនចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាម៉េរិក ព្រមទាំងភ្ជាប់ការប្រាក់ចំនួន ១៥០ (មួយរយហាសិប) ដុល្លារអាម៉េរិក ក្នុងមួយខែ ។ បន្ទាប់ពីថ្ងៃចុះកិច្ចសន្យាខ្ចីប្រាក់រួច សហាចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ ពុំដែលបង់ការប្រាក់ ឬបង់រំលោះប្រាក់ដើមមកឱ្យកូនក្តីខ្លួនវិញនោះទេ ។ ទើបនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ កូនក្តីខ្លួន បានប្រគល់សិទ្ធិឱ្យខ្លួន ដើម្បីដាក់បណ្តឹងសម្របសម្រួលគ្នានៅសាលាសង្កាត់ ដើម្បីឱ្យសាលាសង្កាត់ ជួយដោះស្រាយ ជៀសវាងការប្តឹងផ្តល់គ្នាវែងឆ្ងាយនៅតុលាការ ។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ គណៈកម្មការដោះស្រាយទំនាស់សង្កាត់បានធ្វើកំណត់ហេតុផ្សះផ្សា និងសម្របសម្រួល ពេលនោះសហាចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ បានទទួលស្គាល់ថា ខ្លួនពិតជាបានខ្ចីប្រាក់ពីកូនក្តីខ្លួនពិតប្រាកដមែន ។

២-អ្នកតំណាងដោយអាណត្តិឱ្យភាគីសហាចុងចម្លើយបានអះអាងថា: ដើមចោទឈ្មោះ ដ និងចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ បានបង្កើតកិច្ចសន្យាខ្ចីប្រាក់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។ លុះមកដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ សាលាសង្កាត់ លោកចំណាត់ការបានផ្សះផ្សាសម្រុះសម្រួលលើកិច្ចសន្យាខ្ចីប្រាក់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨ ឲ្យចុងចម្លើយឈ្មោះ

កំណត់សំគាល់ៈ សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

ច១ និងទទួលពិតជាបានខ្ចីប្រាក់ដើមចោទ ដ ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាម៉េរិក ។ នោះក៏ពុំមានភាពត្រឹមត្រូវតាមច្បាប់នោះដែរ បញ្ញត្តិមាត្រា៤៨០ មាត្រា៤៨១ និងមាត្រា៤៨២ ក្រមរដ្ឋប្បវេណី ។ លុះដល់ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៨ ដើមចោទឈ្មោះ ដ បានដាក់ពាក្យបណ្តឹងចូលមកតុលាការ ប្តឹងទាមទារប្រាក់ពីចុងចម្លើយ ច១ និងប្រពន្ធឈ្មោះ ច២ តាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។ ហើយមកដល់អំឡុងពេលអនុវត្តសិទ្ធិធ្វើពាក្យបណ្តឹង ទាមទារប្រាក់នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅពេលនេះ មិនមានភាពត្រឹមត្រូវតាមច្បាប់ទេ គឺផុតអាជ្ញាយុកាល នៃបណ្តឹងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល បញ្ញត្តិ៤៨០ មាត្រា៤៨១ និងមាត្រា៤៨២ ក្រមរដ្ឋប្បវេណី ។

៣-ផ្អែកតាមភស្តុតាងកំណត់ហេតុផ្សះផ្សា សម្រុះសម្រួលលេខ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ របស់សាលាសង្កាត់ បានបង្ហាញឱ្យឃើញថា ភាគីសហចុងចម្លើយបានទទួលស្គាល់នូវអត្ថិភាពនៃកាតព្វកិច្ចរបស់ខ្លួន ដែលជាហេតុនាំឱ្យផ្អាកអាជ្ញាយុកាល អំឡុងពេលនៃអាជ្ញាយុកាលកន្លងផុតនោះ ក្លាយទៅជាគ្មានន័យ ហើយអាជ្ញាយុកាលថ្មីនឹងចាប់ផ្តើមមានដំណើរការចាប់ពីថ្ងៃដែលសហចុងចម្លើយទទួលស្គាល់នូវអត្ថិភាពនៃកាតព្វកិច្ចរបស់ខ្លួន (បញ្ញត្តិមាត្រា៤៨៩ ចំណុច គ នៃក្រមរដ្ឋប្បវេណី) ។

**ខ-ការវិនិច្ឆ័យចំពោះការទាមទារៈ**

១-បង្គាប់សហចុងចម្លើយ ច១ និងប្រពន្ធឈ្មោះ ច២ សងប្រាក់ដើមចំនួន ៦.០០០( ប្រាំមួយពាន់) ដុល្លារអាម៉េរិក គប្បីតុលាការទទួលស្គាល់ការទាមទារ ដោយហេតុថា ទី១ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ រវាងឈ្មោះ ច១ និងឈ្មោះ ច២ បានបង្កើតកិច្ចសន្យាខ្ចីប្រាក់ជាមួយឈ្មោះ ដ ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាម៉េរិក គិតអាត្រាការប្រាក់ចំនួន ១៥០ (មួយរយហាសិប) ដុល្លារអាម៉េរិក ក្នុងមួយខែ ដោយមានរយៈពេលខ្ចី ៦ (ប្រាំមួយ) ខែ គឺពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ (ភស្តុតាងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨) ។ ទី២ ផ្អែកតាមការវិនិច្ឆ័យចំពោះចំណុចវិវាទ ឃើញថាភាគីដើមចោទនៅតែមានអត្ថភាពសិទ្ធិលើបំណុលចំពោះសហចុងចម្លើយ ដែលអាចទាមទារឱ្យសហចុងចម្លើយធ្វើការសងត្រឡប់មកវិញ ហេតុនេះគប្បីតុលាការសម្រេចតាមការទាមទារ ។

២-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ បង់ការប្រាក់ចំនួន ១៥០( មួយរយហាសិប) ដុល្លាអាម៉េរិក ក្នុងមួយខែ គិតចាប់ពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ទៅឱ្យដើមចោទឈ្មោះ ដ រហូតសងប្រាក់គ្រប់ចំនួន ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ឃើញថា គូភាគីបានកំណត់នូវចំនួនអត្រាការប្រាក់ ១៥០ (មួយរយហាសិប) ដុល្លារអាម៉េរិក ក្នុងមួយខែ ឃើញថាការប្រាក់ដែលគូភាគីបានព្រមព្រៀងគ្នានៅពេលបង្កើតកិច្ចសន្យាខ្ចីប្រាក់នោះ មានចំនួនលើសពីការប្រាក់ដែលមានកំណត់ ហេតុដូច្នេះគប្បីតុលាការទទួលការទាមទាររបស់ដើមចោទត្រង់ចំណុចត្រឹមមួយផ្អែកដោយផ្អែកតាមបញ្ញត្តិមាត្រា៣១៨ ក្រមរដ្ឋប្បវេណី ។

៣-បង្គាប់ឱ្យសហចុងចម្លើយ សងប្រាក់ថ្លៃការខាតបង់ពេលវេលា ជំងឺចិត្ត និងសេវាផ្នែកច្បាប់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាម៉េរិក ទៅឱ្យដើមចោទឈ្មោះ ដ ករណីនេះជាការទាមទារ

ប្រាក់ដោយផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ តុលាការយល់ឃើញថា សហចុងចម្លើយមិនបានបំពានដល់ផលប្រយោជន៍បុគ្គល ដូចជា កេរ្តិ៍ឈ្មោះ អាយុជីវិត រូបរាងកាយជាដើម នោះទេ ហើយដើមចោទក៏គ្មានភស្តុតាងបញ្ជាក់អំពីព្យសនកម្មខាងផ្លូវចិត្តជូនតុលាការពិនិត្យផងដែរ ។ ម្យ៉ាងទៀតការខាតបង់ពេលវេលា និងសេវាកម្មមេធាវី វាក្លាយជាកម្មវត្ថុសំណងការខូចខាតបាន តែក្នុងករណីដែលភាគីអាចព្យាករណ៍ទុកមុន នៅពេលបង្កើតកិច្ចសន្យា ប៉ុន្តែករណីនេះភាគីនៃកិច្ចសន្យា មិនបានគិតពិចារណាពីចំណុចនេះនៅពេកបង្កើតកិច្ចសន្យាទេ ដូច្នេះសេវាមេធាវីមិនអាចគិតចូលក្នុងទំហំនៃសំណងការខូចខាតបានឡើយ (មាត្រា៤០១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) ។ ហេតុដូច្នេះគប្បី សម្រេចច្រានចោលការទាមទារ ។

៤-ចំពោះប្រាក់ប្រដាប់ក្ដី ក្នុងរឿងក្ដីនេះ ទាមទារចម្បងរបស់ដើមចោទ តុលាការទទួលស្គាល់ហេតុនេះហើយប្រាក់ប្រដាប់ក្ដី គឺសហចុងចម្លើយទទួលបន្ទុកទាំងស្រុង (មាត្រា៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

៥.ដើមចោទទាមទារប្រកាសអនុវត្តបណ្ដោះអាសន្នចំពោះទាមទារខាងលើ ដោយហេតុថាៈ ការទាមទាររបស់ដើមចោទ គឺជាការទាមទារប្រាក់ (ការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ) តុលាការអនុវត្តបណ្ដោះអាសន្នលើប្រាក់ដើម (មាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

## សេចក្ដីសម្រេចបញ្ចប់

១-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ សងប្រាក់ទៅឱ្យដើមចោទឈ្មោះ ដ ដូចខាងក្រោម ៖

ក-ប្រាក់ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាម៉េរិក ។

ខ-ការប្រាក់ក្នុងអត្រា ៥% (ប្រាំ) ភាគរយ ក្នុង១ (មួយ) ឆ្នាំ នៃប្រាក់ ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាម៉េរិក គិតចាប់ពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ រហូតដល់ពេលសងគ្រប់ចំនួន ។

២-ច្រានចោលការទាមទាររបស់ដើមចោទត្រង់ចំណុចទី៣ ។

៣-សាលក្រមនេះអាចអនុវត្តបណ្ដោះអាសន្នបានចំពោះចំណុចទី១.ក នៃសេចក្ដីសម្រេចបញ្ចប់។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីសហចុងចម្លើយ ។

សាលក្រមនេះបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ ចំពោះមុខអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ និងអ្នកតំណាងដោយអាណត្តិឱ្យសហចុងចម្លើយ ។

ទុកសិទ្ធិឲ្យប្ដឹងឧទ្ធរណ៍តាមបញ្ញត្តិមាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រាៈ រស់ ពិសិដ្ឋ**

បានឃើញ និងឯកភាព

**ចៅក្រមជំនុំជម្រះ**

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៩កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦២

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩

**ក្រឡាបញ្ជី**